ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Mar-2015, 15:46
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៧នាទី**

**សវនាការលើកទី២៥៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែរន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី
កញ្ញា រ៉ូប៊ីន្ទី ក្រូហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*
លោក សេង ប៊ុនឃាង
កញ្ញា សុង ឆវ័ន្ត

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ
លោក ស្ហួន វិសាល
លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែរកគែន

*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ូច អរុណ

លោកស្រី ស៊ួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សួន វិសាល | ខ្មែរ |
| លោក មឿន សុវណ្ណ (មេធាវីប្រឹក្សាសាក្សី) | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក អាកទួរ វែកគែន | បារាំង |
| លោក នាង អ៊ូច ហៅ តាសាន (2-TCW-803) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក នាង អ៊ុច ហៅ តាសាន** (2-TCW-803)

សួរដោយលោក សួន វិសាល ផ្តើមពី ......................................................................ទំព័រ ៥
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី........................................................................ទំព័រ ៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៧:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី នាង អ៊ូច ដែលនឹងសួរដោយក្រុមមេធាវីការពារក្តី។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺលោក នាង អ៊ូច លោកនិងមេធាវីប្រឹក្សាលោក មឿន សុវណ្ណ មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ហើយនៅថ្ងៃនេះមានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-948។ សាក្សីរូបនេះបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែក កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ហើយសាក្សីរូបនេះនឹងមានមេធាវីប្រឹក្សា គឺលោក មឿន សុវណ្ណ ផងដែរ។ សូមអរគុណលោកប្រធាន។

[០៩:០៩:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា។ អង្គជំនុំជម្រះបាន

ទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនា-ការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព គាត់សុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥។ ដោយមេធាវីការពារក្ដីរបស់គាត់បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំព្យាបាលសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះជាប្រចាំ ហើយជាពិសេសនៅពេលអង្គុយយូរ និងផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:១១:០១]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គ-ជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:១១:៤០]

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។ ហើយជាដំបូងនេះ សូមជូនទៅក្រុមមេធាវីការពារក្ដីលោក

នួនជា។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់។ មុននឹងមេធាវីជាតិ សហការីរបស់ខ្ញុំឡើងសួរ ខ្ញុំសូមសួរបញ្ជាក់ គឺថាយើងមានពេលវេលាស្មើនឹងសហព្រះរាជអាជ្ញា គឺប្រាំវគ្គ។ ដូច្នេះយើងនឹងបន្តរហូតដល់ថ្ងៃស្អែក។ ប៉ុន្តែ ខ្ញុំសូមធានាថា ខ្ញុំនឹងសសួររហូតទាល់តែចប់ថ្ងៃនេះតែប៉ុណ្ណោះ គឺពេលវេលាសម្រាប់ក្រុមយើងខ្ញុំ។

**ប្រធានអង្គជំនុំ៖**

ទាំងពីរក្រុមហ្នឹង គឺមានពេលវេលា១ថ្ងៃ ហើយនិងមួយវគ្គនៃសវនាការ។ បានន័យថា១ថ្ងៃនេះ ហើយនិងមួយវគ្គថ្ងៃស្អែក ទាំងពីរក្រុម។ បាទ ទាំង នួន ជា, ទាំងខៀវ សំផន។

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណលោកប្រធាន។ យើងខ្ញុំព្យាយាមបញ្ចប់ឲ្យបានចប់នៅត្រឹមថ្ងៃនេះ។ សូមអរគុណ។

[០៩:១៣:១១]

**លោក សួន វិសាល៖**

សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការទាំងមូល។ ប៉ុន្តែមុននឹងខ្ញុំសួរទៅសាក្សីរូបនេះ ខ្ញុំបាទស្នើសុំដាក់សំណើមួយជូនលោកចៅក្រម និងអង្គជំនុំជម្រះសម្រេចទាក់ទងទៅនឹងនីតិវិធីសួរសាក្សី។ តើលោក -- ខ្ញុំចំណាយពេលប្រហែលជា ៥នាទីអីទេ តើលោកចៅក្រមអនុញ្ញាតទេបាទ?

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញ!

**លោក សួន វិសាល៖**

បាទ សូមអរគុណ។ កាលពីម្សិលមិញ យើងទាំងអស់គ្នានៅទីនេះ យើងសង្កេតឃើញថា លោកចៅក្រម ម៉ាកឡាវែន៍ គឺថាបានសួរសំណួរទៅសាក្សីរូបនេះ អស់រយៈពេលកន្លះថ្ងៃជាង -- ជាងកន្លះថ្ងៃ។ ខ្ញុំសង្កេតឃើញថា ការសួររបៀបនេះគឺថា គាត់ហាក់ដូចជាដើរតួដូចជាព្រះរាជអាជ្ញាអ៊ីចឹងដែរ។ គឺថាគាត់សួរដេញដោលសាក្សី--

**ប្រធានអង្គជំនុំ៖**

មិនមែនលោកមានវេទិកាមកទិតៀនចៅក្រមទេ ចៅក្រមបានជម្រាបហើយ ចៅក្រមជាគោល-

ការណ៍ត្រូវតាំងសំណួរដេញដោលជាមុន នីតិវិធីនេះគឺនីតិវិធីតាមនីតិវិធីកម្ពុជា។ ប៉ុន្តែដោយសារអង្គជំនុំជម្រះមានបំណងជំរុញល្បឿនកិច្ចដំណើរការនីតិវិធីសវនាការ ទើបអង្គជំនុំជម្រះរៀបចំធ្វើការបែងចែកពេលវេលាទៅឲ្យភាគី អាស្រ័យលើលទ្ធភាពជាក់ស្តែង។ អង្គជំនុំជម្រះមានបទពិសោធន៍មួយថា នៅក្នុងអំឡុងពេលនៃដំណើរការសវនាការកន្លងមកនេះ យើងធ្វើមានប្រសិទ្ធភាពដែលគួរឲ្យយកជាបានការនោះ គឺឲ្យភាគីសួរដេញដោល។ បន្ទាប់មក គឺអង្គជំនុំជម្រះអាចសួរៗនៅចន្លោះពេលណាក៏បានដែរ ឲ្យតែអង្គជំនុំជម្រះចង់បញ្ជាក់បន្ថែមលើបញ្ហាណាមួយ។ ដូច្នេះ លោកមេធាវីមិនគប្បីពាក់ព័ន្ធជាមួយអង្គជំនុំជម្រះទេ ទាំងពីពេលវេលា ទាំងនីតិវិធីនៃដំណើរការសវនាការ។

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកយកវេទិកាមកទិតៀនអង្គជំនុំជម្រះទេ។ ពិនិត្យមើលឡើងវិញ មិនមែនវេទិកាទិតៀនអង្គជំនុំជម្រះនោះឡើយ។ ណេះ! យើងមិនច្បាស់ ហើយបើសិនវាច្បាស់ លោកអាចបង្ហាញនូវក្រមសីលធម៌វិជ្ជាជីវៈ ឬក៏លក្ខន្តិកៈមេធាវីរបស់លោកដើម្បីបញ្ជាក់លើបញ្ហានេះឲ្យយើងក៏បានដែរ។

[០៩:១៥:២៧]

**លោក សួន វិសាល៖**

សូមអរគុណលោកប្រធាន ប៉ុន្តែអ្វីដែលខ្ញុំលើកឡើង គឺផ្អែកតាមមូលដ្ឋានច្បាប់។ អ៊ីចឹង ខ្ញុំមិនទាន់បានបង្ហាញមូលដ្ឋានច្បាប់ លោកចៅក្រមកាត់ខ្ញុំតែម្តង តើខ្ញុំបញ្ជាក់ដោយរបៀបណាកើត?

**ប្រធានអង្គជំនុំ៖**

យើងសួរថា ឥឡូវលោកសួរសំណួរអត់? បើសិនជាសួរពាក់ព័ន្ធជាមួយអង្គជំនុំជម្រះ គឺលោកអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើនីតិវិធីពាក់ព័ន្ធនឹងយកវេទិកាទិតៀនអង្គជំនុំជម្រះទេ!

**លោក សួន វិសាល៖**

អូខេ! អ៊ីចឹងបើសិនលោកចៅក្រមមិនអនុញ្ញាតទេ ខ្ញុំនឹងបន្តសំណួរបាទ។ សូមអរគុណ។ ប៉ុន្តែមូលដ្ឋានទាំងអស់នេះ យើងនឹងប្តឹងឧទ្ធរណ៍នៅពេលក្រោយ។

**ប្រធានអង្គជំនុំ៖**

តាមចិត្តរបស់លោកចុះ!

**លោក សួន វិសាល៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សួន វិសាល៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរមួយចំនួនបាទ។ កាលពីម្សិលមិញ លោកបានជម្រាបជូនអង្គសវនាការអំពីការលោកត្រូវបានតែងតាំងទៅឱ្យធ្វើការជាជំនួយការនៅស្រុកត្រាំកក់។ ទន្ទឹមនឹងហ្នឹងលោកបានគេចាត់តាំងឱ្យទទួលខុសត្រូវនៅឃុំលាយបូរ។ ខ្ញុំចង់សួរលោកថា តើនៅក្រៅពីឃុំលាយបូរតើលោកមានបានគេចាត់តាំងឱ្យទទួលខុសត្រូវឃុំណាផ្សេងទេ?

[០៩:១៦:៥៩]

**លោក នាង អ៊ួច៖**

**ឆ៖** ខ្ញុំមិនមែនគេចាត់តាំងឱ្យទទួលខុសត្រូវឃុំលាយបូរទេ តែការស្នាក់នៅរបស់ខ្ញុំ គឺនៅមុខសហករណ៍លាយបូរ ក្នុងឃុំលាយបូរ។ ឯឃុំផ្សេងៗទៀត ក៏មិនមានថ្នាក់លើណាចាត់តាំងឱ្យខ្ញុំទទួលខុសត្រូវឃុំណាមួយទេ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកទៅធ្វើជាជំនួយការនៅក្នុងស្រុកត្រាំកក់នោះ តើការងារជាក់លាក់របស់លោកធ្វើអីដែរ?

**ឆ៖** ការងារជាក់លាក់របស់ខ្ញុំ គឺម្តងគេឱ្យទៅធ្វើប្រឡាយ ធ្វើភ្លឺ ធ្វើការដ្ឋាន តាមការដ្ឋានស្រែចំការ។ ដូច្នេះ មិនមានការងារជាក់លាក់អី ពិតប្រាកដនោះទេ។ តែភាគច្រើន គឺនៅតាមប្រឡាយ តាមភ្លឺស្រែ តាមការដ្ឋានស្រែ តាមស្ថានីយបូមទឹក។

**ស៖** ភាគច្រើននៃការងាររបស់លោកនៅពេលនោះ តើលោកច្រើនចុះទៅនៅឃុំណា?

**ឆ៖** ដំបូង ខ្ញុំចុះទៅខាងប្រឡាយមួយខ្សែ ដែលទប់ស្ទឹងស្លាគូនៅទំនប់លោក ហើយជីកកាត់ខាងកើតវត្តមួយ ប្រឡាយនេះចូលមកទំនប់ខ្ពបត្របែក ចម្ងាយប្រហែលជាជាង១០គីឡូម៉ែត្រ។ ហើយទី២ គឺខ្ញុំធ្វើប្រឡាយពីម្លិច គឺធ្វើទ្វារទឹកទប់ស្ទឹងស្លាគូ ត្រង់កន្លែងស្ពានស្លាគូឱ្យទឹកមកមានដល់ស្ពានម្លិចហើយធ្វើប្រឡាយហ្នឹង មួយខ្សែហ្នឹងលេខ៦៨ កាត់ខាងកើតអង្គតាសោម គឺមកបុកផ្លូវលេខ២៥ គឺពីតាកែវមកអង្គតាសោម។ បានជីកតមកត្បូងទៀត ទៅដល់ខាងកើតថ្នល់បែកឈ្យូក បឹងស្រែននោងហើយឆ្លងទៅកើតទៀត ទៅផ្លូវជាតិ អ៎! ផ្លូវរទេះភ្លើងៗ គឺជាប់ស្រុកត្រាំកក់ហើយ។

[០៩:២០:០០]

ទី៣ គឺថាធ្វើស្ថានីយបូមទឹកនៅអូរចំបក់ យកទឹកពីបឹងៗតាកែវ គឺបឹងខាងជើងទីរួមខេត្តតាកែវ

បូមតាមស្ថានីយបូមទឹកនេះ បញ្ចូលទឹកមកឃុំលាយបូរ។ ដូច្នេះភាគច្រើន ខ្ញុំធ្វើការប៉ុន្មានខ្សែហ្នឹង ហើយនិងទៅរួមប្រជុំជាមួយតាចាយ ជាមួយតាគិត ដែលជាលេខាស្រុកនៅអង្គរកា ដែលទី -- មន្ទីរស្រុកនៅអង្គរកា ផ្សារអង្គរកាបច្ចុប្បន្ននេះ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកទៅធ្វើការទីនោះ តើអ្នកដែលធ្វើការជានរណាដែរ?

**ឆ៖** អ្នកធ្វើការនៅការដ្ឋានជាកម្លាំងយុវជន យុវនារី កម្លាំងកងចល័ត។

**ស៖** តើកម្លាំងកងចល័តនោះមកពី -- ចេញមកពីណាដែរ?

**ឆ៖** កម្លាំងកងចល័តនោះ មកពីគ្រប់ឃុំ ក្នុងស្រុកត្រាំកក់ទាំងមូល។

**ស៖** តើនៅពេលនោះមានបែងចែកជាកងចល័តមូលដ្ឋាន ឬក៏កងចល័តថ្មីអីទេ?

**ឆ៖** អត់មានបែងចែកទេ នៅចម្រុះគ្នាទាំងអស់។

**ស៖** ចុះការហូបចុកនៅពេលដែលលោកទៅមកធ្វើការកន្លែងនោះ តើលោកឃើញការហូបចុកយ៉ាងម៉េចដែរ?

**ឆ៖** ការហូបចុកនៅពេលនោះ កម្លាំងនេះជាកម្លាំងកងចល័ត ហូបចុកគឺគ្រប់គ្រាន់។

**ស៖** នៅពេលដែលកងចល័តទាំងអស់នោះ នៅពេលដែលធ្វើការ តើនៅពេលដែលគេឈឺថ្កាត់ហ្នឹង តើការយកចិត្តទុកដាក់របស់អ្នកដឹកនាំទីនោះយ៉ាងម៉េចដែរ?

**ឆ៖** ពេលឈឺថ្កាត់ គឺថាមានពេទ្យៗប្រចាំនៅកន្លែងការដ្ឋានហ្នឹងព្យាបាល ហើយបើវាព្យាបាលទៅវាមិនជាទេ គេបញ្ជូនមកមន្ទីរពេទ្យស្រុកនៅវត្តត្រពាំងគល់។

**ស៖** សូមអរគុណ។ ខ្ញុំសួរសំណួរមួយទៀត ទាក់ទងនឹងការរៀបការ។ កាលពីម្សិលមិញលោកបានបញ្ជាក់អំពីការរៀបការ ហើយលោកបាននិយាយថាមានគូស្រករខ្លះ គឺការរៀបការដោយស្ម័គ្រចិត្ត ដោយគេជ្រើសរើសគូស្រករដោយខ្លួនគេ ហើយគេក៏ដាក់ឈ្មោះរៀបការ សុំរៀបការ។ ចំណែកចំណុចមួយទៀតលោកបាននិយាយថា អ្នកដឹកនាំនៅទីនោះគឺថាផ្សំផ្គុំឲ្យ។ ខ្ញុំចង់បញ្ជាក់ថាតើលោកប្រើពាក្យ “ផ្សំផ្គុំ”ហ្នឹង តើមានន័យយ៉ាងម៉េចដែរ?

[០៩:២៣:៥៦]

**ឆ៖** ផ្សំផ្គុំហ្នឹងមានន័យថា ខាងឃុំគឺគាត់យកនារីនេះ ដាក់គូជាមួយយុវជននោះ អីចឹង។ ពាក្យ “ផ្សំផ្គុំ”ហ្នឹងគឺមានន័យប៉ុណ្ណឹង។

**ស៖** ប្រសិនបើលោកថ្នាក់ដឹកនាំផ្សំផ្គុំអីចឹង។ ប្រសិនភាគី ឬក៏គូស្រករហ្នឹងមិនព្រម តើមាន

លទ្ធផលយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំៗមិនដែលបានជួបរឿងគូស្រករដែលមិនព្រមទេ តែងតែបានទទួលការយល់ព្រម ហើយរៀបចំតែម្តង។

**ស៖** សូមអរគុណ។ នៅពេលដែលលោកទៅធ្វើការទីនោះ តើនៅកងចល័តនោះមានការរៀបការទេ? មានសមាជិកនៅទុំង លោកដែលមានឃើញថ្នាក់ដឹកនាំ គេផ្តួចផ្តើមពីការរៀបការដែរឬទេ?

**ឆ៖** មានការរៀបការកងចល័តហ្នឹងហើយ ព្រោះកងចល័តសុទ្ធតែយុវជន យុវនារី។

**ស៖** នៅពេលមុនរៀបការ តើលោកមានដឹងថាតើនីតិវិធីគេ មានសួរនាំយោបល់សាមីខ្លួនមុននឹងរៀបការហ្នឹងទេ នៅពេលដែលគូណាដែលគេមិនទាន់ស្ម័គ្រចិត្តដោយខ្លួនឯងផ្ទាល់?

**ឆ៖** ខាងឃុំ ខាងប្រធានកងចល័ត មានសាកសួរយោបល់តើ មាន ហើយក៏-- យោបល់ហើយអ៊ីចឹងទៅ ក៏រៀបរយ រៀបការទៅ។

**ស៖** សូមអរគុណ។ ខ្ញុំសួរទៅប្រធានបទមួយទៀត គឺទាក់ទងទៅនឹងកិច្ចការលោកនៅក្នុងជាជំនួយការនៅក្នុងស្រុកតែម្តង។ លោកក៏បាននិយាយផងដែរថា ពេលខ្លះលោកបានប្រជុំជាមួយនឹងគណៈស្រុកនៅទីនោះ។ ខ្ញុំចង់ដឹងថា តើនៅពេលប្រជុំ គេផ្តល់គោលការណ៍អ្វីខ្លះសម្រាប់លោកទៅជួយធ្វើការនៅតាមសហករណ៍មួយៗ?

[០៩:២៧:០៣]

**ឆ៖** លំបាកឆ្លើយដែរបញ្ហាហ្នឹង គឺការប្រជុំនេះជាការប្រជុំពិនិត្យកិច្ចការដែលកន្លងទៅ ហើយលើកផែនការតទៅមុខទៀត ដូចថាធ្វើប្រឡាយ ធ្វើភ្លឺ ធ្វើស្រែ ធ្វើពីណាទៅណាអ៊ីចឹង គឺមានលើកផែនការប៉ុណ្ណឹង។ ឯគោលការណ៍អីដែរធំៗ ដូចជាមិនសូវមានបានរៀបចំគោលការណ៍ធំៗទេ។ ចំពោះខ្ញុំទាក់ទិនបញ្ហាប៉ុណ្ណឹង។

**ស៖** លោកក៏បាននិយាយផងដែរនៅកិច្ចការ នៅក្នុងថ្នាក់ស្រុក គឺមានកិច្ចការបី គឺកិច្ចការមួយគឺកិច្ចការនយោបាយ កិច្ចការសេដ្ឋកិច្ច និងសន្តិសុខ។ តើនៅពេលដែលលោកជំនួយការហ្នឹង តើគេមានចាត់តាំងឲ្យលោកធ្វើកិច្ចការណាមួយជាក់លាក់ទេ ឬក៏លោកត្រូវជួយកិច្ចការទាំងអស់?

**ឆ៖** ខ្ញុំអត់បាននិយាយថា កិច្ចការនយោបាយ កិច្ចការសេដ្ឋកិច្ច កិច្ចការសន្តិសុខអីទេ ដែលថាខ្ញុំត្រូវបំពេញនោះ ក៏ប៉ុន្តែត្រូវគេចាត់ចែងឲ្យខ្ញុំទៅធ្វើអី គឺខ្ញុំត្រូវគោរពបទបញ្ជាត្រូវធ្វើហ្នឹង។

**ស៖** សូមអរគុណ។ នៅពេលដែលលោកប្រជុំនៅស្រុកត្រាំកក់នោះ តើលោកមានបានដែលឮថ្នាក់ដឹកនាំស្រុកហ្នឹងកំណត់ថា នៅពេលដែលលោកចុះទៅមើលមូលដ្ឋាន ត្រូវតែកម្ទេចអាណិកជនចាមដែរឬទេ?

**ឆ៖** ខ្ញុំដែលឮទេ។

**ស៖** តើលោកមានដែលបានឮឃុំផ្សេងៗទៀតនិយាយអំពីបញ្ហាហ្នឹងទេ?

**ឆ៖** អត់ទេ។

**ស៖** ចុះចំពោះជនជាតិវៀតណាមវិញ តើលោកមានដែលបានគេពិភាក្សាថា ឲ្យតែជនជាតិវៀតណាមនៅក្នុងមូលដ្ឋានហ្នឹងត្រូវកម្ទេច ឬក៏ត្រូវយកចិត្តទុករបៀបណាទេ?

**ឆ៖** អត់ៗមាន អត់មានបែងចែកអ៊ីចឹងទេ។

[០៩:៣០:១០]

**ស៖** តើនៅក្នុងសហគមន៍ដែលលោកទៅធ្វើការនៅស្រុកត្រាំកក់ មានដែលជួបប្រទះខ្មែរកម្ពុជាក្រោមធ្វើការនៅទីនោះទេ?

**ឆ៖** អត់មាន ខ្ញុំអត់ដឹងកម្ពុជាក្រោមទេ អត់ដឹងជនជាតិកម្ពុជាក្រោមនៅស្រុកត្រាំកក់ទេ អត់ដឹង។

**ស៖** ចុះនៅក្នុងកម្រិតពេលប្រជុំ តើមានបានដែលធ្លាប់ឮការណែនាំថាត្រូវ ខ្មែរកម្ពុជាក្រោមត្រូវបញ្ជូនទៅស្រុកវិញ ឬក៏ត្រូវកម្ទេចចោល ឬក៏ត្រូវឲ្យធ្វើការរបៀបណាទេ?

**ឆ៖** អត់មានដែលឮវិធានការចំពោះខ្មែរក្រោមដូចលោកចោទសួរនេះទេ អត់ទេ។

**លោក សួន វិសាល៖**

សូមអរគុណលោកសាក្សី ខ្ញុំអស់សំណួរប៉ុណ្ណឹងហើយ។ សូមអរគុណនិងផ្តល់ -- លោកចៅក្រមសូមផ្តល់តួនាទីទៅសហការីរបស់ខ្ញុំបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[០៩:៣១:២៦]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

ជម្រាបសួរលោកសាក្សី។ ខ្ញុំសូមចាប់ផ្ដើម សូមសួរលោកសំណួរមួយចំនួន អំពីពាក្យពេចន៍ខ្មែរដែលយើងបានពិភាក្សាគ្នាកាលពីម្សិលមិញ គឺអំនានពាក្យខ្មែរ គឺពាក្យថា "បោសសម្អាត" ដែលភាសាអង់គ្លេស គេថា "*ស្វីបភីង ឃ្លីន*" – បោសសម្អាត។ លោកនិយាយពាក្យនេះ នៅពេលដែលលោកឆ្លើយតបនឹងសំណួររបស់លោកចៅក្រម ឡាវែន៍ ហើយតាមរយៈការពិភាក្សាលើពាក្យនេះ ពាក្យពេចន៍នេះ ខ្ញុំសូមឲ្យលោកមើលចម្លើយរបស់លោកដែលបង្ហាញជូនលោកជាច្រើនដងដែរកាលពីម្សិលមិញ។ គឺឯកសារ E319.1 -- បាទ .12.2។ សំណួរដែលអ្នកស៊ើបអង្កេតសួរទៅកាន់សាក្សីរូបនេះ គឺដូចមានដូចតទៅ ខ្ញុំសូមដកស្រង់៖ "ពេលដែលលោកនិយាយពាក្យថា បោសសម្អាត តើលោកមានន័យថាចាប់ខ្លួនឬ?" ហើយនៅក្នុងចម្លើយ៣១១៖ "ខ្ញុំសូមឲ្យលោកឆ្លើយតប ឬក៏មានប្រតិកម្មទៅនឹងចម្លើយរបស់សាក្សីរូបនេះ ដែលនិយាយថា បោសសម្អាត មានន័យថា ចាប់ខ្លួន"។ E319/12.3.2 គឺជាចម្លើយរបស់សាក្សីដែលយើងបានលើកយកមកពិភាក្សាកាលពីម្សិលមិញ។

ខ្ញុំស្នើសុំឲ្យមេធាវីប្រឹក្សាជួយបង្ហាញទៅគាត់ផង គឺឯកសារ E319/12.3.2 ។

ហេតុផលដែលខ្ញុំ ដែលសួរនេះ គឺថាខ្ញុំនឹងសួរសំណួរច្រើនទៀតទៅលើឯកសារនេះ។

លោកប្រធាន ខ្ញុំស្នើសុំឲ្យមន្ត្រីតុលាការផ្ដល់ឯកសារនេះមួយច្បាប់ជូនទៅសាក្សី។ ប៉ុន្តែ ខ្ញុំគិតឃើញថា គាត់បានទទួលឯកសារនេះហើយកាលពីម្សិលមិញ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[០៩:៣៦:១៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សម្រាប់មេធាវីប្រចាំការ គឺសំណួរ៣១១ នៅ បាទគឺចម្លើយ -- សំណួរ៣១១។ បើសិនជាខ្ញុំសួរម្ដងទៀត លោកសាក្សី គឺសំណួរ-ចម្លើយលេខ៣១១ គឺសំណួរសួរទៅ៖ "នៅពេលលោកស្រីនិយាយអំពីពាក្យ "បោសសម្អាត" គឺលោកស្រីសំដៅទៅលើការចាប់ខ្លួន។ តើត្រឹមត្រូវដែរឬទេ? ឆ្លើយ៖ ចាស"។ សំណួររបស់ខ្ញុំទៅលោកសាក្សី តើលោកមានប្រតិកម្មយ៉ាងដូចម្ដេច ឬក៏លោកវាមានៗយោបល់យ៉ាងម៉េចដែរ ចំពោះចម្លើយរបស់សាក្សីនេះ?

**លោក នាង អ៊ួច៖**

**ឆ៖** ពាក្យ "បោសសម្អាត" នេះ លោកព្រះរាជអាជ្ញាខាងនេះបានសួរខ្ញុំម្ដងរួចហើយពីម្សិល

មួយថ្ងៃ ពេលល្ងាច។ ហើយបានសុំប្រឹក្សាយោបល់ ខ្ញុំសុំប្រឹក្សាយោបល់ជាមួយមេធាវី។ ស្អែកឡើងពីម្សិលមិញនេះ បានខ្ញុំឆ្លើយ។ ដូច្នេះ ខ្ញុំបានឆ្លើយរួចហើយជាមួយលោកប្រធាន -- ព្រះរាជអាជ្ញានោះ។

[០៩:៣៧:៥៧]

**ស៖** ខ្ញុំដឹងថាលោកបានឆ្លើយ ប៉ុន្តែឥឡូវនេះ ខ្ញុំកំពុងសួរតទល់ជាមួយលោក។ ដោយសារថា ខ្ញុំអាចយល់ឃើញថា វាអាចនឹងមានការបកស្រាយទៅលើពាក្យនេះមានន័យខុសគ្នាជាភាសាខ្មែរ។ ហេតុដូច្នេះឯងទើបខ្ញុំឱ្យលោកឆ្លើយមើល លោកមានប្រតិកម្មយ៉ាងម៉េចដែរចំពោះចម្លើយរបស់សាក្សីរូបនេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបនឹងសំណួរនេះ ពីព្រោះមានការឆ្លើយខុសគ្នារវាងចម្លើយរបស់លោកជាមួយនឹងចម្លើយរបស់សាក្សីដែលលោកមេធាវីបង្ហាញនេះ។ តើលោកគិតថាយ៉ាងម៉េចអំពីចម្លើយនេះ? ចម្លើយរបស់សាក្សីដែលគាត់អានអម្បាញ់មិញនេះ ធៀបនឹងជាមួយចម្លើយរបស់លោក ដែលបានឆ្លើយចំពោះសហព្រះរាជអាជ្ញាកាលពីម្សិលមិញ។

**លោក នាង អ៊ួច៖**

**ឆ៖** ន័យៗ "បោសសម្អាត"សម្រាប់ខ្លួនខ្ញុំប្រើ គឺថាសម្លាប់ – សម្លាប់ចោល។ ដូច្នេះ វាខុសពីន័យនេះ គឺន័យនេះមានត្រឹមតែចាប់ខ្លួន។

**លោក វ៉ិចទ័រ កូប៉េ៖**

យើងខ្ញុំនឹងសួរទៅលើពាក្យនេះបន្តទៅទៀត ខ្ញុំបន្តសំណួររបស់ខ្ញុំ។ សំណួររបស់ខ្ញុំទាក់ទងទៅនឹងឯកសារ E3/493 បាទគឺឯកសារ E319.1. -- បាទឯកសារ E3/4093។ ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារនេះជូនសាក្សីផងដែរ លោកប្រធាន។

[០៩:៤០:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ប៉ុន្តែ ជម្រាបថាយើងអត់មានប្រព័ន្ធនៃការដាក់បង្ហាញឯកសារនៅលើអេក្រង់ទេ ពីព្រោះបច្ចេកទេសនោះវាខូច។ អ៊ីចឹងគឺសូមដាក់បង្ហាញឯកសារជាក្រដាសជូនសាក្សីដើម្បីធ្វើការពិភាក្សាដេញដោលនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី សៀវភៅការកត់សម្គាល់តូចមួយនូវអ្វីដែលលោក -- កាលពីម្សិលមិញនេះ

គឺការសរសេរ អក្សរសរសេរដោយដៃ គឺមានសរសេរទៅលើឯកសារផ្សេង ដែលមាននៅក្នុងឯកសារ E3/4093។ ស្ត្រីមេម៉ាយដែលលោកនិយាយនៅក្នុងកំណត់ត្រារបស់លោកនេះ គឺជាស្ត្រីមេម៉ាយដែលយើងត្រូវនិយាយនៅទំព័របន្ទាប់នេះ។ សំណួររបស់ខ្ញុំគឺមានដូចតទៅនេះ។ តើលោកដឹងថាមានអ្វីពិតជាបានកើតឡើងចំពោះស្ត្រីមេម៉ាយទាំងប្រាំនាក់ ឈ្មោះមួយ, ឈ្មោះ ប៊ិន សុគន្ធ, ឈ្មោះគៀត ហើយនិងម៉ោន។

[០៩:៤៣:២០]

**លោក នាង អ៊ួច៖**

**ឆ៖** ស្ត្រីមេម៉ាយទាំងប្រាំនាក់នេះមានសេចក្ដីរាយការណ៍ជាក្រដាសជូនជាប់មកហើយ។ ដូច្នេះខ្ញុំយកសេចក្ដីរាយការណ៍នេះទៅឆ្លងជាមួយនឹង តារ៉ន, តាប៊ិត ហើយក៏គាត់សម្រេចឲ្យខ្ញុំសរសេរតាមដែល ដូចដែលចំណារដែលខ្ញុំបានទទួលការណែនាំ ការសម្រេចពី តារ៉ន ហើយខ្ញុំសរសេរនៅទំព័រ E3 4093 ចុះថ្ងៃ៧ ខែ៨ នេះ។ ការសរសេរទាំងអស់នេះ គឺខ្ញុំសរសេរតាមការសម្រេច តាមការជូនរាយ-ការណ៍នេះទៅ តារ៉ន។ ហើយគាត់សម្រេច គឺខ្ញុំធ្វើតាមការសម្រេចរបស់ថ្នាក់លើ គឺតារ៉ន។

**ស៖** ខ្ញុំយល់ហើយ គឺថាយើងបានឆ្លើយពីម្សិលមិញហើយ។ ប៉ុន្តែសំណួររបស់ខ្ញុំ ថាតើលោកដឹងថាមានអ្វីកើតឡើងចំពោះជោគវាសនាស្ត្រីមេម៉ាយទាំងនេះ? តើលោកមានបានឃើញដោយផ្ទាល់ភ្នែក មានឃើញការសម្លាប់ស្ត្រីមេម៉ាយទាំងប្រាំនាក់នេះដោយផ្ទាល់ភ្នែកទេ?

**ឆ៖** ខ្ញុំអត់បានឃើញដោយផ្ទាល់ភ្នែកទេ។

**ស៖** នេះមិនមែនជាសំណួររបស់ខ្ញុំទាក់ទងទៅនឹងឯកសារ E3/4093 នោះទេ។ គឺចុះថ្ងៃទី០៧ ខែសីហា គឺថារបាយការណ៍ដែលលើកឡើងមកនេះ គឺថាលោកថាលោកចុះកាលបរិច្ឆេទថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៧៨ ។ សំណួររបស់ខ្ញុំ តើលោកមានចាំអ្វីអំពីរបាយការណ៍នេះ ឬក៏លោកអាចពន្យល់ជូនអង្គជំនុំជម្រះថា វាអាចទេដែលថាលោកបញ្ជូនឯកសារនេះ១ថ្ងៃមុន?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ សហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម ខ្ញុំយល់ឃើញថា នេះមិនមែនជាចម្លើយមួយដែលត្រឹមទំព័រចំពោះឯកសារ E3/4093 នេះ ទាក់ទងទៅនឹងរបាយការណ៍ថា ឯកសារនេះចុះកាលបរិច្ឆេទថ្ងៃទី៧

ខែសីហា មិនមានឃើញចុះកាលបរិច្ឆេទ០៧ ខែសីហា នេះទេ។ ប៉ុន្តែទំព័របន្ទាប់នេះ គឺចុះថ្ងៃទី៨ ខែសីហា ខ្ញុំសូមបញ្ជាក់អំពីរបាយការណ៍នេះ គឺឯកសារពី ម៉េង ចុះថ្ងៃទី៨ ខែសីហា គឺបញ្ជាក់អំពីរបាយ-ការណ៍មុន។

**លោក វ៉ិចទ័រ កូប៉េ៖**

យើងចង់ដឹងអំពីខ្លឹម -- សហព្រះរាជអាជ្ញាចង់ដឹងខ្លឹមសារនៃឯកសារ -- របាយការណ៍ទាំងពីរ។ អ៊ីចឹង ខ្ញុំចង់ឲ្យសាក្សីពន្យល់មើល ថាតើកាលបរិច្ឆេទនៅលើឯកសារពីរខុសគ្នានេះ វាយ៉ាងម៉េច? ដូច្នេះ ខ្ញុំមានសិទ្ធិសួរទៅសាក្សីបែបនេះបាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជាថ្មីម្តងទៀត លោកសាក្សី តើលោកចាំទេ? ខ្ញុំសូមរៀបសំណួរឡើងវិញ តើលោកដឹងថា វាអាចទេ ថាឯកសារដែលថាលោកបានបញ្ជូននេះ គឺចុះកាលបរិច្ឆេទ១ថ្ងៃក្រោយមក ខុសពីកំណត់ត្រារបស់លោកនោះ?

[០៩:៤៨:៥០]

**លោក នាង អ៊ូច៖**

**ឆ៖** ឯកសារចុះថ្ងៃ៧ ខែ៨ និងឯកសារចុះថ្ងៃទី៨ ខែ៨ ជាឯកសារខុសគ្នា។

**ស៖** សូមលោកពន្យល់ឲ្យបានទូលំទូលាយបន្តិចថា លោកដឹងវាខុសគ្នាយ៉ាងម៉េច?

**ឆ៖** វាខុសគ្នាត្រង់ឯកសារចុះថ្ងៃ៨ ខែ៨ -- ចុះថ្ងៃ៧ ខែ៨ ជាហត្ថលេខារបស់ខ្ញុំ។ ខ្ញុំសរសេរពិតប្រាកដ។ ឯឯកសារចុះថ្ងៃ៨ ខែ៨នេះ គឺឈ្មោះ ម៉េង ជាអ្នកសរសេរ។ ដូច្នេះ ខ្ញុំចាំមិនបានទេ ឯកសារទាំងពីរនេះ។ តែឯកសារទី១ ចុះថ្ងៃ៧ ខែ៨ នេះ គឺពិតជាអក្សរខ្ញុំ និងហត្ថលេខារបស់ខ្ញុំពិត។

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ទៅទៀត លោកនិយាយថា ការកត់ត្រារបស់លោកមិនសំដៅទៅលើរបាយការណ៍ចុះថ្ងៃទី៨ ខែសីហា ១៩៧៨ ដែលធ្វើឡើងដោយ ម៉េង នោះទេ។ តើត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំឆ្លើយមិនបានទេ ព្រោះអានេះឈ្មោះគេ។

**ស៖** លោកសាក្សី លោកមានការនឹកឃើញឡើងវិញ អំពីការអនុវត្តជាក់ស្តែងណាមួយរបស់លោកនៅពេលពាក់ព័ន្ធទៅនឹងរបាយការណ៍ដែលគេផ្ញើជូនមកលោក។ តើលោកមានការចងចាំទៅលើ

E1/275.1

កូនក្រដាសតូចមួយដែលលោកបានសរសេរកត់ត្រាចំពោះនេះ ឯកសារដែលមានលើកឡើងមកនិយាយគ្នានេះទេ?

**ឆ៖** កូនក្រដាសតូចដែលចុះថ្ងៃទី៧ ខែ៨នេះ គឺការពិតជាការដែលខ្ញុំសរសេរ ហើយខ្ញុំយកទៅឆ្លង យកទៅរាយការណ៍ជូន តារ៉ន។ តារ៉ន សម្រេចយ៉ាងអីចឹង បានជាខ្ញុំសរសេរអីចឹង។ អានេះគឺការពិតរបស់ខ្ញុំ និងអាកូនៗក្រដាសតូចនេះ សរសេរបួនបន្ទាត់ហ្នឹង។

[០៩:៥២:៥៩]

**ស៖** ប្រហែលជាខ្ញុំបាត់ផ្នែកណាមួយពីម្សិល ឬថ្ងៃនេះ។ គឺកំណត់ត្រានេះ គឺជាកំណត់ត្រារបស់ ជុន។ តើ ជុន នេះជាមនុស្សតែម្នាក់ឈ្មោះ រ៉ន ហ្នឹងដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំរកមិនឃើញឈ្មោះ ជុន ឈ្មោះ រ៉ន ហ្នឹង។

**ស៖** សូមទោសលោក ខ្ញុំមិនចេះនិយាយភាសាខ្មែរទេ។ ខ្ញុំអានការបកប្រែជាអង់គ្លេស ការបកប្រែជាភាសាអង់គ្លេសចេញពីកំណត់ត្រារបស់លោក គឺចាប់ផ្ដើមជាមួយ "សមមិត្តជុន ជាទីស្រឡាញ់"។ តើលោកមានឃើញនៅលើកំណត់ត្រារបស់លោកនុ៎ងដូចគ្នាដែរទេ?

**ឆ៖** អត់មាន សមមិត្តជុន ហ្នឹងអត់មាន។

**ស៖** បាទ សូមកែតម្រូវ គឺ "សមមិត្ត បងឈឿន ជាទីស្នេហា"។

**ឆ៖** នេះ ខ្ញុំឃើញហើយ ឈឿន បាទ សមមិត្ត ឈឿន។

**ស៖** ជៀសវាងកុំឲ្យមានការយល់ច្រឡំ សួរថាតើ ឈឿន នេះជាអ្នកណា?

**ឆ៖** ឈឿន នេះមានតួនាទីជាប្រធានមន្ទីរស្រុកត្រាំកក់។

**ស៖** សូមលោកពន្យល់បន្តិចមើល៍ ថាតើលោកស្នើសុំយ៉ាងម៉េចនេះ ជាមួយមនុស្សម្នាក់ដែលមានកម្រិតឋានៈប្រហាក់ប្រហែលលោកហ្នឹង ដើម្បីឲ្យដោះស្រាយមនុស្សដែលៗគេចោទថាមានបញ្ហានេះ?

[០៩:៥៦:១៩]

**ឆ៖** ខ្ញុំយករឿងរ៉ាវហ្នឹងទៅឆ្លងជាមួយបងរ៉ន ហើយ បងរ៉ន សម្រេចណែនាំឲ្យសរសេរអីចឹង។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី ក៏ប៉ុន្តែនៅក្នុងការបកប្រែជាភាសាអង់គ្លេសនេះគឺថា លោកនេះហាក់បីជាលោកនេះស្នើសុំជាជាងការណែនាំទៅវិញ។ កន្លែងនេះគឺលោក -- ឃ្លាទី១ គឺសរសេរថា "ទាក់ទងទៅនឹងអ្នកទោសពី មកពីឃុំជាងទង ស្នើសុំឲ្យយកកូនណាមួយ"។ តើលោកពន្យល់បានទេនូវ

ឃ្លានេះ គឺមើលទៅវាហាក់បីដូចជាការលោកស្នើសុំ មិនមែនណែនាំនោះទេ។

**ឆ៖** មិនមែនខ្ញុំស្នើសុំទេឃ្លាហ្នឹង។ មានន័យនែ៎ ការសរសេរនេះគឺតាមៗការណែនាំរបស់បងរ៉ន–លោកតារ៉ន។

**ស៖** ដូច្នេះខ្ញុំអាចអានឯកសារថា មិនមែនជាសំណើសុំទៅសមមិត្ត ឈឿន ទេ គឺជាការណែនាំ។ តើត្រឹមត្រូវទេ?

**ឆ៖** ការសម្រេចរបស់ តារ៉ន គឺខ្ញុំសរសេរអ៊ីចឹងមិនមែនជាការស្នើសុំទេ គឺការបញ្ជាឲ្យសមមិត្ត ឈឿន អ៊ីចឹង គឺការសរសេរទៅបងឈឿន ឲ្យធ្វើតាមការសម្រេចរបស់ តារ៉ន អ៊ីចឹង។

**ស៖** ខ្ញុំនៅតែមិនច្បាស់ថា ហេតុអ្វីបានជាលោកស្នើសុំ ឬក៏ណែនាំ ឈឿន ឲ្យបោសសម្អាតស្ត្រីមេម៉ាយ ឬកូនៗទាំងនេះ?

[០៩:៥៩:២៨]

**ឆ៖** ខ្ញុំមិនអាចពន្យល់លោកយ៉ាងម៉េចបានតទៅទៀត ក្រៅពីការបកស្រាយកន្លងមកនេះទេ។ ព្រោះខ្ញុំនិយាយដដែលៗ គឺថាមានៗការស្នើរបស់ខ្ញុំជូន តារ៉ន។ មានការរាយការណ៍របស់ខ្ញុំជូន តារ៉នៗ សម្រេចយ៉ាងម៉េចគឺខ្ញុំសរសេរតាមបញ្ជារបស់ តារ៉ន ហើយបើខ្ញុំមិនសរសេរតាមបញ្ជារបស់ តារ៉ន ទេ ខ្ញុំក៏មានគ្រោះថ្នាក់ដូចបងប្រុសបង្កើតរបស់ខ្ញុំដែរ។ ដូចថា ទោះបីជាខ្ញុំជាប់សាច់ញាតិជាមួយ តាម៉ុក ជាប្អូនថ្លៃ តាម៉ុក យ៉ាងក៏ដោយ ប៉ុន្តែបើខ្ញុំមិនធ្វើតាមបទបញ្ជាទេ គ្រោះថ្នាក់វាធ្លាក់ដល់ខ្លួនខ្ញុំដដែល។

**ស៖** លោកសាក្សី កាលពីម្សិលមិញ យើងបានបង្ហាញឯកសារជូនលោក ក្នុងពេលដែលលោកឆ្លើយទៅនឹងសំណួររបស់ចៅក្រម ឡាវែន៍ ហើយនិងបានបញ្ជាក់ថា កំណត់ត្រានេះ គឺមានហត្ថលេខារបស់លោក ហើយជាសំណេរដោយផ្ទាល់ដៃរបស់លោក។ ហើយលោកក៏បង្ហាញផងដែរ អំពីឯកសារមួយចំនួន ដែលឯកសារនោះមានឈ្មោះលោកនៅលើ ប៉ុន្តែលោកបាននិយាយថា "ឈ្មោះ ឬក៏ហត្ថលេខាហ្នឹង មិនមែនជារបស់លោកទេ"។ អ៊ីចឹងដែលមិនបាច់ពិនិត្យមើលម្តងទៀតហ្នឹង តើលោកអាចប្រាប់បានទេ ថាហេតុអ្វីបានជាឯកសារដែលលោកមាននៅខាងមុខលោកហ្នឹង ថាតើវាជាឯកសារដែលមានសរសេរដៃដោយលោក ហើយមានឈ្មោះលោក ហេតុអ្វីក៏ជាឯកសារប្រាំ-ប្រាំមួយផ្សេងទៀត មិនមែនជាឯកសារដែលសរសេរដោយផ្ទាល់ដៃរបស់លោក ហើយមិនមែនជាឈ្មោះរបស់លោកនោះ។ តើលោកអាចពន្យល់បានទេ?

[១០:០២:០២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី លោកអាចនិយាយឲ្យបានច្បាស់ទេ ព្រោះថាអ្វីដែលលោកបាននិយាយជាភាសាអង់គ្លេសហ្នឹង វាមិនច្បាស់លាស់ទេ។ លោកនិយាយថា ឯកសារជាភាសាដៃបែបណានោះ ខ្ញុំអត់យល់។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអាចបង្ហាញឯកសារជូនគាត់ពិនិត្យមើលបាន ព្រោះថាឯកសារហ្នឹង គឺថាមិន--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកចង់សួរថាម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺឯកសារហ្នឹង គឺជាឯកសារដែលបង្ហាញថាមិនមែនជាហត្ថលេខារបស់គាត់ និងមិនមែនជាសរសេរដៃរបស់គាត់ ប៉ុន្តែមានឈ្មោះគាត់។ ដូច្នេះ ខ្ញុំចង់ដឹងថា តើគាត់សម្រេចបែបណា ថាអាណាជាឯកសារគាត់សរសេរដៃ អាណាមិនសរសេរដៃ ណាមានឈ្មោះគាត់ មិនមានឈ្មោះគាត់អ៊ីចឹង។ ខ្ញុំចង់ដឹងបែបនេះ។

[១០:០២:៥១]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះខ្ញុំសួរមួយសាទៀតដើម្បីឲ្យច្បាស់លាស់។ ម្សិលមិញលោកនិយាយថាគឺមានឯកសារជាច្រើន ដែលយើងបង្ហាញជូនលោក គឺមិនមែនជាឯកសារដែលសរសេរដោយផ្ទាល់ដៃរបស់លោក និងមិនមែនជាឯកសារដែលមានហត្ថលេខារបស់លោក។ ដូច្នេះ ខ្ញុំចង់ដឹងថា ឯកសារ -- ថាហេតុអ្វីបានជាឯកសារ E3/4093ហ្នឹង លោកបញ្ជាក់អះអាងថាជាឯកសារដែលសរសេរដោយផ្ទាល់ដៃរបស់លោកទៅវិញ?

**លោក នាង អ៊ួច៖**

**ឆ៖** ពីព្រោះខ្ញុំស្គាល់អក្សរច្បាស់លាស់។ ទី១ ឯកសារ E3/2785 ចុះថ្ងៃទី៧ ខែ៣ ដាក់ឈ្មោះខាងក្រោម សាន។ ឯកសារនេះ មិនមែនខ្ញុំសរសេរទេ ហើយក៏មិនមែនខ្ញុំចុះហត្ថលេខាដែរ។

**ស៖** នេះគឺជាអ្វីដែលខ្ញុំយល់ពីសក្ខីកម្មរបស់លោក កាលពីម្សិលមិញ លោកសាក្សី។ ប៉ុន្តែវាមានឯកសារប្រាំមួយផ្សេងទៀត ដែលជារបាយការណ៍របស់ស្រុកត្រាំកក់ ហើយមានឈ្មោះរបស់លោក និងឯកសារខ្លះមានហត្ថលេខា ឯខ្លះគ្មាន ប៉ុន្តែលោកបានបញ្ជាក់ថា ឯកសារទាំងមិនមែនជាឯកសារសរសេរ

ដៃដោយលោក និងមិនចុះហត្ថលេខាដោយលោកនោះឡើយ។ ដូច្នេះ ខ្ញុំចង់សួរលោកថា ហេតុអ្វីបានជាលោកប្រាកដថាឯកសារ E3/4093 នេះគឺប្រាកដជាឯកសារដែលលោកសរសេរដៃ ចំណែកឯកសារដទៃទៀត គឺឯកសាររបស់អ្នកដទៃ ដូចជា សាន ឬក៏របស់អ្នកណាអ៊ីចឹង។ ហេតុអ្វីបានជាលោកដឹងច្បាស់ដូច្នេះ?

[១០:០៤:៥៩]

**ឆ៖** ខ្ញុំដឹងច្បាស់ ព្រោះខ្ញុំស្គាល់ ខ្ញុំនៅចាំថាអក្សរខ្ញុំ។

**ស៖** មិនអីទេលោកសាក្សី ប៉ុន្តែខ្ញុំចង់ដឹងបន្តទៀតថា តើអ្នកណាជា សាន ដែលចុះហត្ថលេខាទៅលើឯកសារប្រាំមួយប្រាំពីរផ្សេងទៀតនោះ គឺខ្ញុំចង់ដឹងថាឈ្មោះ សាន ហ្នឹងជាអ្នកណា?

**ឆ៖** ខ្ញុំអត់ដឹង ព្រោះមិនមែនអក្សរខ្ញុំ។

**ស៖** មិនអីទេលោកសាក្សី។ ឥឡូវនេះ ខ្ញុំនឹងលើកយកឯកសារដដែលគឺ ឯកសារ E3/4093 ហើយជាពិសេស គឺនៅត្រង់ប្រយោគមួយដែលខ្ញុំសុំអាន៖ "ប៉ុន្តែប្រសិនបើក្មេងៗមិនអាចបំបែកពីម្តាយគេយកក្មេងហ្នឹងទៅសួរចម្លើយ ហើយនៅពេលដែលដឹងរឿងរ៉ាវអស់ហើយ យើងបោសសម្អាតទាំងអស់ចុះ"។ ខ្ញុំចង់ដឹងថាចុះពាក្យ ថាតើ"បើ"។ ពាក្យដែលលោកសរសេរថា "ប៉ុន្តែបើកូននេះមិនដាច់ពីម្តាយទេ" តើពាក្យ "បើ" ហ្នឹង "ប៉ុន្តែបើ" ហ្នឹង ចង់មានន័យថាយ៉ាងម៉េច?

**ឆ៖** ខ្ញុំពិបាកពន្យល់ពាក្យថា"បើ"ហ្នឹង។ ចង់និយាយថា "បើកូនបេះមិនដាច់ចេញពីម្តាយទេ គឺយកមកចុះ គឺយកទាំងអស់ហ្នឹងណា៎ យកទាំងកូនទាំងម្តាយ អស់រឿងរ៉ាវហើយ បោសសម្អាតទាំងអស់ចុះ។ នេះជាការសម្រេចរបស់ តារ៉ន គាត់ឲ្យសរសេរអ៊ីចឹង។

[១០:០៧:៤៨]

**ស៖** ខ្ញុំយល់អំពីចម្លើយរបស់លោក ហើយលោកធ្លាប់ជាគ្រូបង្រៀន ហើយលោកបង្រៀនអស់រយៈពេលយូរឆ្នាំណាស់មកហើយ។ ខ្ញុំគិតថាចំពោះភាសាខ្មែរមិនដឹងយ៉ាងម៉េចទេ ប៉ុន្តែចំពោះភាសាអង់គ្លេស គេប្រើពាក្យមួយ"ប្រសិនបើ" ដូច្នេះប្រសិនបើបានន័យថា វានឹងកើតឡើង។ ដូច្នេះ ខ្ញុំចង់ដឹងថាតើលោកដឹងទេថាក្មេងៗទាំងអស់នោះ គឺក្មេងៗដែលមិនអាចបំបែកបានហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** ក្មេងៗដែលបំបែកមិនបានហ្នឹង គឺវានៅជាប់ជាមួយនឹងម្តាយ។

**ស៖** ប៉ុន្តែខ្ញុំចង់សួរលោកថា តើលោកដឹងថាក្មេងៗទាំងអស់ហ្នឹងវាមាន -- តើក្មេងៗទាំងអស់រកឃើញនៅណា?

**ធ៖** សុំម្តងទៀត។

**ស៖** ខ្ញុំគិតថាមានបញ្ហានៃការប្រើប្រាស់វេយ្យាករណ៍ខ្មែរ និងភាសាអង់គ្លេសខុសគ្នាមើលទៅ។ ប៉ុន្តែ ខ្ញុំចង់និយាយអំពីកំណត់ត្រារបស់លោក គឺថាកំណត់ត្រារបស់លោកដាក់ថា "ប៉ុន្តែបើ"។ ដូច្នេះ ខ្ញុំចង់សួរថា តើលោកដឹងទេថាក្នុងកាលៈទេសៈជាក់ស្តែងបែបនេះ ថាតើក្មេងៗហ្នឹងគេរកឃើញនៅកន្លែងណា?

**ធ៖** ខ្ញុំៗមិនយល់សំណួរនេះ ប៉ុន្តែក្មេងៗ ម៉ែហើយនិងកូននៅជាប់គ្នា។ ធម្មតាអ៊ីចឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអាចយល់បាន។ លោកប្រធាន ខ្ញុំមើលទៅឃើញថាដូចជា ប្រហែលជាមានបញ្ហាបកប្រែទៅលើភាសារបស់ខ្ញុំ។ ខ្ញុំចង់និយាយអំពីពាក្យជាភាសាអង់គ្លេសថា "*អ៊ីហ្វ*"។ គឺមានន័យថា "ប្រសិនបើ"។ ដូច្នេះ គឺនិយាយថាវាមានអាចករណីពីរ គឺករណីប្រសិនបើកើតឡើង ឬមិនកើតឡើង។ ដូច្នេះប្រហែលជាលោកប្រធានអាចថា សួរសាក្សីមើល៍ ថាតើកូនហ្នឹង ថាតើវាអាចមានករណីកើតឡើងចំពោះក្មេងហ្នឹងដែរឬទេ? ចង់និយាយថា តើក្មេងដែលបេះមិនដាច់ហ្នឹងម៉េចដែរ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំចង់សួរថា តើលោកចង់សួរថាមានករណីដែលក្មេងបែបនេះកើតដែរឬទេ?

[១០:១១:១៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនមែនចង់សួរបែបនេះទេ។ ខ្ញុំចង់ដឹងអំពីករណីពិសេសមួយ។ ប្រសិនបើ -- ខ្ញុំចង់ដឹងថាតើវាអាចមានករណីដែលក្មេងហ្នឹងត្រូវបានគេសម្លាប់ដែរឬទេ? ដូច្នេះ ខ្ញុំចង់សួរថាតើវាអាចមានករណីដែលថាក្មេងហ្នឹងគឺមិនត្រូវបានគេផ្តាច់ពីម្តាយ ហើយត្រូវបានគេសម្រេចសម្លាប់។ ដូច្នេះ ខ្ញុំចង់ដឹងថាតើវាមានករណីដែលថាក្មេងបេះមិនដាច់ហ្នឹង ហើយគេយកទៅសម្លាប់ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយ ទំនងឆ្លើយបានហើយ វាច្បាស់លាស់ហើយ។

នៅក្នុងចំណារនេះមានលក្ខខណ្ឌ ថាឲ្យបំបែកក្មេងចេញពីម្តាយ ហើយបើសិនជាបំបែកមិនដាច់ចេញពីម្តាយទេគឺ "ឲ្យយកទៅសម្អាតទាំងអស់ចុះ"។ ពាក្យខ្មែរ គឺមានន័យគ្រប់គ្រាន់ហើយ គឺលក្ខខណ្ឌគឺឲ្យបំបែកកូនហ្នឹងចេញពីម្តាយ តែបើបំបែកចេញវាមិនបានទេ ឲ្យយកទៅសួររឿងរ៉ាវអស់ហើយ

"បោសសម្អាតទាំងអស់ចុះ"។ តើផលវិបាកវាប៉ះពាល់ទៅលើកូនហ្នឹងយ៉ាងដូចម្ដេចបើសិនជាតាមចំណារបែបនេះ ហើយក្នុងការអនុវត្តជាក់ស្ដែងនោះវាយ៉ាងម៉េច?

**លោក នាង អ៊ួច៖**

**ឆ៖** បន្ទាប់ពី តារ៉ន សម្រេចអ៊ីចឹងហើយ ខ្ញុំសរសេរតាមគាត់ ហើយជាលទ្ធផល ៗចុងក្រោយយ៉ាងណា ខ្ញុំអត់បានដឹងទេ ព្រោះគេមិនបានរាយការណ៍ជូនខ្ញុំវិញទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ ខ្ញុំមានសំណួរបន្តទៀត អំពីកថាខណ្ឌដដែល។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សារបស់គាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា។ អង្គជំនុំជម្រះ សូមជម្រាបជូនដំណឹងដល់ភាគីបានជ្រាបថា កាលពីសប្ដាហ៍មុន គឺអង្គជំនុំជម្រះបានទទួលនូវសំណើសុំរបស់សហព្រះរាជអាជ្ញា ឯកសារ E319/7 គឺសំណើសុំឲ្យអង្គជំនុំជម្រះស្ដាប់នូវសាក្សីថ្មី។ ហើយអង្គជំនុំជម្រះមានបំណងស្ដាប់នូវសារណារបស់ភាគី លើ

សំណើសុំនេះនៅថ្ងៃនេះ នៅចុងម៉ោងរសៀលនៃកិច្ចដំណើរការពិភាក្សារបស់យើង ដើម្បីអង្គជំនុំជម្រះនឹងមានមូលដ្ឋានពិចារណាសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញានេះ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីស្ដាប់សារណាភាគីពាក់ព័ន្ធ សូមជ្រាប។

បាទ ជាបន្តនេះសូមផ្តល់វេទិកាជូនទៅមេធាវី វ៉ិចទ័រ កូប៉េ។ បាទសូមអញ្ជើញ!

[១០:៣៤:៥៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សី ខ្ញុំមានសំណួរបន្ថែមមួយទៀតអំពីឯកសារដែលយើងបានពិភាក្សាកន្លងមក គឺឯកសារ E3/4093 ហើយខ្ញុំចង់ពិភាក្សាអំពីប្រយោគដដែល ដែលនិយាយថា ប៉ុន្តែបើកូននោះបេះមិនដាច់ -- ខ្ញុំឃើញថាសាក្សីគាត់កំពុងនិយាយទូរស័ព្ទ។ ដូច្នេះខ្ញុំសូមផ្អាកបន្តិចសិន។

លោកសាក្សី ខ្ញុំចង់ឲ្យលោកពិនិត្យទៅលើប្រយោគដដែលនេះ គឺប្រយោគដែលចាប់ផ្តើមថា ប៉ុន្តែបើកូននោះ -- ខ្ញុំសូមអានជូនលោកស្ដាប់អំពីការបកប្រែជាភាសាអង់គ្លេសរបស់ខ្ញុំដែលខ្ញុំមាន។ "ប៉ុន្តែបើកូននោះបេះមិនដាច់ពីម្ដាយទេ យើងស្នើយកមកសាកសួរ ហើយបន្ទាប់ពីសាកសួររឿងអស់ហើយបោសសម្អាតចោលទាំងអស់"។ ដូច្នេះខ្ញុំចង់សួរលោកថា ក្មេងដែលគេមិនអាចបំបែកពីម្ដាយ ឬក៏បេះមិនដាច់ពីម្ដាយ តើវាមានន័យថាក្មេងទាំងនោះ គឺសំដៅទៅលើទារក ទារិកាតូចៗ ឬមួយក៏យ៉ាងណា?

**លោក នាង អ៊ូច៖**

**ឆ៖** បញ្ហាក្មេងដែលប្រើក្នុងពេលនេះ មិនមែនទារក ទារិកាទេ ក្មេងធំៗហើយ។ ក៏ប៉ុន្តែការពិតទៅទៀត ក៏ខ្ញុំមិនបានឃើញដែរ មិនបានឃើញក្មេង មិនបានឃើញម្ដាយទេ គឺខ្ញុំទទួលតែរាយការណ៍។ ហើយស្នើយោបល់ យកសេចក្តីរាយការណ៍ហ្នឹងទៅជម្រាបថ្នាក់លើតែប៉ុណ្ណោះ។ ថ្នាក់លើសម្រេចយ៉ាងម៉េច ខ្ញុំសរសេរតាមថ្នាក់លើសម្រេច។

[១០:៣៧:៣១]

**ស៖** ខ្ញុំយល់លោកសាក្សី ប៉ុន្តែខ្ញុំចង់និយាយអំពីពាក្យ "កូនដែលបេះមិនដាច់" តើកូនដែលបេះមិនដាច់ហ្នឹង សំដៅកូនង៉ែត ឬមួយក៏ក្មេងតូចៗ ដែលនៅក្រោមការមើលថែពីម្ដាយនោះ? តើមួយណាដែរ?

**ឆ៖** ពាក្យនេះមិនមែនកូនង៉ែតនៅបៅទេ គឺក្មេងដែលៗចេះដើរ ចេះនិយាយអីហើយ តាមខ្ញុំ

យល់។ ហើយការពិតទៅទៀត ក៏ខ្ញុំមិនបានឃើញដែរ តាមទទួលតាមរាយការណ៍។

**ស៖** ប៉ុន្តែកំណត់ត្រា ហាក់ដូចជាបង្ហាញភាពខុសគ្នារវាងក្មេងធំៗដែលគេបញ្ជូនទៅកងចល័តរួចទៅហើយ។ ហើយមួយក្រុមទៀត គឺក្មេងតូចៗដែលមិន -- ដែលបំបែកពីម្ដាយមិនបាន។ ដូច្នេះ ខ្ញុំចង់សួរថាតើៗមានន័យយ៉ាងម៉េចដែរ នៅពេលដែលគេថាកូនដែលបេះមិនដាច់ពីម្ដាយនោះ? តើសំដៅលើក្មេងបែបណាដែរ?

[១០:៣៩:០៧]

**ឆ៖** អ្នកមនុស្សនៅកងចល័ត គឺយុវជន យុវនារី ឯមានកុមារមួយផ្នែកទៀត កុមារហ្នឹងវាអាយុ ១០ឆ្នាំ ១២ឆ្នាំអី។ ឯទារកៗដែលបេះមិនដាច់ពីម្ដាយ។ ន័ន័យនេះ ខ្ញុំៗបញ្ជាក់ហើយបញ្ជាក់ទៀតរឿងហ្នឹង គឺលោកស្ដាប់មិនបាន។ គឺថា មានន័យថាមិនមែនទារកបេះមិនដាច់ពីម្ដាយទេ ក៏ប៉ុន្តែជាកុមារតូចៗដែលចេះដើរ ចេះនិយាយអីហើយ។ តែការពិតទៅទៀត ក៏ខ្ញុំមិនបានឃើញជាក់ស្ដែងដែរ។ ខ្ញុំទទួលរាយការណ៍ ហើយខ្ញុំយកសេចក្ដីរាយការណ៍នេះទៅជូន តារ៉ន។ តារ៉ន សម្រេចថាម៉េច ខ្ញុំធ្វើតាមហ្នឹង។

**ស៖** សូមអរគុណលោកសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមានសំណើមួយ ហើយសំណើហ្នឹងទាក់ទងទៅនឹងឯកសារនេះដែរ។ ដូចដែលយើងទាំងអស់គ្នាបានដឹងរួចទៅហើយថា គឺយើងមានពេលវេលាតិចតួច ដែលថាយើង ភាគច្រើនយើងមិនមានឯកសារច្បាប់ដើមដែលនៅមាននៅឡើយ។ ដូច្នេះ យើងមានតែឯកសារថតចម្លង។ យើងបានធ្វើការកាត់ត បិទចុះបិទឡើង។ បានន័យថា យើងរៀបចំឯកសារនេះដើម្បីបង្ហាញឲ្យបានច្បាស់ថាតើឯកសារច្បាប់ដើមហ្នឹង វាមើលទៅវាមានលក្ខណៈបែបណា។ ខ្ញុំគិតថាទាំងនេះគឺផ្អែកទៅលើឯកសារជាភាសាខ្មែរ ហើយវាជាកំណត់ត្រាតូចៗ ហើយសាក្សីនេះបានឃើញហើយ គឺថាយើងភ្ជាប់ទៅនឹងឯកសារនេះ។ ខ្ញុំគិតថាចំពោះការណែនាំរបស់អង្គជំនុំជម្រះគឺ ខ្ញុំបានធ្វើដូចតទៅនេះ ខ្ញុំសូមបង្ហាញ។ នេះគឺជាសៀវភៅកំណត់ត្រា ហើយប្រហែលជាកំណត់ត្រារបស់គាត់ហ្នឹង គឺត្រូវបានភ្ជាប់ដូចដែលខ្ញុំបានរៀបចំនេះ។ ហើយខ្ញុំចង់សួរសាក្សីអំពីបញ្ហាថា តើអ្វីដែលខ្ញុំបានធ្វើបង្ហាញហ្នឹង គឺវាប្រហែល ឬក៏ដូចទៅនឹងកំណត់ត្រាដែលគាត់បានធ្វើ ថាតើវាៗធ្វើដូចលក្ខណៈបែបនេះ ឬមួយក៏យ៉ាងដូចម្ដេច? ខ្ញុំគិតថានេះគឺដោយសារតែយើងមិនមានឯកសារច្បាប់ដើម យើងមិនអាចបង្ហាញអំពីឯកសារច្បាប់ដើមបាននោះ។ សូមលោកប្រធានសម្រេច។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៤២:៥៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំចង់សួរលោកបន្ថែមថាតើវា -- តើលោកចង់សួរអំពីថាតើគេបិទ ឬក៏គេកិបជាប់ជាមួយគ្នា ឬមួយក៏យ៉ាងម៉េចដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា បាទ គឺថាបែបនេះមែន ព្រោះវាមានឯកសារជាច្រើន ហើយខ្ញុំព្យាយាមបង្ហាញថាតើតាមពិតទៅអានេះគឺជាវិធីសាស្ត្រដែលគេធ្វើ ឬមួយក៏យ៉ាងដូចម្ដេចដែរ? ឧទាហរណ៍ដូចជាៗវាមានកំណត់ត្រាសរសេរដៃ ហើយបន្ទាប់មកគេយកមកកិប យកមកបិទជាប់គ្នា។ ខ្ញុំយល់បែបនេះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ហេតុអ្វីក៏លោកមិនសួរសំណួរតែម្ដងទៅ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា ខ្ញុំអាចទទួលបានចម្លើយ ប្រសិនបើបង្ហាញឲ្យបានច្បាស់អំពីវិធីសាស្ត្រនៃការរៀបចំឯកសារនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៤៤:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម ខ្ញុំគិតថាការបង្ហាញហ្នឹង វាគឺជាការម៉្យាងដែរ ព្រោះដើម្បីឲ្យភាគីដទៃបានឃើញ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំអាចនឹងទុកសំណួរហ្នឹងទៅក្រោយពេលឈប់សម្រាកបាន ដើម្បីយើងបង្ហាញនូវការថ្មែប្រឌិតរបស់ខ្ញុំទៅដល់ភាគីនានា។

ហេតុផលដែលខ្ញុំសួរបែបនេះ ព្រោះវាមានលក្ខណៈមិនច្បាស់លាស់ ថាតើឯកសារដែលយើង

កំពុងតែអនុវត្តនោះវាមានលក្ខណៈយ៉ាងដូចម្ដេច? ព្រោះថាយើងមិនមានឯកសារច្បាប់ដើម។ ខ្ញុំគិតថាយើងចាំបាច់ត្រូវកំណត់ឲ្យច្បាស់ ថាតើកំណត់ត្រាតូចៗដែលយើងមាននៅក្នុងឯកសារយើងនោះវាបានមកពីរបៀបណា ហើយវាបង្កើតឡើងដោយរបៀបណា ហើយខ្ញុំគិតថាសាក្សីគាត់មានលទ្ធភាពអាចបង្ហាញ ក៏ដូចជាអាចជម្រាបប្រាប់ថានៅពេលនោះឯកសារដែលគេធ្វើហ្នឹងគេធ្វើដោយរបៀបណា ថាគេកិប ឬក៏បិទការ ឬក៏គេប្រើប្រដាប់ខ្ទាស់យ៉ាងដូចម្ដេច? ដូច្នេះវាអាចដែលថាកំណត់ត្រាតូចមួយនោះវាអត់មានអីពាក់ព័ន្ធជាមួយនឹងឯកសារសំខាន់ដូចឯកសារបន្ទាប់នោះឡើយ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា អ្វីដែលព្រះរាជអាជ្ញានិយាយ គឺវាសមហេតុផល ប៉ុន្តែវាហាក់ដូចជាមិនមែនជាអ្វីដែលបង្កើតឡើងដោយសាក្សី។ គាត់អាចសួរថាតើ គេភ្ជាប់ឯកសារ គេបិទឯកសារដោយរបៀបណា គេកិបយ៉ាងណា ហើយគេមានលំដាប់លំដោយបែបណា គាត់អាចធ្វើអ៊ីចឹងបានមិនចាំបាច់ត្រូវបង្ហាញរបៀបនេះទេ។

[១០:៤៦:១៣]

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំនឹងព្យាយាមសាកល្បង។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរលោកអំពីកំណត់ត្រាតូចដែលយើងឃើញទាំងអស់គ្នានេះ។ តើលោកចាំទេថា តើលោកភ្ជាប់កំណត់ត្រា ឬក៏លិខិតតូចៗរបស់លោកទៅនឹងឯកសារធំៗហ្នឹងភ្ជាប់ ដោយរបៀបណា? តើលោកកិបវា ឬមួយក៏លោកប្រើប្រាស់ប្រដាប់ខ្ទាស់ ឬមួយក៏លោក តើលោកចាំទេថាលោកភ្ជាប់កំណត់ត្រាតូចរបស់លោកហ្នឹងទៅឯកសារដទៃទៀតនោះ ភ្ជាប់ដោយរបៀបណា? បិទ ឬក៏កិប ឬក៏អី?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមទោស ព្រោះថាការជំទាស់ខ្ញុំមិនច្បាស់លាស់ទេ ប៉ុន្តែខ្ញុំគិតថាសំណួរ គឺមានន័យថាមេធាវីគាត់សន្មតថា ក្រដាសកំណត់ត្រានោះភ្ជាប់រួចទៅហើយទៅនឹងឯកសារដើម។ ប៉ុន្តែអ្វីដែលមេធាវីបានលើកឡើងកន្លងមកនេះ គឺនៅទំព័រពីរបន្ទាប់ទៀត គឺវាបាននិយាយថា ពីរបាយការណ៍ពីមូលដ្ឋាននៅកំពង់ធំ ហើយផ្ញើទៅគណៈស្រុកនេះ គឺជាកំណត់ត្រាថតចម្លងនៃរបាយការណ៍ពីមូលដ្ឋាន។ ហើយ

ផ្ញើជូន ហើយ "ដោយក្តីគោរពជូនសមមិត្ត វ៉ាត់ សូមជូនជ្រាប"។ ដូច្នេះ ខ្ញុំមិនចង់បង្ហាញអ្វីប្រាប់សាក្សីនោះឡើយ ប៉ុន្តែនេះគឺជាលទ្ធភាពមួយដែលថាឯកសារទាំងអស់នេះ ត្រូវបានសាក្សីបញ្ជូន ឬមួយក៏យ៉ាងដូចម្តេច? ដូច្នេះ ខ្ញុំគ្រាន់តែចង់បាន។

[១០:៤៧:៥០]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ស្របទាំងស្រុងជាមួយខាងព្រះរាជអាជ្ញា ព្រោះថាយើងអត់ដឹង។ អ្វីដែលយើងដឹងគឺដូចដែលខ្ញុំបានបញ្ជាក់ច្រើនដងហើយថា យើងមិនមានឯកសារច្បាប់ដើម។ ហើយយើងដឹងថា ឯកសារនេះត្រូវបានប្រើប្រាស់យ៉ាងច្រើននៅក្រោយឆ្នាំ៧៩។ ដូច្នេះ ប្រសិនបើលិខិតតូចមួយនេះ ត្រូវបានភ្ជាប់ទៅនឹងឯកសារធំ យើងត្រូវកំណត់ឱ្យបានច្បាស់ ព្រោះថានៅពេលចុងក្រោយ គឺយើងនិយាយអំពីការបង្គាប់ឱ្យសម្លាប់មនុស្ស។ ដូច្នេះ ខ្ញុំចង់សាកសួរសំណួរនេះទៅសាក្សី។ លោកសាក្សី តើលោកចាំ បានដែរឬទេ នៅក្នុងករណីជាក់លាក់មួយនេះ គឺលោកភ្ជាប់កំណត់ត្រាតូចរបស់លោកទៅនឹងឯកសារ ខាងក្រៅហ្នឹង តើលោកភ្ជាប់ដោយរបៀបណា?

**ឆ៖** ខ្ញុំចាំៗអត់បាន។ ព្រោះខ្ញុំៗមកឃើញឯកសារតូចៗ សរសេរ ឬនបន្ទាប់អ៊ីចឹង គឺនៅលើក្រដាសហ្នឹងតែម្តង។ ដូច្នេះ ខ្ញុំចាំមិនបាន។

**សៈ** តើលោកចាំថា លោកធ្លាប់ប្រើនៅកំណត់ត្រាតូចៗ ឬក៏របៀបជាលិខិតតូចៗភ្ជាប់ជាមួយនឹងឯកសារធំៗ ឬក៏ក្រដាសធំៗ ដែលនិយាយអំពីក្មេងហ្នឹងដែរឬទេ? តើលោកចាំថាលោកធ្លាប់មានធ្វើអ៊ីចឹងទេ?

**ឆ៖** ខ្ញុំអត់មានចាំទេ គឺខ្ញុំសរសេរខ្លីៗអ៊ីចឹង ហើយមិនដឹងជាភ្ជាប់របៀបណា ខ្ញុំមិនចាំ។ ឃើញឯកសារទាំងអស់នេះ គឺសុទ្ធតែឯកសារថតចម្លង អត់មានច្បាប់ដើមទេ។

[១០:៥០:០០]

**សៈ** ឥឡូវនេះ ខ្ញុំចង់អានឱ្យលោកស្តាប់នូវឃ្លាមួយនៃសាក្សីស្ត្រីម្នាក់ ដែលយើងបានពិភាក្សាកន្លងមក ហើយខ្ញុំចង់ឱ្យលោកពិនិត្យមើលទៅលើសំណួរ២១២ គឺឯកសារ E319/12.3.2 គឺសំណួរ ២១២ ខ្ញុំសូមដកស្រង់ "នៅពេលដែលឈ្លបចាប់ខ្លួនមនុស្សហើយ តើលោកស្រីសរសេរសំបុត្រឆ្លើយតបទៅ អាន់ វិញដែរឬទេ? ឆ្លើយ៖ ខ្ញុំមិនសរសេរទៅ អាន់ ទេ គឺខ្ញុំសរសេរទៅលេខាស្រុកតែម្តង ព្រោះនៅពេលនោះ មានលិខិតខ្លះក្លែងក្លាយ។ ដូច្នេះ ខ្ញុំក៏មានការបារម្ភអំពីខ្លួនឯងផងដែរ។ នៅក្នុងសំបុត្រនោះ ខ្ញុំ

សរសេរថា ឥឡូវចាប់មនុស្សបានហើយ តាមការស្នើ""។ លោកសាក្សី សាក្សីស្ត្រីម្នាក់នេះ គឺជាកម្មាភិបាលស្ថិតនៅក្នុងឋានៈកម្រិតស្មើលោកដែរ ហើយគាត់និយាយថា វាមានលិខិតខ្លះក្លែងក្លាយ តើលោកយល់យ៉ាងម៉េចដែរ ចំពោះការគាត់និយាយថាមានលិខិតខ្លះក្លែងក្លាយនោះ?

[១០:៥១:៣៨]

**ឆ៖** ខ្ញុំសូមលើកបង្ហាញ ឯកសារលេខ E3/2785 "សរសេរជូនមកបងសមមិត្ត អាន់ ជ្រាបពីរនាក់នេះ គឺរត់ទៅយួន ជាមួយពួកអាពីរថ្ងៃមុន។ ចុះថ្ងៃ៧ ខែ៣ សរសេរឈ្មោះខាងក្រោម គឺ សាន។ ដូច្នេះ លិខិតនេះ ជាលិខិតក្លែងក្លាយ។ ក្នុងសម័យនុ៎ងវាលំបាកអ៊ីចឹង មានលិខិតក្លែងក្លាយអ៊ីចឹងតើឲ្យខ្ញុំដោះស្រាយយ៉ាងម៉េច? ខ្ញុំឆ្លើយអ៊ីចឹង ឆ្លើយថាលិខិតនេះមិនមានជាអក្សររបស់ខ្ញុំទេ។ ខ្ញុំស្គាល់អក្សរខ្ញុំច្បាស់លាស់។ អ៊ីចឹងដូចៗស្ត្រីម្នាក់ដែលឆ្លើយថាវាមានលិខិតក្លែងក្លាយអ៊ីចឹង។ ដល់អ៊ីចឹងបានខ្ញុំគិតឃើញដល់ការបញ្ជារបស់ តារ៉ុន។ តារ៉ុន ហេតុម៉េចក៏គាត់បានជាបញ្ជាខ្ញុំមាត់ទទេ ហើយគាត់អត់ចុះហត្ថលេខា គឺគាត់ត្រៀម មិនដឹងជាយុទ្ធសាស្ត្រគាត់យ៉ាងម៉េចក្នុងសមភាពការណ៍ពេលនុ៎ង ប្រហែលជាគាត់គិតដល់ថ្ងៃហ្នឹងដែរ។ អ៊ីចឹងធ្លាក់កំហុសហ្នឹងមកលើតែខ្ញុំ។ មកពីឯកសារហ្នឹងខ្ញុំសរសេរ ខ្ញុំចុះហត្ថលេខា ដូច្នេះសម្ដី តារ៉ុន ដែលបញ្ជាឲ្យខ្ញុំធ្វើតាមវាបាត់ទៅក្នុងខ្យល់ទៅ។

**ស៖** ខ្ញុំយល់លោកសាក្សី។ តើលោកសាក្សីអាចពន្យល់បានទេ ហេតុអ្វីឯកសារ E3/2785 ជាឯកសារក្លែងក្លាយ។ តើលោកមានមូលដ្ឋានអ្វី ឬក៏មានហេតុផលអ្វីដែលលោកអាចបញ្ជាក់ថា ឯកសារដែលសល់ពីសម័យខ្មែរក្រហមនេះ គឺជាឯកសារក្លាយក្លែងទៅវិញ? តើលោកមានភស្តុតាង មានមូលហេតុអីទេ?

**ឆ៖** ខ្ញុំមានភស្តុតាងត្រង់អក្សរនេះ មិនមែនជាអក្សររបស់ខ្ញុំ ដែលសរសេរដោយដៃខ្ញុំ។ មិនមែនទេ។

[១០:៥៤:០៨]

**ស៖** ប៉ុន្តែ តើលោកអាចបង្ហាញបានដោយរបៀបណា ដែលថានេះជាឯកសារដែលធ្វើឡើងក្លែងក្លាយតាំងពីសម័យខ្មែរក្រហម គឺខ្ញុំកំពុងតែស្នើឲ្យលោកធ្វើការសន្មត ជាការស្មាន។ ថាតើឯកសារហ្នឹងមិនមែនក្លែងក្លាយតាំងពី -- មិនមែនក្លែងក្លាយក្រោយឆ្នាំ៧៩ ទេឬ?

**ឆ៖** បញ្ហាឆ្នាំ ខ្ញុំមិនយល់ដែរ មិនដឹងជាក្លែងក្លាយនៅពេលណា តែខ្ញុំមិនយល់ពីឆ្នាំទេ ពីពេលវេលាទេ។

**ស៖** ដូច្នេះលោកនៅរក្សាចម្លើយរបស់លោក ព្រោះថាវាមិនដូចជាឯកសារសរសេរដៃ មិនមែនជាហត្ថលេខា ដោយសារអ៊ីចឹងហើយទើបលោកថាវាជាឯកសារក្លែងក្លាយ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទអ៊ីចឹងមែន ព្រោះមិនមែនអក្សរខ្ញុំ ដែលៗសរសេរដៃ មិនមែនអក្សរខ្ញុំទេ។

**ស៖** ចុះលោកឯកសារ -- ចុះឯកសារ E3/2423 ដែលខ្ញុំគិតថាជាសក្ខីកម្មពាក់ព័ន្ធទៅនឹងឯកសារនេះផងដែរ ហើយជាឯកសារដែលមិនមែនជាលិខិតសរសេរដៃរបស់លោក គឺខ្មែរ មានលេខ 0079128 លោកសាក្សីខ្ញុំចង់ឲ្យលោកពិនិត្យទៅលើឯកសារ E3/2423។ ហើយខ្ញុំចង់ឲ្យលោកប្រាប់ថាតើឯកសារហ្នឹងជាហត្ថ -- មានហត្ថលេខាហ្នឹងជារបស់លោកឬក៏អត់ ហើយតើវាជាឯកសារពិតប្រាកដ ឬក៏ជាឯកសារក្លែក្លាយ? សូមលោកពិនិត្យមើល។

**ឆ៖** ឯកសារ E3/2423 នេះមិនៗមែនជាអក្សររបស់ខ្ញុំទេ។

**ស៖** ចុះចំពោះឯកសារកន្លងមកនេះ ឯកសារមុននេះ អ៊ីចឹងលោកនៅប្រាកដណាស់ថាវាជាឯកសារក្លែងក្លាយ ហើយឯកសារនេះក៏ជាឯកសារក្លែងក្លាយដែរ។ អ៊ីចឹង ហេតុអ្វី លោកមានមូលហេតុអ្វីទេដើម្បីបញ្ជាក់?

**ឆ៖** ខ្ញុំមានមូលហេតុតែមួយគត់គឺ អក្សរនេះមិនមែនអក្សរសរសេរដៃដោយខ្ញុំ។

[១០:៥៧:៣៣]

**ស៖** លោកសាក្សី ឥឡូវនេះខ្ញុំចង់ឲ្យលោក -- E3/2444 ហើយខ្ញុំនឹងសួរលោកនៅសំណួរដដែល។ កន្លងមកលោកបានបញ្ជាក់ បានផ្ដល់សក្ខីកម្មរួចហើយថាមិនមែនជាឯកសារសរសេរដោយដៃរបស់លោក និងមិនមែនជាហត្ថលេខារបស់លោក។ សូមលោកបញ្ជាក់ឡើងវិញម្ដងទៀត ថាតើអ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងជាតិ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស អរគុណលោកប្រធាន។

យោងទៅលើឯកសារ E324/44 ដែលមេធាវីការពារទើបតែលើកឡើង។ តាមដែលខ្ញុំកត់សម្គាល់ដោយកំណត់ហេតុផ្ទាល់របស់ខ្ញុំ គឺសាក្សីបាននិយាយថា ឯកសារនេះមិនអាចអានបាន មិនមែនគាត់ថា មិនមែនជាហត្ថលេខារបស់គាត់ទេ។ អ៊ីចឹង ប្រសិនបើមេធាវីមានចម្លើយរបស់សាក្សីដែលឆ្លើយ

សូមឲ្យ លេខឯកសារ ហើយនិងលេខយោងឲ្យបានច្បាស់លាស់។ សូមអរគុណលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនជាបញ្ហាទេលោកស្រី។ ខ្ញុំនឹងបន្តទៅឯកសារមួយផ្សេងទៀត ព្រោះថាខ្ញុំផ្អែកទៅលើសេចក្តីព្រាងនៃប្រតិចារឹក។ ដូច្នេះ យើងមិនច្បាស់ទាំងអស់គ្នា។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវនេះ ខ្ញុំចង់ឲ្យលោកពិនិត្យមើលទៅលើឯកសារមួយទៀត E3/4122 ហើយខ្ញុំចង់សួរសំណួរដដែលចំពោះលោក។ សូមលោកពិនិត្យមើលឯកសារ E3/4122។

[១១:០០:១៧]

**កញ្ញា សុង ឆវ័ន្ត៖**

លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញសហព្រះរាជអាជ្ញារងជាតិ!

**កញ្ញា សុង ឆវ័ន្ត៖**

សូមទោសលោកប្រធាន ដោយសារតែមេធាវីបានយោងទៅលើឯកសារទាំងមូល ហើយប្រសិនបើមានលេខយោង ERN ច្បាស់លាស់ សូមឲ្យមេធាវីផ្តល់ជូន។ ពីព្រោះឯកសារនេះ វាមានច្រើនទំព័រ តើទំព័រមួយណា ដែលលោកមេធាវីយោង ផ្ញើ -- យោងទៅដល់នោះ?

**ប្រធានអង្គជំនុំ៖**

បាទ អគុណ។ សូមព្រះរាជអាជ្ញា អ៎! សូមមេធាវី កូប៉េ អានបញ្ជាក់ឯកសារ និងលេខ ERN ជាបីភាសាផង ដើម្បីងាយក្នុងការ ភាគីតាមដានពិនិត្យមើលឯកសារចំណុចដែលលោកយោងមកសួរដេញដោលសាក្សីនេះ។ រួមទាំងសាក្សីផង និងមេធាវីប្រឹក្សា គាត់អាចជួយជ្រោមជ្រែងដល់កិច្ចការនេះឲ្យបានឆាប់រហ័ស។

[១១:០១:១០]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន។ ខ្មែរមានលេខ ERN00271087, អង់គ្លេសមានលេខ 00779255 រហូតដល់57 ហើយខ្ញុំសូមអភ័យទោស ដោយសារខ្ញុំមិនមាន ERN ជាភាសាបារាំងទេ។

លោកប្រធាន ខ្ញុំគិតថា មេធាវីប្រចាំការ ដូចជាមិនមានឯកសារនេះទេ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតប្រគល់ឯកសារនេះ ជូនទៅមេធាវីប្រចាំការ គឺឯកសារដែលមេធាវីប្រឹក្សានេះ គឺខ្ញុំសូមអនុញ្ញាតប្រគល់ឯកសារជូនទៅមេធាវីប្រឹក្សាដើម្បីផ្ដល់ជូនសាក្សី។

[១១:០២:០១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកមេធាវីប្រឹក្សាគឺខ្ញុំគិតថា ឯកសារមានលេខ 00271087។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះ លោកសាក្សី ពីម្សិលមិញលោកនិយាយថា "អក្សរនេះមិនមែនជាអក្សរដោយដៃលោកទេ" តើលោកនៅរក្សាចម្លើយនេះដដែល ជំហរនេះដដែលឬ? ខ្ញុំឃើញសហព្រះរាជអាជ្ញាអន្តរជាតិលោកឡើងឈរហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគឺថា ពេលខ្ញុំនឹកទៅដល់ចៅក្រម ឡាវ៉ែន៍ ឬក៏ដូចជាចៅក្រមដទៃ ដែលបង្គាប់ឲ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសួរនោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំស្នើសុំឲ្យក្រុមរបស់ខ្ញុំប្រមូលឯកសារទាំងអស់ ដើម្បីបង្ហាញទៅដល់សាក្សីដែល គឺឯកសារដែលពាក់ព័ន្ធនឹងចម្លើយសាក្សី។ ដូច្នេះ ខ្ញុំសុំរៀបចំបញ្ហានេះឡើងវិញ ហើយខ្ញុំមិនដឹងថាយើងមានសេចក្ដីព្រាងគ្រប់របាយការណ៍ទាំងអស់ ឬក៏អត់ទេ។

អ៊ីចឹង ខ្ញុំសុំចូលទៅប្រធានបទមួយផ្សេងទៀតដើម្បីឲ្យបានលឿនបន្តិច ហើយខ្ញុំ លោកចៅក្រមឡាវ៉ែន៍ ខ្ញុំឃើញថាឯកសារ E3/2424 ដែលបានបង្ហាញកាលពីម្សិលមិញ ហើយខ្ញុំមើលទៅឃើញដូចជាមិនមានការងក់ក្បាល ប៉ុន្តែលោកសាក្សីសុំឲ្យមើលឯកសារ E3/2424, ERN ខ្មែរ 00270757 ដល់ 58 និងរហូតដល់ 61។

[១១:០៦:១១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំដូចជាមិនចាំថាខ្ញុំបានប្រើឯកសារនេះទេ លោកមេធាវី កូប៉េ។ ខ្ញុំគិតថា ខ្ញុំអត់បានប្រើទេឯកសារមួយនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

បើអ៊ីចឹងទេ លោកចៅក្រមខ្ញុំសុំបន្ទាប់ពីសម្រាក សុំប្រើពិនិត្យមើលឯកសារនេះឡើង ប្រហែលជាបញ្ហាដោយសារក្រុមខ្ញុំពិនិត្យមិនបាន--

**លោក នីកូឡាស គូមជែន៖**

ខ្ញុំបានប្រើប្រាស់ឯកសារនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ឥឡូវ លោកសហព្រះរាជអាជ្ញាបានឆ្លើយហើយថាគាត់បានប្រើឯកសារនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើនេះជាអក្សរដៃរបស់លោក និងជាហត្ថលេខារបស់លោក ឬអត់ទេ? ហើយបើសិនជាអត់ទេ ថាតើនេះ អក្សរដៃនេះ និងហត្ថលេខានេះ គឺជារបាយការណ៍ក្លែងក្លាយដែរឬក៏អត់?

**ឆ៖** ឯកសារលេខប៉ុន្មាន?

**ស៖** ឯកសារ E3/2424។ លោកសាក្សីមានឯកសារហើយឬនៅ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានសុំការអនុញ្ញាតបង្ហាញឯកសារជាក្រដាសនេះទៅសាក្សីគឺឯកសារ E3/2424។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកសាក្សីជាពិសេសគឺខ្ញុំចង់ឲ្យលោកពិនិត្យមើលជាមួយនឹងមេធាវីប្រឹក្សារបស់លោកគឺ ERN ជាភាសា 00277057 ដល់ 58 ដល់ 61 – ERN ខ្មែរ 00270757 ដល់ 58 ដល់ 61។

[១១:០៨:៥៥]

ខ្ញុំគិតថាអានឈ្មោះជាខ្មែរហ្នឹងវាមិនច្បាស់ទេ ប៉ុន្តែត្រង់ទំព័រខ្មែរ ទំព័រ៦១ និងទំព័រ៥៧, ៥៨ គឺ ទំព័រទាំងបីនេះគឺជាទំព័រដែលពាក់ព័ន្ធ។

*(សម្រាករយៈពេលខ្លី)*

[១១:១១:៥១]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ អក្សរនេះអក្សរលោកឬ ហើយ ហត្ថលេខានេះ ហត្ថលេខារបស់លោក ឬមិនមែនទេ?

**លោក នាង អ៊ួច៖**

**ឆ៖** ឯកសារលេខប៉ុន្មាន លេខ 00270761, ឯកសារ E3/2424 មែនទេ?

**ស៖** ខ្ញុំទើបតែឲ្យឯកសារនេះទៅលោកមួយច្បាប់អម្បាញ់មិញ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំស្នើសុំដូចតទៅ ដើម្បីរៀបចំបញ្ហានេះឡើងវិញ កុំឲ្យមើលទៅឲ្យចំៗទំព័រ ពាក់ព័ន្ធតែម្តង។ ប៉ុន្តែខ្ញុំ គឺថាពឹងពាក់ទៅលើទីប្រឹក្សា -- មន្ត្រីច្បាប់របស់ខ្ញុំ។ ប្រសិនជាលោកប្រធានមិន យល់ទាស់ទេ គឺថាបន្ទាប់ពីសម្រាកពិសាបាយថ្ងៃត្រង់ហើយ យើងខ្ញុំនឹងរៀបចំបញ្ហានេះឲ្យស្រួលបួល ឡើងវិញ។ ខ្ញុំសូមចូលទៅប្រធានបទផ្សេងចុះពេលនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំនឹងត្រឡប់មកនិយាយពីឯកសារនេះឡើងវិញ។ តែឥឡូវនេះខ្ញុំសួរសំណួរ លោកខ្លះៗទាក់ទងទៅនឹងបញ្ហាដទៃទៀត ចំពោះសាក្សីស្រីដែលយើងបានផ្តល់សក្ខីកម្មនេះ។ មានសារ ជាច្រើននៅក្នុងចម្លើយរបស់-- ខ្ញុំចង់អានជូនឲ្យលោកសាក្សីស្តាប់។ សំណួរខ្ញុំគឺ សួរមួយសំណួរឲ្យ លោកផ្តល់មតិយោបល់មួយសំណួរ។ ឯកសារនេះគឺ E319.12.32 គឺត្រង់សំណួរចម្លើយលេខ៥៦។ បាទ ឯកសារ -- អូខេនៅពេលដែលពិនិត្យមើល ដូច្នេះខ្ញុំសូមដកស្រង់តែម្តង គឺសំណួរសួរអំពី តាម៉ុក។ “សួរ៖ តើលោកស្គាល់តាម៉ុកដោយផ្ទាល់ខ្លួនឬ? ចាស ខ្ញុំស្គាល់គាត់ដោយផ្ទាល់ ជួនកាលគាត់មកមើល សហករណ៍ មើលផ្ទះបាយ ហើយសួរថា តើប្រជាជនមានអាហារហូបគ្រប់គ្រាន់តែ? ខ្ញុំជួបតាម៉ុក”។ សំណួររបស់ខ្ញុំស្រួលទេលោកសាក្សី តើលោកអាចបញ្ជាក់បានឬក៏អត់ទេថា តាម៉ុក តែងតែសួរតើប្រជា ជនមានម្ហូបអាហារគ្រប់គ្រាន់ដែរឬទេ?

[១១:១៤:៤៧]

**លោក នាង អ៊ួច៖**

**ឆ៖** តាម៉ុក តែងតែសួរដូចស្ត្រីនេះឆ្លើយអ៊ីចឹង។ គឺថាគាត់តែងតែសួរថា មានបាយ មានម្ហូបអីគ្រប់គ្រាន់ឬទេ?

**ស៖** តាមការចងចាំរបស់លោកថា តាម៉ុក គាត់មានការព្រួយបារម្ភខ្លាចក្រែងប្រជាជនមានមិនមានអាហារហូបគ្រប់គ្រាន់។ តើនេះជាការព្រួយបារម្ភរបស់គាត់តាំងពីដំបូងមក ឬក៏យ៉ាងម៉េច?

**ឆ៖** ការព្រួយបារម្ភរបស់គាត់នេះ គឺគាត់ព្រួយបារម្ភជារឿងរហូតអ៊ីចឹងហ្នឹង ពីព្រោះគាត់ជាកសិករ គាត់ជាអ្នកស្រែ អ្នកចម្ការ។

**ស៖** តើមាននៅចាំថា មានស្ត្រីក្នុងស្ថានភាពណាមួយនោះ គាត់ត្រូវគេបានបង្ហាញ មកប្រាប់ថាប្រជាជនមិនមានអ្វីហូបគ្រប់គ្រាន់ ហើយគាត់ចាត់វិធានការអីទេ ដែលមានពេលណាដែលគេប្រាប់គាត់ថាប្រជាជនមិនមានអ្វីហូបគ្រប់គ្រាន់ ហើយគាត់មានចាត់វិធានការនោះទេ?

**ឆ៖** មាន ខ្ញុំជួប មានពេលខ្លះគឺមានគាត់ចាត់វិធានការ គឺយកៗអង្ករពីខាងឃ្លាំងរបស់គាត់យកមកឱ្យប្រជាជនហ្នឹង យកមកឱ្យសហករណ៍ហ្នឹង។ មាន ជួបម្តងម្កាល។

**ស៖** សូមអរគុណលោកសាក្សី។ សាក្សីដដែលនេះត្រូវបានសួរសំណួរ គឺសំណួរ២០១ -- សំណួរ១០១។ ខ្ញុំសូមសួរឱ្យលោកមានប្រតិកម្មម៉េចយ៉ាងម៉េចដែរនឹងសំណួរហ្នឹង។ "សួរ៖ ក្រោយខ្មែរក្រហមប្រកាសជ័យជម្នះនៅឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញគ្មានមនុស្សទេ ដោយមនុស្សត្រូវបានគេដេញចេញពីក្រុងទាំងអស់។ ប្រជាជនជាច្រើនត្រូវបានគេជម្លៀសទៅតំបន់១៣។ តើអាជ្ញាធរខ្មែរក្រហមបានបែងចែក ឬក៏ចាត់ថ្នាក់ប្រជាជនទាំងអស់នោះដូចម្តេច? ឆ្លើយ៖ តាមខ្ញុំចាំ ដំបូងគេយកប្រជាជនទាំងអស់ទៅដាក់នៅម្ដុំសិន។ បន្ទាប់មក គេចែកទៅតាមភូមិដោយរស់នៅចម្រុះគ្នា។ គេចែកឱ្យតាមភូមិនីមួយៗត្រូវយកប្រជាជនប៉ុន្មាន អាស្រ័យទៅតាមទំហំសេដ្ឋកិច្ចរបស់ភូមិនោះ"។ តើលោកមានប្រតិកម្ម ឬមានយោបល់យ៉ាងម៉េច ថាតើចម្លើយនេះត្រឹមត្រូវដែរឬក៏អត់ទេ?

[១១:១៧:៥២]

**ឆ៖** ចម្លើយនេះត្រឹមត្រូវ។

**ស៖** លោកអាចនិយាយបានឱ្យលម្អិតបន្តិចបានទេថា ដោយឱ្យរស់នៅចម្រុះគ្នាហ្នឹង។ សូមរៀបរាប់លម្អិតបន្តិចមក?

**ឆ៖** ន័យៗដែលថារស់នៅចម្រុះគ្នាហ្នឹង គឺប្រជាជនដែលចេញទៅពីភ្នំពេញ ឲ្យរស់នៅតាមភូមិជាមួយប្រជាជនដែលរស់នៅក្នុងភូមិនោះពីយូរហើយ។ ន័យវាគឺអ៊ីចឹង ចម្រុះគ្នា។ ឧទាហរណ៍ផ្ទះប្អូនប្រាំអ៊ីចឹង ដាក់ពីរបីគ្រួសារ។ ផ្ទះប្អូនដប់ ដាក់ពីរបីគ្រួសារអ៊ីចឹងទៅ។ បន្ថែមប្រជាជនដែលចេញមកពីភ្នំពេញ។

**ស៖** តើលោកចាំថាប្រជាជនដែលមកពីទីក្រុងភ្នំពេញ រស់នៅចម្រុះគ្នាជាមួយអ្នកភូមិនោះ ហើយក្រោយមកត្រូវបានគេរើសអើងដែរឬក៏អត់ ដោយសារតែពួកគេមកពីក្រុងភ្នំពេញនោះដែរឬអត់ទេ?

**ឆ៖** ខ្ញុំមិនដែលជួបប្រទះរឿងរើសអើងហ្នឹងផង។

**ស៖** លោកសាក្សី គឺមានសក្ខីកម្មដែលគេនិយាយថា ប្រជាជន១៧ មេសា គិតថា គេគឺមិនមានឋានៈដូចអ្នកភូមិនោះទេ។ តើលោកយល់យ៉ាងម៉េចដែរចំពោះបញ្ហានេះ?

**ឆ៖** បញ្ហាហ្នឹងប្រហែលជាប្រជាជនមកពីភ្នំពេញ គាត់គិតខ្លួនអ៊ីចឹងឬយ៉ាងណា។ ដូចៗខ្ញុំគិតខ្លួនខ្ញុំអ៊ីចឹង។ ខ្ញុំមានម៉ែបង្កើត បងបង្កើត ប្អូនស្រីបង្កើត មកពីភ្នំពេញហ្នឹង ខ្ញុំគិតថាសាច់ឈាមខ្ញុំ ១៧ មេសាអ៊ីចឹង។ ខ្ញុំចេះតែគិតអ៊ីចឹងដែរ តែប្រហែលជាប្រជាជនចេញពីភ្នំពេញទៅ គាត់គិតខ្លួនគាត់អ៊ីចឹងដែរដឹង អាហ្នឹងបញ្ហាហ្នឹង ខ្ញុំមិនៗច្បាស់ទេ។

[១១:២០:៥៦]

**ស៖** តើលោកដឹងថាមានគោលនយោបាយណាមួយ គោលនយោបាយខ្មែរក្រហមរើសអើងចំពោះប្រជាជន១៧មេសាដែរឬទេ? តើលោកដឹងថាមានគោលនយោបាយបែបនេះទេ?

**ឆ៖** មុនខ្ញុំមកនៅស្រុកត្រាំកក់នេះ ខ្ញុំមិនៗដឹងថាមាននយោបាយហ្នឹង ឬយ៉ាងម៉េចទេ។ តែខ្ញុំមិនចាំៗពេលវេលា ពេលដែលខ្ញុំមកនៅស្រុកត្រាំកក់ហើយ ពួគណៈស្រុកប្រកាសថា ប្រជាជនទាំងអស់គឺស្មើគ្នា មានភាពស្មើគ្នា។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចូលទៅចម្លើយមួយទៀតពីសាក្សីរូបនេះ គឺចម្លើយ១១១ដល់១១៤។ ខ្ញុំសូមអានសំណួរ-ចម្លើយនេះ ប៉ុន្តែវាៗវែងបន្តិច។ “សួរ៖ ក្នុងរបបខ្មែរក្រហម បក្សគឺជាអ្នករៀបចំការរៀបការ តើគេរៀបចំការរៀបការយ៉ាងដូចម្ដេច? តើមានការពិភាក្សានៅក្នុងថ្នាក់តំបន់ឬទេ ឬនៅសហករណ៍ ឬថ្នាក់ភូមិជាអ្នកសម្រេច? ឆ្លើយ៖ ថ្នាក់ឃុំជាអ្នកសរសេរឈ្មោះបុរសស្ត្រីដែលត្រូវរៀបការ ហើយបញ្ជូនទៅថ្នាក់តំបន់ជាអ្នកសម្រេចថាតើត្រូវរៀបការប៉ុន្មានគូម្ដង។ ខ្ញុំថ្នាក់ក្រោមពុំបានសម្រេចចំពោះបញ្ហានេះទេ។ អ្នកដែលស្រឡាញ់គ្នា គេប្រាប់មកយើង ហើយយើងសរសេរឈ្មោះបញ្ជូន

ទៅតំបន់ ហើយអ្នកដែលមិនពុំគឺប្រាប់ថាមិនព្រម យើងនឹងឆូតឈ្មោះចោល។ សួរ៖ យើងមានភស្តុតាង ហើយដឹងថាប្រជាជនពុំមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសប្តីប្រពន្ធនោះទេ។ បក្ស គឺជាអ្នកបង្ខំប្រជាជនឲ្យរៀបការ តើនេះជាការពិតដែរឬទេ? ឆ្លើយ៖ បក្សជាអ្នកសម្រេច ប៉ុន្តែគេរៀបចំឲ្យប្រជាជនថ្មីរៀបការជាមួយនិងប្រជាជនថ្មី ចំណែកប្រជាជនចាស់ត្រូវរៀបការជាមួយនឹងប្រជាជនចាស់។ យើងអាចនិយាយថា បង្ខំឲ្យរៀបការបាន ព្រោះបក្សជាអ្នកសម្រេចនៅក្នុងការរៀបការនេះ។ ប្រសិនបើប្រជាជនថ្មីត្រូវរៀបការជាមួយនឹងប្រជាជនចាស់ ហើយមានអ្នកណាបដិសេធ គេនឹងឆូតឈ្មោះចេញព្រោះអ្នកខ្លះមានប្រវត្តិរូបមិនល្អ។ សួរ៖ តើការរៀបការដោយបង្ខំនេះ ឬការកំណត់រៀបការនេះ ថ្នាក់មជ្ឈិមកំណត់មកថ្នាក់ភូមិភាគ ហើយមកថ្នាក់តំបន់ រួចហើយមកថ្នាក់ស្រុកឃុំតែម្តង ឬក៏ការរៀបការនេះ គឺថ្នាក់ឃុំស្រុកជាអ្នកសម្រេច? ឆ្លើយ៖ ការរៀបការនេះ គឺមិនមែនថ្នាក់មជ្ឈិមទេ គឺថ្នាក់ឃុំជាអ្នករៀបចំ។ ហើយសំណួរចុងក្រោយ៖ តើអ្នកណាជាអ្នកសម្រេចថាអ្នកណាម្នាក់រៀបការជាមួយនឹងអ្នកណាម្នាក់ទៀត? ឆ្លើយ (ចម្លើយ១១៤)៖ សម្រាប់កន្លែងរបស់ខ្ញុំ ខ្ញុំមើលសភាពការណ៍ថា កម្លោះម្នាក់ហ្នឹងនិងក្រមុំម្នាក់ហ្នឹងធ្វើការចូលគ្នា ហើយខ្លះក៏មានការខិលខូច ហើយក៏ -- ដូច្នេះ ខ្ញុំក៏រៀបចំការពួកគេជាមួយគ្នា។ ថ្នាក់ភូមិរាយការណ៍មកឃុំថា ឈ្មោះនេះត្រូវរៀបការជាមួយនឹងឈ្មោះនេះ ហើយក៏មានការបង្ខំដែរ។ បន្ទាប់មកទៀត ថ្នាក់ឃុំរាយការណ៍ទៅថ្នាក់ស្រុកបន្តទៀត តែខ្ញុំមិនដឹងថាថ្នាក់ស្រុករាយការណ៍បន្តឬក៏អត់ទេ។ ចំណែកកន្លែងខ្លះរបស់គេផ្សេងទៀត ខ្ញុំមិនដឹងគេរៀបចំការរៀបការដូចម្តេចនោះទេ"។ ខ្ញុំក៏មានសំណួរ-ចម្លើយ១១៦ដែរ "យើងមានភស្តុតាង ហើយដឹងថា មានមនុស្សប្រុសស្រីជាច្រើនបានបដិសេធមិនព្រមរៀបការជាមួយគ្នា ដោយសារពួកគេក៏មិនដែលបានជួបមុខគ្នាពីមុនមកទេ។ តើលោកស្រីដឹងបញ្ហានេះដែរឬទេ តើមានរឿងអ្វីកើតឡើងប្រសិនគេបដិសេធមិនព្រមរៀបការទៅតាមការរៀបចំនេះ? ឆ្លើយ៖ នៅកន្លែងខ្ញុំអត់មានរឿងដូច្នេះកើតឡើងទេ គឺថាអ្នកទាំងអស់សុទ្ធតែស្គាល់គ្នា ព្រោះកន្លែងរបស់ខ្ញុំវាតូច។ យើងរៀបចំការរៀបការជាមួយគ្នា ហើយស្វាមីយល់ព្រម ប៉ុន្តែបើថ្នាក់លើមិនយល់ព្រម នោះពួកគេក៏ពុំអាចរៀបការនោះបានដែរ"។ នេះគឺជាសំណួរចម្លើយដ៏វែងពីសាក្សីរូបនេះ។ ខ្ញុំសូមសួរទូទៅ តើលោកយល់ស្របទេ ឬក៏មិនយល់ស្របទេជាមួយនឹងចម្លើយនេះពាក់ព័ន្ធទៅនឹងការរៀបការ?

**ឆ៖** ខ្ញុំយល់ស្រប ព្រោះករណីឃុំខ្លះធ្វើអ៊ីចេះ ករណីខ្លះធ្វើអ៊ីចុះ។ ហើយដូច្នេះ គាត់ក្នុងករណីឃុំគាត់ គាត់ធ្វើអ៊ីចឹង អាហ្នឹងខ្ញុំយល់ស្រប។

[១១:២៦:៤០]

**ស៖** លោកដឹងទេថា ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យមានគោលនយោបាយបង្ខំបុរសស្ត្រី ឲ្យរៀបការប្រឆាំងនឹងឆន្ទៈរបស់គេ។ តើលោកដឹងទេ? មានន័យម្យ៉ាងទៀតថា ថាពួកគេត្រូវការរៀបចំ ឲ្យរៀបការទោះបីគេមិនយល់ព្រម ឬក៏ទោះបីជាពួកគេមិនស្រលាញ់គ្នាក៏ដោយ។

**ឆ៖** បញ្ហាហ្នឹងខ្ញុំមិនដឹងច្បាស់ទេ ប៉ុន្តែការបកស្រាយរបស់សាក្សីរូបនេះ គឺឆ្លើយបាន -- គឺត្រឹមត្រូវគាត់អនុវត្តនៅកន្លែងគាត់គឺត្រឹមត្រូវតាមហ្នឹង។ ឯការបង្ខិតបង្ខំអីដែលគេមិនព្រម ដូចគាត់បញ្ជាក់អីចឹងគឺថាមានការឆូតឈ្មោះមួយគូហ្នឹងចេញ។

**ស៖** តើមានគោលការណ៍ទូទៅណាមួយចេញពីថ្នាក់កំពូលមកដល់អាជ្ញាធរថ្នាក់ក្រោមបំផុតដែលបញ្ជាក់ថាត្រូវបង្ខំប្រជាជនឲ្យរៀបការដែរទេ?

**ឆ៖** ខ្ញុំដូចជាមិនចាំ។ គោលការណ៍ហ្នឹងខ្ញុំមិនដែល ខ្ញុំមិនចាំទេ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះអំពីភាពខុសៗគ្នារវាងឃុំផ្សេងៗគ្នា កាលណានិយាយអំពីការរៀបការនេះ? តើលោកមានការចងចាំរបៀបគេរៀបចំការរៀបការនុ៎ងវាខុសគ្នាយ៉ាងម៉េចដែរពីឃុំមួយទៅឃុំមួយ?

[១១:២៨:៥៤]

**ឆ៖** របៀបរៀបចំការមិនខុសប្លែកគ្នាប៉ុន្មានទេ របៀបណ៎ា របៀបរបបរៀបចំការគឺឧទាហរណ៍ថាប្រាំគូអីចឹង ប្រធានឃុំ ឬប្រធានសហករណ៍រៀបចំសមាជិករបស់ខ្លួនហើយ កូនចៅរបស់ខ្លួនហើយ។ ដូច្នេះ ប្រធានឃុំ ឬប្រធានសហករណ៍ប្រកាសៗ ហើយថាពេលនេះរៀបចំប្រាំគ្រួសារនេះឲ្យបានគ្នាជាប្ដីជាប្រពន្ធអីចឹងទៅ ហូរហែអីចឹងទៅ ហើយបានឲ្យសាមីខ្លួនប្រុសសម្រេចចិត្តឡើងសម្រេចចិត្តឡើងប្ដេជ្ញាចិត្តស្រលាញ់គ្នាទទួលគ្នាជាប្ដីប្រពន្ធទេ ហើយបន្ទាប់ពីសាមីខ្លួនប្រុសឡើងសម្រេចចិត្តហើយសាមីខ្លួនស្រីក៏ឡើងសម្រេចចិត្តទៀត ឡើងសម្រេចចិត្តបន្តៗគ្រប់ប្រាំគូ។ ហើយបានកម្មវិធីហ្នឹងគេបញ្ចប់ទៅ ហើយមានការហូបបាយហូបទឹកអី គេហៅថា មានមាន់មានអី មានមាន់ស្ងោ មានបាយសម្លអីស្រួលបួលពេលហ្នឹងឯង។

**ស៖** លោកនិយាយអំពីពិធីរៀបការ។ លោកអាចនិយាយពីរបៀបដែលបុរសនិងស្ត្រីគេរកឃើញគ្នា ស្គាល់គ្នាដោយរបៀបម៉េចពីឃុំមួយទៅឃុំមួយ តើគេចង់និយាយថាតើគេនាំគូស្រករហ្នឹងឲ្យស្គាល់គ្នា ជួបគ្នាដោយរបៀបម៉េច?

**ឆ៖** ភាគច្រើនមិនៗមានឆ្លងឃុំទេ។ មិនមានឆ្លងពីឃុំមួយទៅឃុំមួយទេ គឺនៅក្នុងឃុំជាមួយគ្នា ប៉ុន្តែអាចភូមិខុសគ្នាដែរ ពីព្រោះកងចល័តយុវជន និង យុវនារីវាធ្វើការជាមួយគ្នា ការដ្ឋានជាមួយគ្នា ឃើញគ្នារាល់ថ្ងៃ។ ឯខ្ញុំមានការរៀបចំមួយនៅខាងឃុំលាយបូរ ខាងក្រុមអ្នកបរឡានខាងតំបន់មកស្នើខាងនារីកងចល័តលាយបូរ។ ដូច្នេះវាៗខុសគ្នាដែរ ពីមន្ទីរមកស្នើកងចល័តលាយបូរ។ គេបានឃើញគ្នា គេពេញចិត្តនឹងគ្នា ហើយក៏យើងសម្រេចតាមការស្នើរបស់សាមីខ្លួនខាងប្រុសទៅ ហើយបានការរៀបចំ ដូចខ្ញុំរៀបរាប់ពីពិធីរៀបចំអីចឹងទៅ ដូចបានជូនជ្រាប លោកជ្រាបមុនហ្នឹង តែគ្មានភ្លេងភ្លាត់ អាចារ្យអីៗ គឺគ្មានទេ អត់ទេ។

[១១:៣២:០៥]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំទៅលើប្រធានបទនេះមុនពេលឈប់សម្រាកបាយថ្ងៃត្រង់។ តើលោកនៅចាំ ឬក៏នឹកឃើញពីហេតុការណ៍ណាមួយដែលស្ត្រីណាម្នាក់មិនស្រឡាញ់អនាគតប្តីរបស់ខ្លួន ហើយត្រូវបានបានគេបង្ខំឲ្យរៀបការដែរទេ?

**ឆ៖** ខ្ញុំមានឃើញព្រឹត្តិការណ៍នេះមួយនៅលាយបូរ ខាងអ្នកបរឡាន ខាងតំបន់១៣ មកការជាមួយនឹងនារីកងចល័តលាយបូរ។ រៀបចំការហើយរស់នៅជាមួយគ្នាបួនដប់ថ្ងៃទៅ នារីក៏ប្រកែកៗមិនព្រមយកគូហ្នឹង។ ការប្រកែកនេះ ខាងប្រធានឃុំមិនមានប្រតិកម្មអីទេនៅអីចឹងសិនទៅ ប្រកែករស់នៅដាច់ពីគ្នាសិនទៅ ហើយក៏គេខំអប់រំ។ នារីគេខំអប់រំខាងនារី យុវជនគេខំអប់រំខាងយុវជនហ្នឹងទៅ ថ្ងៃក្រោយទៅរស់នៅមូលគ្នាបាន។ អាហ្នឹងមានអីចឹង។ តែមានមួយគូទៀតរៀបចំអីចឹងដែរ ស្រឡាញ់គ្នាអីចឹងទៅបានប្រហែលជាមួយខែក៏សុំបែក។ សុំបែកអីចឹងទៅ បែកគ្នារាប់ឆ្នាំ ដល់ឆ្នាំដែលវៀតណាមចូលមកកម្ពុជាប្តីរត់ចូលព្រៃទៅ រត់ទៅព្រំដែន ដល់ព្រំដែន។ ទៅដល់ព្រំដែនកុហកគេថាគ្រួសារគាត់ស្លាប់ហើយគាត់កប់នឹងខ្លួនគាត់ តែ បូរាណ ដែលជាកូនប្រសាតាម៉ុក ប្រធានកងដឹកជញ្ជូនមិនព្រម ហើយអ្នកនាំសុំរៀបការថ្មីទៀត ប៉ុន្តែគេមិនព្រមទេ គេសួរមកខាងខ្ញុំនៅភ្នំដំរីរមៀលនេះ “ថាតើប្រពន្ធគាត់នៅអត់? ខ្ញុំឆ្លើយថា នៅ”។ ដូច្នេះ គេសម្រេចចិត្តឲ្យខ្ញុំយកប្រពន្ធហ្នឹងទៅឲ្យ ហើយក៏សម្រេចឲ្យយុវជនហ្នឹងមកយកវិញ មកយកបានទៅរស់នៅជាមួយគ្នាបានកូនបួន។ មុនចប់សង្គ្រាមជាមួយរដ្ឋាភិបាលបច្ចុប្បន្ននេះម្នាក់ហ្នឹងក៏រត់ចោលប្តីមករហូត។ អីចឹងវាព្រឹត្តិការណ៍ហ្នឹងវាមានអីចឹង។ ហ្នឹងខ្ញុំជួបព្រឹត្តិការណ៍ពីរហ្នឹង។

[១១:៣៤:៥៧]

**ស៖** សំណួរចុងក្រោយលោកសាក្សី លោកថាលោកជួបតែហេតុការណ៍ពីរហ្នឹងទេ។ តើមានស្ត្រីណាម្នាក់ក្នុងហេតុការណ៍ពីរនេះត្រូវបានគេដាក់ទណ្ឌកម្ម ឬក៏ជួបប្រទះបញ្ហាដោយសារតែខ្លួនប្រកែកហ្នឹងដែរទេ?

**ឆ៖** អត់មានទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ នៅក្នុងពេលអំឡុងសម្រាកថ្ងៃត្រង់ និងបង្គាប់ឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សារបស់គាត់ មកកាន់កន្លែងផ្តល់សាក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយ និងសាមសិបនាទីរសៀលនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន ទៅកាន់បន្ទប់សម្រាកខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៦ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៥១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ ពាក់ព័ន្ធទៅនឹងសំណើកាលពីព្រឹកនេះ គឺជាសំណើដែលស្នើឡើងដោយព្រះរាជអាជ្ញា។ ប្រាកដណាស់ថាសាក្សីនេះ គឺពិតជាមានភាពពាក់ព័ន្ធ។ ដូច្នេះ យើងគួរតែកំណត់កាលបរិច្ឆេទរបស់គាត់ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ហើយខ្ញុំគិតថាសាក្សីរូបនោះប្រហែលជាមានភស្តុតាងយ៉ាងច្រើន ដែលរៀបរាប់អំពីសកម្មភាពនៅកម្រិតថ្នាក់តំបន់។ ដូច្នេះចំពោះយើង គឺយើងមិនជំទាស់ក្នុងការស្នើសុំឱ្យកំណត់កាលបរិច្ឆេទសាក្សីហ្នឹងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាននោះឡើយ។ ជាបន្តទៅទៀតនេះខ្ញុំសូមធ្វើការសាកសួរសាក្សីជាបន្ត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី មុនពេលដែលយើងឈប់សម្រាកអាហារថ្ងៃត្រង់ ខ្ញុំបានអានជូនលោកនូវសម្រង់មួយចំនួននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលលោកដឹងហើយថាខ្ញុំនិយាយអំពីអ្នកណា។ ឥឡូវនេះ ខ្ញុំចង់សួរសំណួរពីរបីបន្ថែមទៀត ពាក់ព័ន្ធទៅនឹងចម្លើយដែលគាត់បានផ្តល់ឱ្យ ជាពិសេសខ្ញុំចង់អាននូវចម្លើយ១៤១។ ហើយខ្ញុំនឹងស្នើសុំឱ្យលោក បង្ហាញនូវការយល់ឃើញរបស់លោក។ លោកសាក្សីគេថាអ្នកស៊ើបអង្កេតបានសួរគាត់ដូចតទៅនេះ៖ "តើលោកស្រីមានសិទ្ធិតែងតាំង និងបណ្តេញប្រធានសហករណ៍ដែលឬទេ? ឆ្លើយ៖ មានការបោះឆ្នោតជ្រើសរើសប្រធានសហករណ៍នៅក្នុងភូមិដែលរកអ្នកណាដែលល្អនៅក្នុងភូមិ។ បន្ទាប់ពីប្រជាជនក្នុងភូមិយល់ព្រមហើយទើបខ្ញុំតែងតាំង។ បើប្រធានសហករណ៍ណាដែលមិនល្អ ស៊ីលើសស៊ីខ្វះអី គឺខ្ញុំមានសិទ្ធិដកចេញ ហើយឱ្យទៅជាប្រជាជនធម្មតាវិញ។ បន្ទាប់ពីជ្រើសរើសប្រធានសហករណ៍ថ្មីចេញពីប្រជាជនធម្មតាដដែល។ សំណួរ៖ ប្រសិនបើប្រធានសហករណ៍ធ្វើមិនល្អ តើប្រធានសហករណ៍នោះអាចត្រូវចាប់ខ្លួន ឬក៏កសាងអប់រំដែរឬទេ? ចម្លើយ៖ ចំពោះមេសហករណ៍ គឺអត់ទេ ប៉ុន្តែបើប្រជាជនអាចត្រូវគេចាប់ខ្លួន។ បើមេសហករណ៍ណាដែលមិនល្អ មិនស្មោះត្រង់ យើងនឹងដកចេញ ហើយធ្វើ -- ហើយឱ្យធ្វើជាប្រជាជនធម្មតា គឺធ្វើការដូចជាជីកឧស ជីកបន្លែជាដើម"។ អ្វីដែលខ្ញុំចង់សួរលោក គឺថាតើលោកយល់យ៉ាងដូចម្តេចដែរចំពោះសម្រង់ដែលបានដកចេញពីសាក្សីមួយនេះ តើលោកយល់ស្របជាមួយនឹងអ្វីដែលសាក្សីនេះបាននិយាយដែរឬទេ?

[១៣:៣៧:៤២]

**លោក នាង អ៊ូច៖**

**ឆ៖** បញ្ហានេះខ្ញុំមិនដែលបានជួបរឿងដក រឿងដូរអីទេ អត់ៗអត់មានបានជួបទេ។

**ស៖** ដូច្នេះខ្ញុំចង់សួរបន្តទៅទៀត ទាក់ទងទៅនឹងពាក្យថា "មេភូមិមិនល្អ មិនៗស៊ីវីល័យ"។ តើលោកស្តាប់ពាក្យហ្នឹងទៅលោកយល់ឃើញយ៉ាងដូចម្តេចដែរ ដែលៗនិយាយថា "មិនល្អ ស៊ីលើស ស៊ីខ្វះ" អីហ្នឹង។ តើលោកយល់យ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំៗន៎ ពាក្យនេះខ្ញុំពិបាកឆ្លើយ ព្រោះព្រឹត្តការណ៍វាកើតចំៗកន្លែងណាដែលខ្ញុំវាអត់ដឹង។ ដឹងថាស៊ីលើស ស៊ីខ្វះ មិនល្អ វាមិនដឹងកើតត្រង់សហករណ៍ណា ឬភូមិណា។

**ស៖** តើលោកចាំដែរឬទេ? ឧទាហរណ៍ថាដូចជាក្នុងទស្សនាវដ្តីទង់បដិវត្ត មានការណែនាំដែលជាការណែនាំទៅដល់កម្មាភិបាលអំពីអកប្បកិរិយាដែលត្រូវប្រព្រឹត្តជាមួយប្រជាជន។ តើមានការណែនាំបែបនេះដែរឬទេ?

**ឆ៖** ទង់បដិវត្ត ខ្ញុំបានឃើញដែរ តែខ្ញុំ -- សំណួរនេះ ដូចខ្ញុំភ្លេចអស់ហើយ មិនដឹងជាបានណែនាំ ឬមិនបានណែនាំទេ។ ខ្ញុំមិនចាំទេវាសាមសិបប្លាយឆ្នាំទៅហើយ។ តែក្នុងវគ្គរៀនសូត្រ មានណែនាំមានការណែនាំឲ្យកម្មាភិបាលធ្វើល្អជាមួយប្រជាជន ខំដោះស្រាយស្បៀង ខំដោះស្រាយឲ្យជម្រករស់នៅ។ ហ្នឹងមានការណែនាំក្នុងការរៀនសូត្រនៅភូមិភាគ នៅតំបន់ ឬក៏មករៀននៅភ្នំពេញ។

**ស៖** តើលោកចាំដែរឬទេថា គោលនយោបាយជាទូទៅ គឺដាក់ទណ្ឌកម្ម ឬក៏ធ្វើទារុណកម្មចំពោះកម្មាភិបាលដែលធ្វើសកម្មភាពមិនល្អជាមួយប្រជាជន។ តើមានគោលនយោបាយបែបនេះដែរឬទេ?

**ឆ៖** ខ្ញុំមិនចាំ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងឈានទៅប្រធានបទថ្មីមួយអំពីបញ្ហាមួយផ្សេងទៀត។ ប្រធានបទនេះត្រូវបានពិភាក្សារួចទៅហើយនៅពេលកន្លងមក ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំនឹងពិភាក្សាសាជាថ្មីម្តងទៀត ហើយនេះគឺជាចម្លើយរបស់គាត់ទៅនឹងសំណួរ១៧៧ និង១៧៨ ព្រមទាំង១៥១ និង១៥២។ ដូច្នេះខ្ញុំនឹងអាននូវសម្រង់នេះ៖ "ខ្ញុំឃើញថា--

**ប្រធានអង្គជំនុំ៖**

អត់មានទេ? អត់មានឯកសារ?

**លោក មឿន សុវណ្ណ៖**

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីយកជូនសាក្សីពិនិត្យ!

[១៣:៤២:២៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គឺ១៤៧ ខ្ញុំចង់សួរសំណួរ១៤៧។ លោកសាក្សី នេះគឺជាប្រធានបទដែលយើងពិភាក្សាគ្នារួចមកហើយ ប៉ុន្តែខ្ញុំចង់ដកស្រង់បន្ថែម។ "សំណួរ៤៧៖ តើបទល្មើសប្រភេទណាជាបទល្មើស ហើយប្រភេទណាជាបទល្មើសកម្រិតធ្ងន់? ឆ្លើយ៖ បទល្មើសស្រាល ដូចខ្ញុំនិយាយអំពីប្រធានសហករណ៍ដែលលួចលាក់របបហូបបន្តិចបន្តួច គឺមិនអីទេ។ អ្នកដែលលួចចានឆ្នាំង ដែលប្រមូលយកទៅទុក ក៏ត្រូវគេចាត់ទុកថាបទល្មើសស្រាលដែរ។ ប៉ុន្តែចំពោះអ្នកដែលបំផ្លិចបំផ្លាញសម្ភារៈផ្សេងៗ ឬក៏ដើរបំផុសបំផុលឲ្យនិយាយប៉ះពាល់ដល់អង្គការ ឬក៏ប្រឆាំងនឹងអង្គការ ឬក៏មានឧបាយកលអ្វីផ្សេងៗនោះត្រូវគេកំណត់ថាបទល្មើសធ្ងន់។ ការចាប់រំលោភប្រពន្ធអ្នកដទៃ ក៏ត្រូវចាត់ទុកថាជាបទល្មើសធ្ងន់ដែរ ព្រោះអ្នកទាំងអស់ត្រូវគេចាប់ខ្លួន និងបញ្ជូនទៅអប់រំ។ ទាំងអស់គឺខ្ញុំនិយាយតែនៅក្នុងមូលដ្ឋានដែលខ្ញុំគ្រប់គ្រងទាំងអស់។ សំណួរ៖ នៅសម័យនោះ គឺអ្វីៗជារបស់សមូហភាពដែលប្រឆាំងនឹងកម្មសិទ្ធិឯកជន ការលួចសម្ភារៈ ឬក៏លួចរបស់អ្វីហូបបន្តិចបន្តួចគឺជាបទល្មើសស្រាល។ តើសកម្មភាពជាសកម្មភាពប្រឆាំងនឹងបដិវត្តន៍ដែរឬទេ? ឆ្លើយ៖ ខ្ញុំសូមជម្រាបថា ទី១ ការលួចដោយសារការស្រេកឃ្លាននោះ ជាបទល្មើសស្រាល។ ទី២ លួចញឹកញាប់ និងមានកម្រិតខ្ពស់ជាងទី១ នោះថ្នាក់ក្រោមនឹងរាយការណ៍មកដល់ខ្ញុំ"។

[១៣:៤៤:២៥]

ហើយសំណួរបន្តទៀត គឺ១៥១ គឺសំណួរដូចតទៅនេះ៖ "គឺថាមានបញ្ជាក់ប្រភេទពីរ បទល្មើសស្រាល និងធ្ងន់ ហើយក្នុងបទល្មើសធ្ងន់ មានការរំលោភសេពសន្ថវៈ។ ចំពោះទណ្ឌកម្ម តើអ្នករំលោភគេត្រូវដាក់ទណ្ឌកម្មដូចម្តេច? ឆ្លើយ១៥១៖ អ្នកដែលរងគ្រោះពុំត្រូវគេដាក់ទណ្ឌកម្មនោះទេ គឺដាក់តែអ្នកដែលរំលោភគេប៉ុណ្ណោះ។ សំណួរ៖ ពេលយើងនិយាយអំពីពាក្យរំលោភ តើជាការបង្ខំឲ្យអ្នកណាម្នាក់រួមភេទដោយប្រើអំពើហិង្សា។ តើលោកស្រីចង់និយាយដូច្នេះមែនទេ? ឆ្លើយ៖ ចាស បើករណីដែលបុរសចាប់រំលោភស្ត្រី ហើយស្ត្រីនោះមិនព្រមនោះ បុរសនឹងត្រូវគេដាក់ទណ្ឌកម្ម។ ចំណែកស្ត្រី គឺពុំ

ដាក់ទោសនោះទេ"។ លោកសាក្សី ជាដំបូងខ្ញុំចង់សួរថាតើលោកយល់ស្របជាមួយនឹងការដកស្រង់អំពីចម្លើយរបស់សាក្សីនេះដែរឬទេ?

**លោក នាង អ៊ួច៖**

**ឆ៖** ខ្ញុំ ចំពោះការដកស្រង់នេះគឺខ្ញុំៗយល់ស្រប។

**ស៖** ដើម្បីឲ្យជាក់ច្បាស់ជាងនេះទៀត នៅពេលដែលគាត់និយាយថា លួចដោយសារការស្រេកឃ្លាន តើលោកយល់ស្របពីចំណុចនេះដែរឬទេ?

**ឆ៖** នោះជាបទល្មើសស្រាល។

**ស៖** តើការរំលោភ គេតែងតែចាត់ទុកការរំលោភ ជាបទល្មើសធ្ងន់ធ្ងរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ការៗចាប់រំលោភដោយបង្ខិតបង្ខំដែលស្ត្រី ឬនារីមិនព្រម អាហ្នឹងជាបទល្មោភ -- ល្មើសបទល្មើសធ្ងន់ហើយ។

[១៣:៤៧:១៤]

**ស៖** តាមដែលលោកចាំ តើអ្នកប្រព្រឹត្តការ -- អំពើរំលោភផ្លូវភេទនុងត្រូវបានគេចាប់ខ្លួន? តើអ្នកត្រូវបានរំលោភគេហ្នឹងត្រូវបានគេចាប់ខ្លួនដែរឬទេក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** មានៗការចាប់ខ្លួន ហើយមានការអប់រំតាមកម្រិត។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទថ្មី គឺជាចម្លើយផ្ទាល់របស់លោកតែម្តង។ លោកប្រធាន ខ្ញុំសូមបង្ហាញឯកសារ E319.1.15។ សំណួរៗ១០៣ ដល់ ១០៥ -- ១០៣ ដល់១០៧។ ដូច្នេះ ក្នុងពេលជាមួយគ្នានេះ ខ្ញុំចង់ឲ្យលោកពិនិត្យមើលទៅលើឯកសារនេះផងដែរ គឺសំណួរ១០៣ ដល់១០៧។

**លោក មឿន សុវណ្ណ៖**

លោកប្រធាន ឯកសារនេះ មានអត់គ្រប់ នៅខ្វះៗទំព័រ។ ដូច្នេះ ស្នើសុំថ្មីមួយទៀតមក សម្រាប់គាត់ដើម្បីមើល។

**ប្រធានអង្គជំនុំ៖**

[១៣:៤៩:២០]

លោកៗ វ៉ិចទ័រ កូប៉េ អាចផ្តល់ថ្មីបានទេ -- អានោះ ទំព័រអត់គ្រប់ អត់គ្រប់ទំព័រណា។

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន ខ្ញុំគិតថានេះជាចម្លើយរបស់គាត់។ ដូច្នេះខ្ញុំគិតថាគាត់គួរតែមាន ព្រោះថាកាលពីម្សិលមិញ ក៏ដូចជាថ្ងៃកន្លងមក យើងបាននិយាយយោងទៅលើឯកសារនេះច្រើនដងរួចមកហើយ គឺ E319.1.15 ។

**ប្រធានអង្គជំនុំ៖**

លោកមន្ត្រីរដ្ឋបាលតុលាការពិនិត្យមើលឯកសារនៅចំពោះមុខ នៅពីមុខមេធាវី រួមជាមួយមេធាវីមើល តើវាមានដូចមេធាវីបានលើកឡើងទេ?

បាទៗ មើលអាថ្មីៗ ព្រោះអាមុនវាថាវាអត់គ្រប់ៗទំព័រ។

**លោក វ៉ិចទ័រ កូប៉េះ**

លោកមេធាវី គឺសំណួរទី១០៣ ដល់ ១០៧។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោកសាក្សីសំណួរ-ចម្លើយនៅត្រង់ចំណុចនេះ គឺនិយាយអំពី តាស៊ី ឬក៏ ជូ ជេត។ តើលោកអាចប្រាប់តុលាការបានដែរឬទេ ថាតើលោកចាំអ្វីខ្លះទាក់ទងទៅនឹងតាស៊ី ឬក៏ ជូ ជេត នោះ?

**លោក នាង អ៊ួច៖**

**ឆ៖** ខ្ញុំចាំ។ ឆ្នាំ១៩៧០ អង្គការរណសិរ្សរួបរួមជាតិបានចាត់តាំងខ្ញុំឲ្យធ្វើជាសមាជិករណសិរ្សនៅស្រុកត្រាំកក់។ មិនៗបានប៉ុន្មានខែផងក៏ -- ខ្ញុំមិនចាំទេ តែៗមិនដឹងបានប៉ុន្មានខែទេ -- ក៏មានការហៅខ្ញុំឲ្យទៅភ្នំពីស ខាងជើងផ្លូវជាតិលេខ៤ ក្នុងខេត្តកំពង់ស្ពឺ។ ហើយនៅទីនោះ ខ្ញុំបានជួប តាស៊ី។ ចេញពីត្រាំកក់ទៅភ្នំពីស ហើយរស់នៅភ្នំពីស៦-៧ថ្ងៃ បានជួប តាស៊ី – តាស៊ីឲ្យប្រាប់ខ្ញុំឲ្យទទួលការងារជាអ្នកទទួលខុសត្រូវអប់រំខាងបង្រៀនអក្សរនៅខេត្តតាកែវ ខេត្តកំពត និងខេត្តកំពង់ស្ពឺ ដោយចេញលិខិតឧទ្ទេសនាមមួយឲ្យ។ ហើយខ្ញុំវិលត្រឡប់មកខេត្តតាកែវ មកស្រុកត្រាំកក់។ រយៈពេលទៅនិងរស់នៅភ្នំពីស និងមកដល់ៗត្រាំកក់វិញគឺរយៈពេល១ខែ។ មកដល់ត្រាំកក់ ក៏ខ្ញុំចាប់ផ្ដើមឈឺគ្រុនរហូត៦ខែ។ ខ្ញុំជម្រាបប៉ុណ្ណឹង។

[១៣:៥២:៣៣]

**ស៖** តើលោកស្គាល់តាស៊ីច្បាស់កម្រិតណាដែរ? តើលោកធ្លាប់ជជែកពិភាក្សាជាមួយគាត់ ឬក៏ធ្លាប់ជួបជាមួយគាត់ញឹកញាប់ដែរឬទេ? តើលោកអាចជម្រាបឲ្យបានលម្អិតបន្ថែមបន្តិចរវាងទំនាក់

ទំនងលោកជាមួយនឹង តាស៊ី ឲ្យបានលម្អិតដែរទេ?

**ឆ៖** ខ្ញុំមិនបានជួបគាត់ញឹកញាប់ទេ។ ខ្ញុំបានជួបម្តងហ្នឹង ហើយខ្ញុំមកខាងត្រាំកក់វិញ ក៏អត់ដែលបានជួបគាត់សោះ។ ដូច្នេះ ខ្ញុំអត់បានដឹងរឿងរ៉ាវអីរបស់គាត់ទេ អត់ទេ។

**ស៖** តើលោកដឹងថា ជូ ជេត មានគោលជំហរបែបណាដែរចំពោះវៀតណាម?

**ឆ៖** ខ្ញុំអត់ដឹង។

**ស៖** តើលោកដឹងថា ជូ ជេត ឬក៏តាស៊ី មានទំនាក់ទំនងយ៉ាងដូចម្តេចដែរជាមួយ តាម៉ុក?

**ឆ៖** តាស៊ី និង តាម៉ុក នៅក្នុងគណៈភូមិភាគតែមួយ ដូច្នេះជាគណៈភូមិភាគជាមួយគ្នា។

**ស៖** តើលោកចាំដែរឬទេថាតើ តាស៊ី ក្លាយទៅជាប្រធានភូមិភាគបស្ចិមនៅពេលណាដែរ?

**ឆ៖** ខ្ញុំអត់ចាំទេ។

**ស៖** តើលោកស្គាល់ប្រពន្ធរបស់ ជូ ជេត ឈ្មោះ អ៊ឹម ណា ដែរឬទេ?

**ឆ៖** អត់ស្គាល់ឈ្មោះ អ៊ឹម ណា ទេតែមានប្រពន្ធគាត់មានឈ្មោះ យាយខ្ចីៗ ទេមិនដឹង។ ឈ្មោះហៅថា យាយខ្ចី។

**ស៖** អ៊ីចឹង អ៊ឹម ណា ហ្នឹងជាឈ្មោះរបស់ប្រពន្ធ ជូ ជេត ឬក៏ម៉េចដែរ?

[១៣:៥៦:៣២]

**ឆ៖** ខ្ញុំៗអត់ដឹង ខ្ញុំអត់ស្គាល់ អ៊ឹម ណា។ តែប្រពន្ធលោក តាស៊ី គេហៅថា យាយខ្ចីៗ។

**ស៖** ខ្ញុំគិតថាប្រហែលជាមួយជាឈ្មោះបក្ស មួយទៀតជាឈ្មោះទូទៅ តើអ៊ីចឹងមែនទេឬក៏យ៉ាងម៉េចដែរ? មួយជាឈ្មោះបដិវត្តន៍ មួយទៀតជាឈ្មោះទូទៅ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បញ្ហានេះខ្ញុំមិនៗដឹងទេ។

**ស៖** តើលោកដឹងថា មានអ្វីកើតឡើងចំពោះ ជូ ជេត ក្នុងឆ្នាំ៧៨?

**ឆ៖** ក្នុងឆ្នាំ៧៨ ខ្ញុំគិតថាប្រហែលជា តាស៊ី នេះក្លាយទៅជាប្រធានភូមិភាគបស្ចិមទៅហើយ។ ហើយពីភូមិភាគបស្ចិមមកខ្ញុំ ៧៨ខ្ញុំនៅត្រាំកក់ ឆ្ងាយគ្នាណាស់ ខ្ញុំអត់បានដឹងដំណឹងហ្នឹងអីទេ ហើយលោកក៏ជ្រាបដែរ សម័យៗកម្ពុជាប្រជាធិបតេយ្យនោះគ្មានទូរស័ព្ទ គ្មានតេអូ ហើយគ្មានវិទ្យុផ្សាយពីរឿងអស់ហ្នឹងទេ អត់ទេ។ ដូច្នេះ ខ្ញុំអត់ដឹង។

**ស៖** ប្រហែលជាខ្ញុំអាចជួយរំឭកលោកបាន។ គឺថា ជូ ជេត ត្រូវបានគេសម្លាប់នៅខែឧសភា ឆ្នាំ៧៨។

**ឆ៖** ខ្ញុំអត់ដឹង។

**ស៖** អ៊ីចឹងលោកអត់ដឹងអ្វីទាំងអស់អំពី ជូ ជេត អ៊ីចឹងលោកចង់និយាយអ៊ីចឹងមែនទេ? លោកអត់ដឹងអំពីជោគវាសនារបស់ ជូ ជេត ទាល់តែសោះអ៊ីចឹងមែនទេ?

**ឆ៖** លោកៗមេធាវីឲ្យខ្ញុំដឹងយ៉ាងម៉េចបើគាត់នៅភូមិភាគបស្ចិម ហើយខ្ញុំនៅខាងត្រាំកក់ តាកែវ វាឆ្ងាយគ្នាណាស់។ ហើយខ្ញុំបញ្ជាក់ហើយថាវាគ្មានៗទូរស័ព្ទ គ្មានទូរទស្សន៍ គ្មានអីដែលផ្សព្វផ្សាយពីរឿងអស់ហ្នឹងទេ។ ឲ្យខ្ញុំដឹងយ៉ាងម៉េច បើខ្ញុំតូចតាចអ៊ីចឹង។

[១៤:00:00]

**ស៖** អ៊ីចឹងក្រោយឆ្នាំ៧៩ តើលោកធ្លាប់ដឹងអំពីជោគវាសនារបស់ ជូ ជេត ដែលត្រូវបានគេបញ្ជូនមក ស-២១ ដែរឬទេ? តើលោកមានដឹងអំពីព័ត៌មានហ្នឹងដែរឬទេ?

**ឆ៖** ក្រោយឆ្នាំ១៩៧៩ ខ្ញុំរត់ចូលព្រៃភ្នំអស់ហើយ មានបានព័ត៌មានអីពីណា។

**ស៖** ខ្ញុំនឹងផ្តល់ឈ្មោះមួយចំនួនដល់លោកគឺមកពីតំបន់១៥ ហើយខ្ញុំនឹងសួរលោកថាតើលោកស្គាល់ ឬក៏អាចដឹងអំពីទំនាក់ទំនងរវាងបុគ្គលទាំងអស់នេះជាមួយ ជូ ជេត ដែរឬទេ? ទី១ គឺឈ្មោះ សុង -- គឺឈ្មោះ សោម គឺជាលេខាតំបន់១៣។ តើលោកដឹងដែរឬទេថា សោម មានទំនាក់ទំនងអ្វីជាមួយ ជូ ជេត?

**ឆ៖** ខ្ញុំអត់បានដឹងការទំនាក់ទំនងរវាង តាសោម លេខាតំបន់១៣ ជាមួយ ជូ ជេត ទេ។ ហើយខ្ញុំជួប តាសោម ចុងក្រោយគឺនៅពេទ្យរុស្ស៊ីរាល់ថ្ងៃហ្នឹង នៅក្នុងពេលដែលខ្ញុំរបួសក្បាលជង្គង់ឆ្វេង ទៅដេកពេទ្យ៣ខែ។ ហើយគាត់ គាត់មានជំងឺរបេងស្ងួត គឺជួបគាត់នៅត្រង់ហ្នឹងហើយ ខ្ញុំវិលត្រឡប់ទៅវិញទៅគឺលែងជួបរហូត លែងបានដំណឹងគាត់រហូត។

[១៤:0២:0៨]

**ស៖** តើលោកដឹងថា មានទំនាក់ទំនងអ្វីរវាង ជូ ជេត និង តាគារ ដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹង។

**ស៖** តើលោកដឹងថា ជូ ជេត មានទំនាក់ទំនងអ្វីដែរជាមួយ មឿន?

**ឆ៖** មឿន នេះ – មឿន នេះ ខ្ញុំអត់ស្គាល់ផង។

**ស៖** មឿន គឺជាប្អូនប្រុសរបស់ នារីពៅ តើលោកចាំទេ?

**ឆ៖** នារីពៅ នេះក៏ខ្ញុំអត់ស្គាល់។

**ស៖** តើលោកដឹងថា ជូ ជេត មានទំនាក់ទំនងអ្វីជាមួយ ផែន ជាអនុលេខាតំបន់១៣ ដែរឬទេ?

**ឆ៖** ផែន – បងផែនខ្ញុំស្គាល់។ ប៉ុន្តែទំនាក់ទំនងគ្នារវាងបងផែន ហើយជូ ជេត ខ្ញុំអត់បានដឹងទេ។

**ស៖** ខ្ញុំបាននិយាយអំពីឈ្មោះ តាគាវ, មឿន, សោម, ផែន។ តើលោកដឹងថាមានអ្វីកើតឡើងចំពោះមនុស្សបីបួននាក់ដែលខ្ញុំនិយាយនេះទេ នៅក្នុងរបបខ្មែរក្រហមនោះ?

**ឆ៖** ទី១ មឿន នេះ ខ្ញុំមិនស្គាល់ទេ។ ខ្ញុំមិនស្គាល់ មឿន ពិតប្រាកដមែន។ ហើយ គាវ នេះ ខ្ញុំស្គាល់គាត់ ហើយក៏ខ្ញុំឃើញគាត់ធ្វើការនៅស្រុកត្រាំកក់ ពេលឆ្នាំ៧០ (១៩៧០) មាឌគាត់ល្អិត ធ្វើការជាមួយ ខុម។ ហើយខ្ញុំទៅស្រុកកោះអណ្តែតទៅក៏ខ្ញុំលែងដឹងរឿងគាត់។

[១៤:០៥:00]

**ស៖** តាមដែលលោកចាំ តើមនុស្សប៉ុន្មាននាក់ដែលខ្ញុំបង្ហាញឈ្មោះហ្នឹង តើលោកចាំថាពួកគាត់ត្រូវគេចាប់ខ្លួន ដោយចោទថាជាជនក្បត់។ តើលោកដឹងទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ ហើយ បងផែន ជាអនុតំបន់១៣នេះ គឺគាត់រត់ចូលព្រៃឆ្នាំ៧៩ មកស្លាប់នៅភ្នំក្នុងខេត្តកំពត។ ខ្ញុំថែមទាំងបានបញ្ចុះសពគាត់ទៀត។ ស្លាប់ដោយជំងឺ។

**ស៖** អ៊ីចឹងមានន័យថាលោកក៏លោកអត់ដឹងថា -- អ៊ីចឹងបានន័យថាលោកអត់ដឹងថាមនុស្សបួននាក់ហ្នឹងគាត់មានខ្សែរយៈអីទំនាក់ទំនងជាមួយ ជូ ជេត ទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។ អត់ដឹងថាមនុស្សបួននាក់ហ្នឹងទំនាក់ទំនង មានការទាក់ទងអីជាមួយ ជូ ជេត ទេ។ ដោយឡែកឈ្មោះ មឿន គឺខ្ញុំមិនស្គាល់តែម្តង។ តាគាវ ខ្ញុំស្គាល់ ហើយបងផែន ជាអនុតំបន់១៣ ខ្ញុំស្គាល់ ព្រោះខ្ញុំទៅរស់នៅស្រុកកោះអណ្តែត គឺជាមួយគាត់ ហើយដល់វៀតណាមចូលឈ្លានពានកម្ពុជាទៅ គាត់រត់ចូលភ្នំ ហើយគាត់ក៏ទៅស្លាប់នៅភ្នំខាងលិចស្ទឹងភេ ក្នុងខេត្តកំពត។ ខ្ញុំបានបញ្ចុះសពគាត់។

[១៤:០៧:00]

**លោក វ៉ិចទ័រ កូប៉េ៖**

ឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទថ្មី ហើយខ្ញុំនឹងប្រើប្រាស់នូវវិធីសាស្ត្រដូចគ្នា គឺប្រើប្រាស់ចម្លើយរបស់ស្ត្រីសាក្សីម្នាក់ ហើយខ្ញុំនឹងអាននូវចម្លើយមួយចំនួនរបស់សាក្សីនេះ គឺឯកសារ E313.1.18។ សូមការអនុញ្ញាតពីលោកប្រធាន ហើយខ្ញុំមើលទៅលើ ហើយខ្ញុំមើលទៅមេធាវីប្រឹក្សាឃើញថា ឯកសារ E313.1.18។

**ប្រធានអង្គជំនុំ៖**

រកឃើញនៅលោកមេធាវី?

អត់ៗមានទេ?

លោកមេធាវីគាត់អត់មានទេ ផ្ដល់ឯកសារជាភាសាខ្មែរឲ្យគាត់។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងផ្ដល់ជូនទៅក្នុងពេលនេះ។ ខ្ញុំសូមសួរសំណួរខ្ញុំសិន ហើយខ្ញុំនឹងអានសំណួរនិងចម្លើយជូនទៅសាក្សី។ ខ្ញុំសួរ អានសំណួរ-ចម្លើយយឺតៗទេ ដើម្បីឲ្យគាត់តាមទាន់។ ខ្ញុំមិនដឹងថាតើខ្ញុំអាចនិយាយឈ្មោះសាក្សីបាន ឬក៏អត់នោះទេ។

**ប្រធានអង្គជំនុំ៖**

ឲ្យលោកសរសេរជាក្រដាសក៏បានដែរ។ សរសេរឈ្មោះសាក្សីជាក្រដាសហើយយកជូនឲ្យមន្ត្រីច្បាប់យកជូនគាត់ យកជូនសាក្សី។ នេះជាវិធីសាស្ត្រមួយដែរដើម្បីអាចលាក់នូវអត្តសញ្ញាណសាក្សីបាន ព្រោះកុំឲ្យ -- លាក់ការការសម្ងាត់តាមសំណើសុំរបស់សហចៅក្រមស៊ើបអង្កេត។

[១៤:១១:00]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នេះគឺជាសាក្សីកំពុងតែនិយាយ។ លោកសាក្សីនៅក្នុងសំណួរចម្លើយលេខ៥៧ អ្នកស៊ើបអង្កេតបានសួរទៅលើសាក្សីរូបនេះ នូវសំណួរដូចតទៅនេះ៖ "តាមលោកដឹងតើ តាម៉ុក ទទួលបញ្ជាផ្ទាល់ពី ប៉ុល ពត ឬក៏ទទួលបញ្ជាផ្ទាល់ពី សុន សេន ហៅបង៨៩ ដែលជានាយអគ្គសេនាធិការដែរឬទេ? ឆ្លើយ៖ តាម៉ុក ទទួលបញ្ជាផ្ទាល់ពីប៉ុល ពត។ សំណួរ៖ តើលោកសំអាងអ្វីដែលនាំឲ្យជឿថា តាម៉ុក ទទួលបញ្ជាផ្ទាល់ពី ប៉ុល ពត។ ឆ្លើយ៖ ព្រោះតាម៉ុក ជាមនុស្សបន្ទាប់ពី ប៉ុល ពត។ រូបភាពចាត់តាំងទី១ ប៉ុល ពត, ទី២ នួន ជា ហើយទី៣ គឺ តាម៉ុក។ ប៉ុន្តែពេលដែលទទួលបញ្ជាគឺ តាម៉ុក ទទួលបញ្ជាផ្ទាល់ពី ប៉ុល ពត មិនមែនទទួលបញ្ជាពី នួន ជាទេ។ ចំណែក សុន សេន ជាអចិន្ត្រៃយ៍មជ្ឈឹម តែស្ថិតនៅក្រោម តា ម៉ុក។ ក្រោយការបោសសម្អាតអស់បួនភូមិភាគ ប៉ុល ពត បានតែងតាំង តាម៉ុក ឲ្យធ្វើជាអគ្គសេនាធិកាកងទ័ពនៅពី សុន សេន។ នេះគឺជារឿងផ្ទៃក្នុងរបស់បក្ស នៅពេលដែលតែងតាំង តាម៉ុក នេះ គឺមានការប្រកាសតាមវិទ្យុផង ហើយ សុន សេន នៅតែបន្តការងាររបស់គាត់ដដែល តែនៅក្រោម តាម៉ុក"។ លោកសាក្សីសំណួររបស់ខ្ញុំ តើលោកតាមដែលលោកដឹង តើលោកអាចយល់ថាយ៉ាងម៉េច

មានប្រតិកម្មយ៉ាងម៉េចចំពោះចម្លើយរបស់សាក្សីរូបនេះ?

**ឆ៖** សមាសភាពចាត់តាំងនេះគឺ ប៉ុល ពត ដែលមានរហស្សនាមថា បងទី១ នោះគឺគាត់ គាត់ពិតហើយ ហើយ តាម៉ុក ប្រហែលជាលំដាប់ទី៣ តែគាត់ទទួលបទបញ្ជាផ្ទាល់ពី ប៉ុល ពត ហើយចំណែក សុន សេន ហ្នឹងគាត់ទទួលខាងអគ្គសេនាធិកាកងទ័ព។ តែព្រឹត្តិការណ៍ផ្លាស់ប្តូរក្រោយនេះ ខ្ញុំមិនបានច្បាស់ទេ មិនបានដឹងទេ។ ក្រោយពីបោសសម្អាតអស់បួនភូមិភាគ ប៉ុល ពត បានតែងតាំង តាម៉ុក ឲ្យធ្វើជាអគ្គសេនាធិកាកងទ័ពពីលើ សុន សេន ហ្នឹង គឺខ្ញុំមិនបានដឹងទេព្រឹត្តិការណ៍នេះ។

[១៤:១៣:៥៥]

**ស៖** សាក្សីមួយរូបដែលបានផ្តល់សក្ខីកម្មមុននេះគឺថា តាម៉ុក ក៏ត្រូវគេស្គាល់ថាជាបងទី២ សាក្សីថាអ៊ីចឹង។ តើត្រឹមត្រូវ ឬក៏មិនត្រូវទេ?

**ឆ៖** អត់ត្រឹមត្រូវទេ បើតាមចម្លើយដែលខ្ញុំអាន -- ដែលគាត់អានអម្បាញ់មិញនេះ គឺ តាម៉ុក ទី៣ ហើយការយល់របស់ខ្ញុំក៏ តាម៉ុក ទី៣ដែរ។ តាម៉ុក ទទួលបទបញ្ជាផ្ទាល់ពី ប៉ុល ពត។

**ស៖** លោកសាក្សី ខ្ញុំចូលទៅសម្រង់មួយទៀតពីចម្លើយរបស់សាក្សីរូបនេះដដែល គឺសំណួរចម្លើយលេខ៦៤ សួរថា៖ តើថ្នាក់ដឹកនាំខាងលើបានផ្តល់ផែនការអ្វីខ្លះ? ហើយចម្លើយឆ្លើយដូចតទៅ៖ “ការប្រជុំនេះ គឺប្រជុំដើម្បីទទួលការងារ សម្រាប់ខ្ញុំត្រូវគេឲ្យទៅចម្ការកៅស៊ូនៅកំពង់ចាម ដើម្បីរៀបចំសហករណ៍ រៀបចំសហជីពនៅទីនោះ។ ចំណែកអ្នកផ្សេងទៀត ទទួលការងារផ្សេង។ នៅពេលប្រជុំ ប៉ុល ពត បាននិយាយអំពីការក្បត់នៅតាមភូមិភាគ ដោយមានសរសេរនៅលើក្តារខៀនផងដែរ។ សួរ៖ លោកនិយាយថា ប៉ុល ពត បាននិយាយអំពីការក្បត់នៅតាមភូមិភាគ។ តើប៉ុល ពត បាននិយាយអំពីការបោសសម្អាតនៅតាមភូមិភាគ ហើយរៀបចំរចនាសម្ព័ន្ធថ្មីដែរឬទេ? ចម្លើយលេខ៦៥៖ ប៉ុល ពត ពុំបានប្រើពាក្យបោសសម្អាតទេ គាត់និយាយថាភូមិភាគនេះក្បត់។ ដាក់មិត្តទៅ មិត្តជាដៃស្តាំ ធ្វើការឲ្យកើតបំពេញបានឬមិនបាន។ អ្នកដឹកនាំគឺនិយាយដូច្នេះ”។ សំណួររបស់ខ្ញុំ សួរលោកថា ដឹងថាមានកិច្ចប្រជុំបែបនេះ ដែល ប៉ុល ពត ទៅធ្វើជាអធិបតីភាពហ្នឹងទេ?

[១៤:១៦:០៨]

**ឆ៖** ខ្ញុំអត់បានដឹងផង ព្រោះខ្ញុំមានបានទៅប្រជុំអីណា អត់បានដឹងទេ។

**ស៖** តាមរយៈសំណួរលោកចៅក្រម ឡាវ៉ែន៍ កាលពីម្សិលមិញ លោកនិយាយអំពីអង្គប្រជុំមួយសម្រាប់កម្មាភិបាល ដែលក្នុងនោះ នួន ជា បានចូលរួម និងបានឡើងថ្លែងសុន្ទរកថា។ សំណួររបស់ខ្ញុំ

តើមានកម្មាភិបាលប៉ុន្មាននាក់បានមកចូលប្រជុំជាមួយលោក ស្តាប់ពាក្យពេចន៍របស់ នួន ជា ហ្នឹង?

**ឆ៖** ខ្ញុំៗចាំមិនបានចំនួនអស់ទេ។ ប៉ុន្តែសាលបុរីកីឡា ពីដើមៗបុរីកីឡា នៅខាងជើងវត្តព្រះពុទ្ធ។ សាលបុរីកីឡានេះ គឺពេញសាលបុរីកីឡា។ ដូច្នេះ ខ្ញុំមិនចាំចំនួនប៉ុន្មានទេ។

**ស៖** តាមការចងចាំរបស់លោកហ្នឹង លោកស្មានមើល៍ -- លោកៗ ជួយគិតមើលថាប្រហែលជាមានកម្មាភិបាលប៉ុន្មានមាន១០ មាន១០០ មាន១០០០នាក់ ឬក៏ប៉ុន្មានដែលស្តាប់ នួន ជា ថ្លែងសុន្ទរកថាហ្នឹង?

**ឆ៖** ខ្ទង់ប្រហែលជា ក្រោម១០០ ឬក៏១០០ និងមួយរយលើ។ ប្រហាក់ប្រហែលប៉ុណ្ណឹង។

**ស៖** ពីម្សិលមិញលោកចៅក្រម ឡាវែន៍ ព្យាយាមសួរ ក្រែងលោកមានការចងចាំអំពីការប្រជុំនោះ តើលោកមានដឹងថាមានកិច្ចប្រជុំណាមួយស្រដៀងគ្នានេះ ដែល នួន ជា មិនបានប្រើប្រាស់ពាក្យថា“បោសសម្អាត” នេះដែរទេ?

**ឆ៖** ខ្ញុំមិនបានចាំទេ។

[១៤:១៩:00]

**ស៖** សំណួរបន្ទាប់ក៏ជាសម្រង់សម្តីរបស់សាក្សីរូបនេះដែរ គឺសំណួរ-ចម្លើយលេខ៩៥ គឺអ្នកស៊ើបអង្កេតបានសួរដូចតទៅនេះ៖ “លោកនិយាយថា សុន សេន ធ្វើការស្ថិតក្រោម តាម៉ុក។ តាមលោកដឹង តើ តាម៉ុក ជាអ្នកតែងតាំង មាស មុត ជាលេខាកងពលលេខ២ ដែរឬទេ? ចម្លើយលេខ៩៥៖ ខ្ញុំមិនគិតដូច្នេះទេ ព្រោះខាងមជ្ឈិមដែលទទួលខុសត្រូវខាងយោធាជាអ្នកសម្រេច។ ហើយអ្នកទទួលខុសត្រូវខាងយោធា មាន សុន សេន, តាម៉ុក, និង ប៉ុល ពត។ ពុំមានអ្នកណាម្នាក់អាចសម្រេចបាននោះទេ គឺត្រូវសម្រេចទាំងអស់គ្នា។ ខ្ញុំសូមបញ្ជាក់ឡើងវិញថា ខ្ញុំសូមឆ្លើយមិនដឹងចំពោះសំណួរនេះ ព្រោះខ្ញុំមិនច្បាស់ទេ”។ លោកសាក្សី ខ្ញុំដឹងថាលោកមិនអាចឆ្លើយបានទេ ប៉ុន្តែលោកដឹងអ្វីអំពីគណៈកម្មាធិការកងទ័ពមជ្ឈិមនេះដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹងគណៈកម្មាធិការ គណៈកម្មាធិការកងទ័ពមជ្ឈិមទេ ខ្ញុំដឹងត្រឹមតែថា សុន សេន ជាអគ្គសេនាធិការ។ ក្រៅពីនេះទៀតសមាជិក ប្រធាន អ៎! អនុប្រធាន ឬសមាជិកអីថែមទៀតខ្ញុំអត់បានដឹងទេ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះសំណួរចម្លើយលេខ១២៦ របស់សាក្សីរូបនេះ។ ខ្ញុំសូមអានសំណួរចម្លើយនេះជូនលោកស្តាប់ ហើយខ្ញុំសួរថាតើលោកមានប្រតិកម្មយ៉ាងដូចម្តេចដែរ គឺនៅ

ពេលដែលខ្ញុំនៅកំពង់ចាម មុនពេលដែលខ្ញុំទៅកំពង់ចាម គឺពួកនៅគណៈតំបន់ដដែល។ "មុនពេលវៀតណាមវ៉ៃចូល១ឆ្នាំ ឈ្មោះ សោម ត្រូវបានគេផ្លាស់មកនៅភ្នំពេញ ដោយធ្វើការប្រធាននៅមន្ទីរក្នុងក្រសួងការបរទេស"។ តើឈ្មោះ សោម នេះ គឺជាឈ្មោះ សោម ដែលខ្ញុំទើបតែសួរលោកអម្បាញ់មិញ ឬក៏អីដែលខ្ញុំសួរលោកថាតើ សោម នេះមានទំនាក់ទំនងយ៉ាងម៉េចដែរ ជាមួយ ជូ ជេត?

**ឆ៖** គឺឈ្មោះ សោម ហ្នឹងហើយ ប៉ុន្តែខ្ញុំមិនដឹងថាគាត់ត្រូវចាត់តាំងទៅធ្វើជាប្រធានមន្ទីរនៅក្រសួងការបរទេសទេ តែខ្ញុំជួបគាត់នៅមន្ទីរពេទ្យរុស្ស៊ី ខែ៧ ឬខែ៨ ៧៧ហើយ។ គាត់ជាអ្នកជំងឺរបេងសួត។

[១៤:២២:២៤]

**ស៖** ខ្ញុំមិនដឹងថាសួរលោកហើយឬនៅទេ។ តើលោកមានទំនាក់ទំនងញឹកញាប់ជាសោមដែរទេ?

**ឆ៖** ពេល បងសោម នៅជាលេខាតំបន់តាកែវ ឆ្នាំ៧០, ៧១ ខ្ញុំទៅកោះអណ្តែត។ មាន៦ខែ វិនណោះ បានខ្ញុំមកជួប បងសោម ម្តង មកជាមួយ បងផែន ហើយបន្ទាប់មក ក្រោយ៧៥ៗ មានការទំនាក់ទំនងហូរហែប្រចាំខែជាមួយគាត់តាមរយៈគាត់ហៅមករៀនសូត្រ។

**ស៖** ចុះអំឡុងពេលចន្លោះពីឆ្នាំ១៩៧៥ទៅ៧៩ ខ្ញុំស្តាប់មិនច្បាស់អំមិញ តើលោកបានជួបនិយាយផ្ទាល់ជាមួយគាត់ញឹកញាប់ទេ គឺចន្លោះពី៧៥ ទៅ៧៩?

**ឆ៖** ខ្ញុំបានជួបរយៈពេលនុ៎ង គឺជួបមួយខែម្តងអី ពីរខែម្តងអីជាមួយគាត់។ ដោយពេល វាពីរវគ្គ ៧៥ ដល់ ៧៧ ខ្ញុំនៅកោះអណ្តែត។ ដូច្នេះឆ្ងាយ ពីរខែបានជួបម្តង បីខែជួបម្តង។ តែ៧៧ទៅ គាត់ជួបគាត់នៅមន្ទីរអ៊ីចឹង គាត់ឈឺអ៊ីចឹង។ ដូច្នេះជួបនៅមន្ទីរពេទ្យហ្នឹងតែម្តងទេ។

**ស៖** ខ្ញុំយល់មិនច្រឡំទេ គឺលោក -- តើលោកធ្លាប់ដែលនិយាយអំពីទំនាក់ទំនងរបស់គាត់ជាមួយ ជូ ជេត ទេ? ឬក៏លោកមិនដឹងអំពីទំនាក់ទំនងរបស់ សោម ជាមួយនឹង ជូ ជេត ទេ?

**ឆ៖** ខ្ញុំៗជម្រាបថា ខ្ញុំអត់ដឹងទេ។

[១៤:២៥:៣០]

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅសំណួរចម្លើយលេខ១៨៨ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដដែលហ្នឹង។ សាក្សី -- នៅក្នុងចម្លើយលេខ១៨៨ គឺនិយាយយោងៗទៅលើឯកសារ ហើយចម្លើយរបស់គាត់ទាក់ទងទៅនឹងឯកសារនុ៎ង។ គាត់ឆ្លើយថា "ខ្ញុំពុំដែលបាន -- ខ្ញុំធ្លាប់ទទួលលិខិតមតិណែនាំរបស់ ប៉ុល ពត ក្នុងខែ៨ ឆ្នាំ១៩៧៨ ឲ្យបញ្ឈប់សម្លាប់មនុស្សបន្តទៀត"។ ហើយលិខិតគឺជា

លិខិតដែលចេញជាទូទៅ។ លោកមានដែលចាំអំពីលិខិតចេញពី ប៉ុល ពត គឺលិខិតចេញជាសាធារណៈតែម្តង ដែលបញ្ជាប់ការសម្លាប់មនុស្សនោះ?

**ឆ៖** សូមទោស ខ្ញុំៗមិនចាំទេ។

**ស៖** បាទ មិនជាអ្វីទេ។ គឺសំណួរចុងក្រោយសម្រាប់សាក្សីរូបនេះ គឺពីររយ -- សំណួរ-ចម្លើយ ២៤៤ សាក្សីត្រូវបាន -- "សួរ៖ ថាតើលោកមានអ្វីកើតឡើងចំពោះខ្មែរក្រោមដែលមកដល់ស្រុកគីរីវង់ដែរទេ? ហើយចម្លើយ២៤៤៖ ខ្ញុំពុំបារម្ភអំពីខ្មែរក្រោមនៅស្រុកគីរីវង់ទេ ព្រោះពួកគេត្រូវយួនធ្វើបាប ហើយរត់មករស់នៅក្នុងប្រទេសកម្ពុជាវិញ។ ហើយ២៤៨៖ ខ្មែរកម្ពុជាក្រោមគឺបានចាកចេញពីប្រទេសវៀតណាមគឺដោយសារពួកវៀតណាម គឺធ្វើបាប ហើយក៏បានចាកចេញមករស់នៅប្រទេសកម្ពុជា"។ លោកដែលដឹងថាមានខ្មែរក្រោមរត់ចេញពីប្រទេសវៀតណាម ដោយសារតែការធ្វើបាបដោយពីសំណាក់អាជ្ញាធរវៀតណាមដែរទេ?

**ឆ៖** ពេលកងទ័ពវៀតណាមចូលមកកម្ពុជា ខ្ញុំរត់ចូលៗភ្នំមក ខ្ញុំជួបកម្លាំងកងទ័ពខ្មែរក្រោមរត់ជាមួយគ្នាដែរ។ ដូចជាមេគេឈ្មោះ តាប្រាជ្ញៗ ខ្ញុំចាំបានប៉ុណ្ណឹងដែរ តែមិនដឹងចំនួនប៉ុន្មានអីប៉ុន្មានទេជាកងទ័ពរត់មកជាមួយគ្នាហ្នឹង។

**ស៖** លោកដឹងអំពីការធ្វើបាបខ្មែរក្រោមពីសំណាក់អាជ្ញាធរវៀតណាមដែរទេ គឺក្នុងឆ្នាំ១៩៧៥ ឬមុនឆ្នាំ១៩៧៦ ឬមុនឆ្នាំ១៩៧៧?

[១៤:២៩:១៦]

**ឆ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** លោកសាក្សី នៅក្នុងរបាយការណ៍មួយស្តីអំពីដំណើរទស្សនកិច្ចរបស់សមាគមមិត្តភាព-ជប៉ុន គឺឯកសារ E3 -- ខ្ញុំបង្ហាញជូន ERN ជាភាសាខ្មែរគឺឯកសារ E3/294 គឺ ERN ជាភាសាអង់គ្លេស 00171073។ ខ្ញុំសូមអានរបាយការណ៍ស្តីអំពីដំណើរទស្សនកិច្ចនេះ ដែលរបាយការណ៍នេះនិយាយថា នៅក្នុងកថាខណ្ឌទី២ នៃឯកសារ E3/2-- នៅតំបន់តាកែវ ភៀសដែលជាៗខ្មែរក្រោម ដែលជា -- រងការធ្វើបាបដោយវៀតណាមនិងគាបសង្កត់ ក៏បានរត់មកជ្រកកោននៅស្រុកគិរីវង់ គឺគណៈប្រតិភូ គឺមានការរន្ធត់ណាស់អំពីការកាប់សម្លាប់រង្គាល ដែលប្រព្រឹត្តឡើងដោយអាជ្ញាធរវៀតណាមដោយមានគោលបំណងបំបាត់ពូជខ្មែរចោលតែម្តង។ លោកសាក្សី ខ្ញុំដឹងថាលោកមិនពាក់ព័ន្ធនៅក្នុងការទទួលភៀវជប៉ុនហ្នឹងទេ ប៉ុន្តែតើលោកដឹងអ្វីមួយអំពីការព្រួយបារម្ភៗចំពោះប្រតិភូជប៉ុននេះដែរទេ?

**ឆ៖** ខ្ញុំអត់បានជួបផង ខ្ញុំអត់បានដឹង។

**ស៖** ភ្ញៀវជប៉ុនហ្នឹង គឺត្រូវបានគេប្រាប់អំពីការសម្លាប់រង្គាលហ្នឹង។ ហើយនៅក្នុងឃុំរបស់លោកៗបានទទួលប្រតិភូមុនៗ។ អ៊ីចឹងឯងបានជាខ្ញុំសួរថាតើលោកមានចាំអ្វីមួយអំពីការធ្វើទុក្ខបុកម្នេញពីសំណាក់អាជ្ញាធរវៀតណាមមកលើខ្មែរក្រោមដែរទេ? ហើយតំណាងរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹងក៏បានរាយការណ៍អំពីរឿងនេះ ជូនទៅដល់ភ្ញៀវជប៉ុនហ្នឹង លោកមានចាំអ្វីពីរឿងនេះទេ?

[១៤:៣២:០៦]

**ឆ៖** ជម្រាបលោកមេធាវី ខ្ញុំបញ្ជាក់ហើយបញ្ជាក់ទៀត ថាភ្ញៀវជប៉ុននេះ ខ្ញុំប្រាប់ថាខ្ញុំអត់បានជួប ហើយខ្មែរក្រោមដែលខ្ញុំជួបពេលរត់នៅភ្នំនេះទៅហើយ មានមេបញ្ជាការឈ្មោះ ប្រាជ្ញ តែប៉ុណ្ណឹងទេ។ ឯទាក់ទិនរឿង ដឹងរឿងទុក្ខសោក សោកនាដកម្មរបស់ខ្មែរក្រោម ដែលឲ្យឃើញ ឲ្យឮនឹងត្រចៀកតែម្តង គឺខ្ញុំអត់បានដឹងបានឮទេ។

**ស៖** សូមអរគុណលោកសាក្សី។ នៅក្នុងឯកសារដដែលហ្នឹង តំណាងកម្ពុជាប្រជាធិបតេយ្យបាននិយាយទៅដល់ -- និយាយប្រាប់ប្រតិភូជប៉ុន យោងតាមរបាយការណ៍នេះ គឺថាពួកគេប្រឆាំងគេ -- ប្រឆាំងជាមួយនឹងបក្សសម្ព័ន្ធឥណ្ឌូចិន គឺឯកសារ E3/294។ តើអ្វី ស្អីដែលជាសហព័ន្ធឥណ្ឌូចិនហ្នឹងលោកសាក្សី?

**ឆ៖** សហព័ន្ធឥណ្ឌូចិនហ្នឹង ខ្ញុំធ្លាប់បានឮ តាម៉ុក គាត់និយាយ គឺសហព័ន្ធរវាងប្រទេសវៀតណាម ឡាវ និង កម្ពុជា។ គេហៅថា សហព័ន្ធឥណ្ឌូចិន។ ពីជំនាន់បារាំង បារាំងដាក់ថា *អាំងឌូស៊ីនហ្វ្រង់សែស្ហ៊ីះ*។ បារាំងដាក់ថាអ៊ីចឹង។ សហព័ន្ធឥណ្ឌូចិន គឺរួមបីប្រទេសហ្នឹង វៀតណាម ឡាវ កម្ពុជា។ ហើយ តាម៉ុក បានបញ្ជាក់ទៀត គឺថាវៀតណាមចង់ធ្វើបីប្រទេសហ្នឹង ឲ្យទៅជាប្រទេសតែមួយ។ គឺប្រទេសវៀតណាម។

**ស៖** តាម៉ុក ដែលពន្យល់ថាតើវៀតណាមមានបំណងដើម្បីសម្រេចគោលបំណងនេះ ដោយរបៀបណាទេ?

[១៤:៣៤:៤៨]

**ឆ៖** តាម៉ុក ដែលពន្យល់ ដែលៗធ្លាប់បានពន្យល់ខ្ញុំអំពី -- ពន្យល់ខ្ញុំនិងកម្មាភិបាលផ្សេងៗទៀតអំពីគោលបំណងសហព័ន្ធឥណ្ឌូចិនហ្នឹង។

**ស៖** តើលោកចាំពាក្យពេចន៍ផ្ទាល់របស់ តាម៉ុក ទេ?

**ឆ៖** យូរឆ្នាំពេកហើយ ខ្ញុំភ្លេចចាំពាក្យពេចន៍សម្ដីៗរបស់គាត់ហ្នឹង។

**ស៖** លោកដឹង ឬក៏លោកចាំថាតើវៀតណាមព្យាយាមធ្វើឲ្យសម្រេចគោលបំណង ឬក៏ទិសដៅនៃសហព័ន្ធឥណ្ឌូចិនហ្នឹងដែរទេ? លោកៗចាំទេ អំពីគោលបំណងឲ្យសម្រេចនូវទិសដៅរបស់សហព័ន្ធឥណ្ឌូចិនហ្នឹង?

**ឆ៖** ខ្ញុំអត់ចាំទេ។

**ស៖** លោកសាក្សី ខ្ញុំជឿថាលោកអានឯកសារទង់បដិវត្ត លោកស្ដាប់វិទ្យុផ្សាយសំឡេងរបស់កម្ពុជាប្រជាធិបតេយ្យ លោកមានចាំអ្វីដែលមុន ដែលកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យនិយាយអំពីៗមហិច្ឆតារបស់វៀតណាមទេ?

**ឆ៖** ខ្ញុំដែលបានស្ដាប់វិទ្យុ បានអានទស្សនាវដ្ដីទង់បដិវត្ត ហើយក៏បានឮ និងឃើញដូចសម្ដីដែលលោកមេធាវីសួរខ្ញុំអ៊ីចឹង។ តែឥឡូវនេះ ខ្ញុំមិនចង់ប៉ិាននិយាយព្រោះប្រទេសកម្ពុជាយើងវៀតណាមមកនៅពេញទៅហើយ។

[១៤:៣៧:២៨]

**ស៖** វាត្រឹមត្រូវហើយលោក។ លោកសាក្សីខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយ ប៉ុន្តែឥឡូវនេះ ខ្ញុំឃើញថាដូចជាម៉ោងពីរសែសិបហើយ ហើយខ្ញុំគិតថាយើងនៅមានលេខERN មួយ ប៉ុន្តែមិនមាន ERN ជាភាសាខ្មែរនិងបារាំងទេ។ ដូច្នេះ ខ្ញុំចង់បន្តទៅប្រធានបទថ្មី។ ដូច្នេះ ថាតើលោកប្រធានចង់សម្រាកសិន ឬមួយក៏អនុញ្ញាតឲ្យខ្ញុំបន្តទៅមុខទេ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មានប្រធានបទថ្មី គប្បីសម្រាកពីឥឡូវហ្នឹងទៅ។

បាទ ឥឡូវ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីនិងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សារបស់គាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុនផ្តល់វេទិកាជូនទៅមេធាវី វ៉ិចទ័រ កូប៉េ សូមជម្រាបលោកមេធាវីថា មេធាវីការពារក្តីមានពេលមួយរសៀលនេះ ហើយនិងស្អែកមួយវគ្គសវនាការនៅថ្ងៃស្អែកយ៉ាងយូរបំផុត។ សូមជ្រាបបាទ។

បាទ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវី វ៉ិចទ័រ កូប៉េ។

ហើយបញ្ជាក់ផងថា -- សូមសម្របសម្រួលជាមួយមេធាវីការពារក្តីលោក ខៀវ សំផន ផងក្រែងលោមានការប្រើប្រាស់ពេលវេលាលើស លោក វ៉ិចទ័រ កូប៉េ សូមបញ្ជាក់ផង។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំមានប្រធានបទពីរបីតូចៗទេ ដែលខ្ញុំចង់ពិភាក្សាជាមួយលោក។ តែមុននឹងបន្ត ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិចទៅនឹងចម្លើយដែលលោកបានផ្តល់មុនពេលដែលយើងឈប់សម្រាក។ ខ្ញុំមិនច្បាស់ថាតើ លោកភ័យខ្លាចមិនហ៊ានផ្តល់ចម្លើយទាក់ទងទៅនឹងវៀតណាម ឬមួយក៏យ៉ាងម៉េច?

**លោក នាង អ៊ួច៖**

**ឆ៖** សូមៗលោកសួរម្តងទៀត។

**ស៖** មុនពេលឈប់សម្រាក លោកបាននិយាយបញ្ហាមួយចំនួន នៅពេលដែលខ្ញុំនិយាយអំពីចិន ហើយនិងមហិច្ឆតារបស់វៀតណាម។ ហើយលោកបាននិយាយអំពីបញ្ហាមួយ ដែលហាក់ដូចជាបង្ហាញថាលោកភ័យខ្លាចមិនហ៊ាន និយាយអំពីបញ្ហានេះ ព្រោះថាដោយសារតែមានវៀតណាមជាច្រើនរស់នៅក្នុងប្រទេសកម្ពុជា។ អ៊ីចឹងតើនេះជាចម្លើយរបស់លោកមែនទេ? ហើយប្រសិនបើវាជាចម្លើយរបស់លោកមែន តើលោកចង់មានន័យយ៉ាងដូចម្តេចដែរ នៅពេលដែលលោកនិយាយឃ្លាទាំងអស់នេះ?

[១៥:០៤:០០]

**ឆ៖** ព្រោះន៎ែ ការនិយាយឲ្យវែងឆ្ងាយអំពីរឿងមហិច្ឆតារបស់វៀតណាម ខ្ញុំយល់អំពីសន្តិសុខ

ផ្ទាល់ខ្លួនរបស់ខ្ញុំ។ ពីព្រោះកម្ពុជាយើង ការដែលខ្ញុំចូលមកធ្វើជាសាក្សីនេះ វិទ្យុ ទូរទស្សន៍អីផ្សព្វផ្សាយរូបខ្ញុំអស់ហើយ។ សំឡេង ខ្លឹមសារនិយាយ ហើយជនជាតិវៀតណាមនៅកម្ពុជាយើងគ្រប់ច្រកល្ហករហូតដល់ស្រុកសំឡូត ដល់ប៉ៃលិន ដែលជាទីកន្លែងរបស់ខ្ញុំ។ ដូច្នេះ កាលណាខ្ញុំនិយាយបញ្ហានេះទៅជ្រាលជ្រៅច្បាស់លាស់ពេកទៅ ខ្ញុំភ័យព្រួយអំពីសន្តិសុខរបស់ខ្ញុំដែរ។ សូមជ្រាប។

**ស៖** ហើយនៅពេលដែលខ្ញុំនិយាយអំពីគោលនយោបាយវៀតណាមកាលពី៤០ឆ្នាំមុន លោកនៅតែមានអារម្មណ៍ដូចគ្នាអ៊ីចឹង ឬមួយក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំនៅតែមានអារម្មណ៍ដូចអ៊ីចឹងដែរ ដូចៗខ្ញុំបញ្ជាក់អំមិញអ៊ីចឹង។

**ស៖** មិនអីទេ ខ្ញុំនឹងបន្តប្រធានបទចុងក្រោយរបស់ខ្ញុំ។ ប្រធានបទដែលខ្ញុំចង់ពិភាក្សាជាមួយលោកពេលនោះ គឺE3/409 -- 4093 ដែលយើងបានពិភាក្សាកន្លែងមកគឺ E3/4093។ ហើយខ្ញុំចង់សួរលោកអំពីទំព័រដែលមានលេខ 00831489, ខ្មែរមានលេខ 00270790 និងបារាំងមានលេខ 0072 9676 គឺជារបាយការណ៍មួយដែលនិយាយអំពីស្ត្រីម្នាក់ ម្នាក់ឈ្មោះ ណៃ ឈៀក ប្រពន្ធរបស់ សេង។ ខ្ញុំឃើញថាសាក្សីកំពុងតែពិនិត្យមើលទៅលើឯកសារ E3/4093 គឺឯកសារដែលមានហត្ថលេខារបស់លោកនោះ។ ហើយខ្ញុំចង់ឲ្យសាក្សីពិនិត្យមើលទៅលើទំព័រដែលបញ្ចប់ដោយលេខ90 នៅខាងចុងនៃលេខ។ ឯកសារនេះនិយាយអំពីស្ត្រីពីររូប មួយឈ្មោះ ណៃ ជី ត្រូវជាប្រពន្ធ សេង និងមួយទៀត ឈ្មោះ ផាន់ ណា។ តើលោកឃើញឯកសារនេះទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមានឯកសារនៅសល់ ប្រហែលជាខ្ញុំអាចជូនទៅបាន។

**ប្រធានអង្គជំនុំ៖**

រដ្ឋបាលតុលាការទទួលឯកសារពីមេធាវីជូនសាក្សីពិនិត្យ!

[១៥:០៨:៣០]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំចង់ឲ្យលោកចាប់អារម្មណ៍ទៅលើអ្វីដែលនិយាយ ដែលសរសេរអំពី ណៃ ជី។ ជាពិសេសគឺប្រអប់មួយដែលខ្ញុំគូសឲ្យលោក។ ខ្ញុំសូមអាន "ស្ត្រីនេះ វាប្រឆាំងជាមួយបក្ស។ ដោះស្រាយមិនចេះចប់ ព្រមជាមួយនេះ វាមើលងើយកម្មាភិបាលដឹកនាំយើងជាប់ជានិច្ច។ ឯសកម្មភាពវាគឺធ្វើឆ្គួត ហើយលួចមិនចេះចប់ គឺលួចសព្វមុខ។ ទោះអប់រំយ៉ាងណាវាមិនព្រមកសាងខ្លួនវាដែរ"។

ដូច្នេះ ខ្ញុំចង់សួរលោកថា "ទោះអប់រំយ៉ាងណា ក៏វាមិនព្រមកសាងខ្លួនវាដែរ"។ តើលោកអាចបញ្ជាក់ ឬក៏ពន្យល់បន្តិចបានដែរឬទេ ថាតើគេចំណាយពេលវេលាប៉ុន្មានដែរ ដើម្បីធ្វើការអប់រំ ឬក៏ដើម្បីបង្រៀន ទៅដល់បុគ្គលមួយនេះ? តើគេចំណាយពេលជាទូទៅ តើគេត្រូវការពេលប្រហែលជាប៉ុន្មានដែរ ដើម្បី អប់រំរៀនសូត្រនោះ?

**លោក នាង អ៊ួច៖**

**ឆ៖** គេអប់រំរៀនសូត្រម្តងៗ កន្លះថ្ងៃអី។ ពាក់កណ្តាលថ្ងៃ កន្លះថ្ងៃហ្នឹង ម្តង។

**ស៖** តើអ្នកដែលគេបញ្ជូនយកទៅអប់រំ ហើយបញ្ចប់ការអប់រំ ហើយត្រឡប់មកវិញហើយ គេ បញ្ជូនទៅម្តងទៀតហើយ ម្តងទៀត និងម្តងទៀត។ តើមានអីកើតឡើងចំពោះមនុស្សបែបនេះ?

**ឆ៖** របៀបដូចនេះ បញ្ជាក់ថាឆ្កួតនេះ គេៗអប់រំហើយអប់រំទៀត មិនៗមានអីដែលមានទុក្ខ មានទោសអីទេ បើគេសន្និដ្ឋាន គេគិតថាជាមនុស្សឆ្កួតទៅហើយ។

**ស៖** តើលោកអាចធ្វើការប៉ាន់ប្រមាណថាតើគេត្រូវការពេលវេលាប្រហែលប៉ុន្មានដែរ ដើម្បីធ្វើ ការអប់រំរៀនសូត្រ មនុស្សម្នាក់នោះជាទូទៅ?

**ឆ៖** គេប្រើពេលពីកន្លះខែ ទៅ ១ខែ។

[១៥:១២:០៥]

**ស៖** តើលោកធ្លាប់ដឹង ឬក៏ធ្លាប់ជួបអ្នកដែលគេបញ្ជូនទៅអប់រំ ម្តងហើយម្តងទៀតៗ នៅតែ អប់រំមិនចេះ ម្តងហើយម្តងទៀតអ៊ីចឹង។ តើលោកធ្លាប់ជួបមនុស្សបែបហ្នឹងអ៊ីចឹងទេ?

**ឆ៖** ខ្ញុំអត់បានធ្លាប់ជួបទេ។

**ស៖** លោកសាក្សីនៅពេលដែលគេបញ្ជូនទៅអប់រំនៅមន្ទីរ១០៥ ឬក៏ហៅថាក្រាំងតាចាន់ហ្នឹង តើលោកដឹងថាគេមានការអប់រំនៅមន្ទីរក្រាំងតាចាន់ដែរឬទេ? ប្រសិនបើមានការអប់រំមែន ថាតើគេត្រូវ ការពេលវេលា ចំណាយពេលវេលាប៉ុន្មានដែរសម្រាប់ការអប់រំនៅក្រាំងតាចាន់នោះ?

**ឆ៖** ខ្ញុំៗអត់បានដឹងទេ តែសភាពបែបនារីដែលមាននៅក្នុងឯកសារនេះ ប្រហែលជាគេអប់រំ នៅកន្លែង ម៉េង នៅខាងលិចអង្គរកា – កន្លែងម៉េងនៅខាងលិចអង្គរកា។ ឯក្រាំងតាចាន់ ការអប់រំនៅ ក្រាំងតាចាន់ខ្ញុំមិនដែលបានដឹងទេ។

**ស៖** ហេតុអ្វីបានជាលោកនិយាយថាគេបញ្ជូនស្ត្រីនេះទៅកន្លែងមួយទៀត មិនមែនបញ្ជូនទៅ ក្រាំងតាចាន់អ៊ីចឹង?

[១៥:១៤:២០]

**ឆ៖** ពីព្រោះស្ត្រីនេះមានកម្រិត គេហៅកម្រិតល្មួច ដែលកម្រិតស្រាល។ ដូច្នេះគេមានកន្លែងអប់រំមួយនៅកន្លែង កម្រិតស្រាល កសាងខ្លួននៅខាងលិចផ្សារអង្គរកា កន្លែងឈ្មោះ ម៉េង ទទួលខុសត្រូវ។

**ស៖** អរគុណលោកសាក្សី។ ខ្ញុំបានលើកពីមុនមកហើយថាអំពី ក្រាំងតាចាន់ៗ គឺមន្ទីរអប់រំ ១០៥ ហើយឈ្មោះរបស់មន្ទីរនេះ គឺមានន័យថា គឺជាមន្ទីរសម្រាប់អប់រំមនុស្ស។ តើលោកដឹងថាវាជាការពិតបែបនេះមែន ឬមួយថាឈ្មោះដែលគេហៅថាមន្ទីរអប់រំហ្នឹង វាមិនសមជាមួយនឹង ឬក៏វាមិនត្រូវជាមួយនឹងការបំពេញសកម្មភាពនៅទីនោះទេ។ តើលោកអាចបញ្ជាក់បានទេអំពីចំណុចនេះ ថាតើជាមន្ទីរអប់រំមែន ឬក៏មិនមែន?

**ឆ៖** ជាៗមន្ទីរអប់រំមែន។

**ស៖** អ៊ីចឹងលោកចង់ផ្តល់សក្ខីកម្មថាឈ្មោះរបស់មន្ទីរនេះ គឺវាសមស្របជាមួយនឹងអ្វីដែលបានធ្វើនៅក្រាំងតាចាន់នោះ។ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំអត់ដឹងសកម្មភាពយ៉ាងជ្រាលជ្រៅនៅក្រាំងតាចាន់នោះទេ។

**ស៖** លោកសាក្សី តើលោកដឹងទេថាអ្នកដែលគេបញ្ជូនទៅក្រាំងតាចាន់ ត្រូវបានគេយកទៅសួរចម្លើយអំពីសកម្មភាពដែលត្រូវបានគេចោទប្រកាន់។ តើលោកដឹងទេអំពីចំណុចនេះ?

**ឆ៖** គេអាចសាកសួរចម្លើយនៅកន្លែងហ្នឹង។

[១៥:១៧:៥៦]

**ស៖** តើលោកធ្លាប់អានរបាយការណ៍សួរចម្លើយ ឬក៏ត្រូវបានគេជម្រាបអំពីខ្លឹមសារនៃការស៊ើបអង្កេត -- នៃការសួរចម្លើយអ្នកដែលត្រូវបានគេបញ្ជូនទៅក្រាំងតាចាន់ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលបានទទួលរបាយការណ៍ហ្នឹងទេ។

**ស៖** លោកសាក្សី មានការប្រើសក្ខីកម្មនៅចំពោះអង្គជំនុំជម្រះនេះ ដែលសក្ខីកម្មនោះនិយាយថា "អ្នកដែលគេបញ្ជូនទៅក្រាំងតាចាន់ គឺទៅមន្ទីរអប់រំតំបន់១០៥ -- ស្រុក១០៥ត្រូវបានគេយកទៅសួរចម្លើយភ្លាមៗតែម្តង"។ តើលោកដឹងអំពីចំណុចនេះទេ?

**ឆ៖** គេសួរចម្លើយភ្លាម ឬទុកយូរសួរចម្លើយ ខ្ញុំអត់បានដឹងច្បាស់លាស់ទេអាហ្នឹង។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់សួរសំណួរមួយទៀតពាក់ព័ន្ធទៅនឹងពាក្យដែលគេប្រើ

ប្រាស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយខ្ញុំចង់បង្ហាញជូនលោកនូវរបាយការណ៍ចំនួនពីរ គឺរបាយការណ៍ស្រុកត្រាំកក់ ឯកសារទី១គឺ E3/2453, ERN អង់គ្លេសមានលេខ 00388586, ខ្មែរមានលេខ 0027874 ហើយខ្ញុំមានឯកសារនៅក្នុងដៃរបស់ខ្ញុំ។ ប្រហែលជាខ្ញុំគិតថាអាចប្រគល់ឯកសារនេះជូនទៅសាក្សី គឺឯកសារ E3/2453។

លោកសាក្សីនេះគឺជារបាយការណ៍របស់ញ៉ៀងញ៉ង របស់ឃុំញ៉ៀងញ៉ង ហើយនៅក្នុងចំណុចកណ្ដាលនៃទំព័រហ្នឹង គឺខ្ញុំចង់អានជូនលោក គឺរបាយការណ៍របស់ឃុំញ៉ៀងញ៉ង គឺនិយាយថា “តាមការវិភាគរបស់ខ្ញុំគឺគេមានផែនការដើម្បីកម្ទេចបដិវត្តន៍របស់យើង”។ គឺស្ថិតនៅក្នុងទំព័រទី១ គឺនៅក្នុងប្រអប់ពណ៌លឿង។ ដូច្នេះ ខ្ញុំចង់សួរអំពីការវិភាគរបស់ខ្ញុំ ដែលថាគេចង់ៗកម្ទេចបដិវត្តន៍របស់យើង។ ខ្ញុំចង់សួរថាពាក្យថា “កម្ទេច” ហ្នឹងមានន័យយ៉ាងដូចម្ដេច?

[១៥:២២:០៨]

**ឆ៖** កម្ទេចនេះមានន័យថា “បំផ្លាញ”។

**ស៖** អ៊ីចឹងវាមានន័យដូចនឹង “សម្លាប់” ដែរ ឬមួយក៏យ៉ាងម៉េចដែរ? លោកចង់និយាយអ៊ីចឹងមែនទេ?

**ឆ៖** អត់មានន័យដូចសម្លាប់ទេ។ បំផ្លាញ។

**ស៖** ខ្ញុំសូមលើកឧទាហរណ៍មួយទៀត គឺឯកសារដែលមិនមាននៅក្នុងអ៊ីនធីហ្វេសនោះទេ។ ខ្ញុំនឹងដាក់បង្ហាញដោយយឺតៗនៅចំពោះមុខអង្គ-- គឺ E3/2053។ ភាសាអង់គ្លេសមានលេខ 00276578 ហើយភាសាខ្មែរមានលេខ 00079122។ ហើយខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់ឯកសារនេះជូនទៅសាក្សី។ ខ្ញុំមានឯកសារ ហើយខ្ញុំបានគូសជាបន្ទាត់ពណ៌ ដើម្បីឲ្យសាក្សីងាយយល់។

**លោក នីកូឡាស គូមជែន៖**

ដើម្បីជាកំណត់ត្រាប្រតិចារឹកខាងព្រះរាជអាជ្ញាពុំមានការជំទាស់នោះទេ។

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកព្រះរាជអាជ្ញា។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

យើងសូមរក្សាសិទ្ធិ។ គាត់បង្ហាញឯកសារមក យើង -- ដើម្បីឲ្យយើងអានសិន។ យើងត្រូវតែគោរពតាមវិធានរួមរបស់យើង។ តើយើងដឹងអំពីឯកសារហ្នឹងជាមុនទេ មុននឹងមេធាវីនេះចែកឯកសារ

ទៅឲ្យសាក្សី និងសួរសំណួរទៅកាន់សាក្សីនោះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងអានដោយយឺតៗ គឺ E3លើ -- គឺឯកសារ E3 ហើយខ្ញុំគិតថា -- ហើយព្រះរាជអាជ្ញាក៏គាត់បានជួយខាងយើងខ្ញុំដែរ។ ដូច្នេះ ខ្ញុំគិតថាប្រហែលជាខាងមេធាវីរដ្ឋប្បវេណីអាចមានឯកសារនេះនៅលើអេក្រង់បានហើយ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមការបំភ្លឺ អំពីចំណុចនេះ លោកប្រធាន។

[១៥:២៥:៣១]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៧:១៣]

**ប្រធានអង្គជំនុំ៖**

បាទឥឡូវនេះ មានការមិនជំទាស់ដោយសហព្រះរាជអាជ្ញា ហើយចំណែកឯមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានការចង់ឲ្យបង្ហាញ។ ហើយភាគីបានបង្ហាញហើយនូវលេខឯកសារ E3/20 -- /2053 ។ ហើយតើលោកស្រីមេធាវី ខាងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវការពេលវេលាពិនិត្យឯកសារហ្នឹងដែរឬទេ? ហើយបើត្រូវការប៉ុន្មាន រយៈពេលប៉ុន្មាន ដើម្បីអាចអង្គជំនុំជម្រះសម្រេច ហើយនិងឲ្យមានការសួរដេញដោលចំពោះពាក់ព័ន្ធនឹងឯកសារនេះ ដោយមេធាវី នួន ជា ចំពោះសាក្សី?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងកំពុងតែ*ដោនឡូត* ឯកសារហ្នឹងនៅលើអេក្រង់។ ក៏ប៉ុន្តែមេធាវីការពារក្តី គាត់អត់យល់អំពីគោលការណ៍ចំពោះមុខយើង គឺថាគាត់ត្រូវតែប្រាប់យើងមុនអំពីការប្រើប្រាស់ឯកសារនៅក្នុងសវនាការ។ អ៊ីចឹង យើងត្រូវការប៉ុន្មាននាទី ដើម្បីយើងដឹងអំពីឯកសារ យើងអាច*ដោនឡូត*ឯកសារហ្នឹង ដើម្បីអាចបង្ហាញជូនទៅសាក្សី។ នៅពេលដែលអង្គជំនុំជម្រះកំពុងតែពិភាក្សា ខ្ញុំបានបើកមើលឯកសារ ក៏ប៉ុន្តែខ្ញុំចង់ធ្វើយ៉ាងម៉េចឲ្យមានការគោរពវិធានរួមសម្រាប់យើងជាភាគីទាំងអស់គ្នា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយយើងព្យាយាមក្នុងការ -- មូលហេតុអីបានជាអង្គជំនុំជម្រះ ពេលដែលលោកមេធាវី វ៉ិចទ័រ កូប៉េ ដាក់ឯកសារដែលបង្ហាញថា ខ្លួនមិនបានដាក់នៅក្នុងអ៊ីនធីហ្វេសភ្លាម ពិតមែនតែឯកសារមានតិចទំព័រ អង្គជំនុំជម្រះយកបញ្ហានេះពិភាក្សា។

ទំនងជាដោយសារអង្គជំនុំជម្រះ មានបំណងឲ្យភាគីអនុវត្តឲ្យបានម៉ឺងម៉ាត់នូវសេចក្ដីណែនាំរបស់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានធ្វើចុងក្រោយ បន្ទាប់ពីបានពិនិត្យលើសេចក្ដីសម្រេចលើកមុនរបស់ខ្លួនកាលពីឆ្នាំ២០១១, ២០១២ ឯណោះ។ នេះគឺគោលបំណង ដើម្បីតម្រូវឲ្យគូភាគីអនុវត្តឲ្យបានទៀតទាត់ម៉ឺងម៉ាត់ នូវសេចក្ដីណែនាំរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងការដាក់ឯកសារនេះ។ ក្នុងករណីមិនបានដាក់ត្រូវបង្ហាញអំពីហេតុផលទាំងឡាយដែលខ្លួនមិនបានដាក់ ហើយសុំការអនុញ្ញាតពីអង្គជំនុំជម្រះជាមុន ហើយរួមទាំងភាគីផ្សេងទៀតហ្នឹងមានសិទ្ធិផ្ដល់មតិយោបល់មុននឹងអង្គជំនុំជម្រះសម្រេច។ ប៉ុន្តែបញ្ហាអម្បាញ់មិញនេះ វាប្លែកត្រង់ថាភាគីម្ខាងទៀត មានសហព្រះរាជអាជ្ញាមិនជំទាស់ទេ ហើយបញ្ហាខាងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទំនងក៏មិនជំទាស់ដែរ គ្រាន់តែលើកលែងហេតុផលបញ្ជាក់រំឭកឲ្យបានច្បាស់លាស់ អំពីការណែនាំអនុវត្តរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងបញ្ហានេះប៉ុណ្ណោះ។

[១៥:៣០:៣៧]

បាទ សូមរំឭកលោក កូប៉េ លើកក្រោយ គឺសូមប្រឹងប្រែងដើម្បីអនុវត្តតាមការណែនាំរបស់អង្គជំនុំជម្រះ។ សង្ឃឹមថាមិនមែនជាការអីធ្ងន់ពេកទេក្នុងការអនុវត្តកម្រិតប៉ុណ្ណោះ។ វាមានហេតុផលអង្គជំនុំជម្រះបានជម្រាបណែនាំភាគីរួចហើយ។

បាទ អង្គជំនុំជម្រះអនុញ្ញាតបន្តសំណួរនេះ ហើយសូមរំឭកថា វ៉ិចទ័រ កូប៉េ ថា ភាគីនេះមានតែកន្លះម៉ោងទៀត ហើយនិងស្អែក បើអាចតដល់ស្អែក គឺមានតែមួយវគ្គទេ គឺត្រឹមពេលចាប់ផ្ដើមរហូតដល់ពេលសម្រាកប៉ុណ្ណោះ ឲ្យច្បាស់លាស់ ព្រោះអម្បាញ់មិញនេះមានភ័ន្តច្រឡំថា មួយព្រឹកស្អែកមិនមែនទេ គឺមួយវគ្គ ត្រឹមពេលចាប់ផ្ដើមរហូតដល់ពេលសម្រាក នៅព្រឹកស្អែកប៉ុណ្ណោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់បញ្ជាក់បន្តិចថា ឯកសារនេះគឺជាឯកសារធម្មតាដែលកាលពីថ្ងៃទី២ ព្រះរាជអាជ្ញាបានយកមកសួរដែរ។ ដូច្នេះពេលខ្លះថា វាអាចមានបញ្ហាដែលថាខ្ញុំត្រូវប្រើប្រាស់ឯកសារនេះ។ ដូច្នេះចាំបាច់ត្រូវតែដឹងអំពីអ្វីដែលយើងចង់សួរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងទទួលស្គាល់ថាវាមានអ្វីកើតឡើង ប៉ុន្តែយើងត្រូវតែគោរពទៅតាមនីតិវិធី។ ហើយយើងបានបង្កើតនីតិវិធី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារ E3/2053 ហើយសូមអនុញ្ញាតពីលោកប្រធានផងដែរ។ ហើយខ្ញុំចង់សូមឲ្យលោកពិនិត្យទៅលើឃ្លាដែលខ្ញុំបានគូសពណ៌ទឹកក្រូច។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

*(សាក្សីពិនិត្យមើលឯកសារ)*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី នេះគឺជារបាយការណ៍ពីត្រពាំងធំខាងត្បូង ហើយខ្ញុំចង់ឲ្យលោកពិនិត្យមើលទៅលើឯកសារមានលេខ 00276578 ហើយចំពោះភាសាខ្មែរនៅចំពោះមុខរបស់លោកហើយ នៅផ្នែកកណ្តាល គឺកថាខណ្ឌទី៣ គឺបាននិយាយដូចតទៅនេះ៖ "ផែនការរបស់វាមានដូចតទៅ ឯកសារនេះគឺនិយាយអំពីបុគ្គលបួនរូប ដែលមានផែនការ។ ទី១ ផែនការ៥ឆ្នាំរបស់វា គឺកម្ទេចសហករណ៍ឲ្យបាន បើ៥ឆ្នាំកម្ទេចមិនបានទៅ៧ឆ្នាំ បើ៧ឆ្នាំកម្ទេចមិនបាន គឺមានផែនការបន្តទៅទៀត ធ្វើយ៉ាងម៉េចឲ្យសហករណ៍ហិនហោច និងប្រឆាំងដាច់ខាតលើបាយរួម"។ ដូច្នេះ ខ្ញុំចង់សួរលោកនូវសំណួរដ៏សាមញ្ញ ហើយខ្លីមួយ តើពាក្យ "កម្ទេច" នៅក្នុងពេលនេះ នៅក្នុងបរិបទនេះ តើលោកយល់ថាពាក្យកម្ទេចនៅត្រង់ចំណុចនេះមានន័យយ៉ាងដូចម្តេចដែរ?

**លោក នាង អ៊ួច៖**

**ឆ៖** មានន័យបំផ្លាញដែល បំផ្លាញសហករណ៍។

[១៥:៣៤:២២]

**ស៖** សូមអរគុណលោកសាក្សី។ ហើយប្រធានបទចុងក្រោយរបស់ខ្ញុំៗ គឺទាក់ទងទៅនឹងការអប់រំ ការបង្រៀន។ តាមដែលខ្ញុំដឹង គឺលោកមានតួនាទីជាអ្នក -- គ្រូបង្រៀនមុនរបបកម្ពុជាប្រជាធិប-តេយ្យផងដែរ។ តើលោកអាចប្រាប់បានទេ ថាតើគោលដៅ ឬក៏គោលបំណងនៃការអប់រំ ឬក៏ការបង្រៀននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺមានគោលដៅអ្វីដែរ? តើលោកអាចប្រាប់យើងឲ្យបានដឹង

អំពីគោលដៅ ឬក៏គោលបំណងជាទូទៅនៃការអប់រំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានដែរឬទេ?

**ឆ៖** គាត់ លោកមេធាវីសួរខ្ញុំឲ្យបានច្បាស់លាស់បន្តិច ព្រោះថាការអប់រំ ឬការបង្រៀននេះ សំដៅទៅលើការអប់រំ ឬការបង្រៀនទៅលើអ្នកណា?

**ស៖** ខ្ញុំនឹងបញ្ជាក់ឲ្យលម្អិតបន្តិច។ ខ្ញុំចង់សួរថា ថាតើគោលដៅនៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យពាក់ព័ន្ធទៅនឹងការបង្រៀនក្មេងតូច ឬក៏ក្មេងៗធំៗ ឬក៏ជាសិស្សជាដើមនោះ។ ថាតើអាជ្ញាធរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងគេចង់បានអ្វីពីការបង្រៀន ឬក៏ពីការរៀនសូត្រនោះ?

**ឆ៖** បង្រៀនកុមារ បង្រៀនក្មេងៗ ទី១ គឺថាបង្រៀនអក្សរឲ្យចេះសរសេរ ចេះអាន។ ទី២ គេបង្រៀនគេអប់រំឲ្យស្រលាញ់បដិវត្តន៍ ស្រលាញ់កម្ពុជាប្រជាធិបតេយ្យ ឲ្យចេះខំធ្វើការ ចេះ -- ឲ្យធ្វើឲ្យបានរីកចម្រើននៅក្នុងភូមិ ក្នុងឃុំរបស់ខ្លួន នៅក្នុងសហករណ៍របស់ខ្លួន។ គោលបំណងគឺមានអ៊ីចឹង។ ហើយវាមានច្រើនទៀត គោលបំណងចង់ឲ្យកុមារមានចិត្តមានគំនិតល្អត្រឹមត្រូវ សីលធម៌ល្អ ស្លូតបូតវាបសា មិនប្រកាន់អាកប្បកិរិយាជាអ្នកភ្លើតភ្លើន ជាអ្នកពាលាអាវ៉ាសែ។ ខ្ញុំសូមអស់។

[១៥:៣៧:៣៧]

**ស៖** អ៊ីចឹង តើគោលដៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺរៀបចំការបណ្តុះបណ្តាលបឋមសិក្សា មធ្យមសិក្សា ហើយនិងបង្កើតនូវសាកលវិទ្យាល័យ។ អ៊ីចឹងគឺមានន័យថា តាមដែលលោកចាំនៅក្នុងកម្ពុជាប្រជាធិបតេយ្យគឺថា គេមានគោលដៅដើម្បីអប់រំទៅដល់ប្រជាជន ឧទាហរណ៍អប់រំ អំពីគណិតវិទ្យា អំពីភាសាអីដែរឬទេ? តាមដែលលោកចាំនោះ?

**ឆ៖** នៅសម័យដែលខ្ញុំនៅត្រាំកក់ មានការបង្រៀន មានកម្មវិធីបង្រៀនដល់កុមារ មានពីរ អក្សររៀនលេខ រៀនអក្សរ តែភាសាមិនមានទេ ព្រោះនៃវាទើបនឹងចាប់ផ្តើមថ្មីៗ។ លេខ អក្សរ មានភូមិវិទ្យាៗខ្លះដែរ។ ថ្នាក់៣ឆ្នាំ ឬ៤ឆ្នាំទៅមានភូមិវិទ្យាខ្លះដែរ។ ហើយមានជា សៀវភៅៗបង្រៀនអក្សរ សៀវភៅគណិតវិទ្យាក៏មានដែរ។ គណិតវិទ្យានៅក្នុងលេខ ហ្នឹងហើយបាទ។ សូមអស់។ តែភាសាមិនទាន់មានទេលោកមេធាវី។ រៀនភាសាបរទេសមិនទាន់មានទេ។ តែពេលដែលៗប្រជាជនរត់ទៅដល់ព្រំដែន គឺមានរៀនៗភាសា ភាសាអង់គ្លេស ភាសាថៃ។ ហ្នឹងកម្ពុជាប្រជាធិបតេយ្យមានគោលនយោបាយបង្រៀនអ៊ីចឹង។

**ស៖** លោកមានជំហរ ឬក៏តួនាទីអ្វីនិយាយអំពីជំហរក្នុងការបង្រៀននៅក្នុងសម័យខ្មែរក្រហមទេ។ តើមានគ្រូបង្រៀនគ្រប់គ្រាន់ទេ ឬក៏លោកព្យាយាមស្វែងរកគ្រូបង្រៀនដើម្បីឲ្យបង្រៀនបាននោះ

តើលោកអាចរៀបរាប់លម្អិតបន្តិចទេ អំពីគោលបំណងបង្រៀននេះ?

**ឆ៖** ភាគច្រើនគ្រូបង្រៀននៅខាងត្រាំកក់ ភាគច្រើនជានារីទេ ជានារី កម្លាំងនារី ហើយការបណ្តុះបណ្តាលអី គឺមានការបណ្តុះបណ្តាលអំពីបច្ចេកទេស អំពីចិត្តវិទ្យាអីខ្លះដែរ ចិត្តវិទ្យា អំពីបច្ចេកទេសក្នុងការបង្រៀនយ៉ាងម៉េចៗគឺថាមានការបណ្តុះបណ្តាល មានការអប់រំដល់គ្រូៗក្នុងការមួយខែម្តង ឬមួយត្រីមាសម្តងបាទ។ សូមជ្រាប។

[១៥:៤១:១៦]

**ស៖** ពេលដែលលោកធ្វើជាគ្រូបង្រៀនក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តើមានហេតុផលណាដែលគួរឲ្យភ័យខ្លាច តើគ្រូបង្រៀនត្រូវបានគេគំរាមកំហែងដែរឬទេក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ចម្លើយមួយដែលឆ្លើយថាខ្ញុំធ្វើគ្រូបង្រៀន ហើយទទួលគ្រូ១០៥នាក់ហ្នឹង ខ្ញុំមិនបានៗ ធ្លាប់ទទួលអីចឹងទេ។ ក៏ប៉ុន្តែគ្រូបង្រៀននៅស្រុកត្រាំកក់នេះ មិនមានអ្នកណាមានការភ័យខ្លាចអីអំពីនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យទេ គេរស់នៅតាមសហករណ៍ធម្មតា គេធ្វើការងារតាមសហករណ៍ធម្មតា។

**ស៖** លោកសាក្សី ដែលថាបន្ទាប់ពីឆ្នាំ១៩៧៩ លោកនៅតែជាបុគ្គលមួយសកម្មភាព ឬក៏មានសភាពនៅក្នុងវិស័យអប់រំ។ ខ្ញុំសូមអានសំណួរចម្លើយលេខ១០២របស់លោក សំណួរដោយអ្នកស៊ើបអង្កេតដូចតទៅនេះថា "ឥឡូវនេះ លោករស់នៅសំឡូត តើលោកមានតួនាទីអ្វីនៅក្នុងបក្ស ឬក៏មន្ត្រីរាជការអីទេ?" លោកឆ្លើយថា៖ អត់ទេ។ ក្នុងឆ្នាំ១៩៨៥ ខ្មែរក្រហមហៅខ្ញុំទៅសំឡូត ហើយខ្ញុំគេឲ្យទទួលខុសត្រូវផ្នែកអប់រំនៅសំឡូត។ នៅពេលដែលមានកម្មវិធីធ្វើសមាហរណកម្មនៅ៩៦ រដ្ឋាភិបាលដឹកនាំដោយសម្តេច ហ៊ុន សែន គឺចាត់តាំងឲ្យខ្ញុំធ្វើជាប្រធានយុវជន -- ប្រធានអប់រំយុវជន និងកីឡានៅសំឡូត"។ តើនេះពិតជាចម្លើយដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេតមែនទេ?

[១៥:៤៣:៣៦]

**ឆ៖** បាទត្រឹមត្រូវហើយ។ ពេលឆ្នាំ១៩៨៥ ខ្ញុំត្រូវកម្ពុជាប្រជាធិបតេយ្យហៅខ្ញុំឲ្យទៅនៅសំឡូត ហើយប្រគល់នាទីនេះឲ្យខ្ញុំទទួលខាងផ្នែកអប់រំ ទទួលខុសត្រូវផ្នែកអប់រំ បើថាភាសាឥឡូវ គេហៅអប់រំយុវជននិងកីឡាក្នុងស្រុកសំឡូតនេះទាំងមូល។ ហើយបន្ទាប់មក ដល់ពេលធ្វើសមាហរណកម្មជាមួយនឹងរដ្ឋាភិបាល រដ្ឋាភិបាលបានចាត់តាំងខ្ញុំជាប្រធានអប់រំយុវជននិងកីឡាស្រុកសំឡូត។ បារាំងហៅថា *សេហ្វសិចទ័រ*។ តែពេលនោះ ក្រោយថ្ងៃ០៥ ថ្ងៃ០៦ កក្កដា ៩៧ ខ្ញុំត្រូវរត់ទៅជំរំនៅក្នុង

ប្រទេសថៃទៅ ហើយវិលត្រឡប់មកវិញៗ ៩៨-៩៩ ក៏គេឆូតឈ្មោះខ្ញុំចោល លុបឈ្មោះខ្ញុំចោលអំពីប្រធានអប់រំយុវជន និងកីឡានេះទៅ។ សូមចប់។

**ស៖** អរគុណលោកសាក្សី។ តើលោកអាចធ្វើការប្រៀបធៀបអំពីស្ថានភាពនៃវិស័យអប់រំនៅក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៩៦-៩៧ ហើយនិងស្ថានភាពអប់រំទូទៅនៅក្នុងសម័យកម្ពុជាប្រជាធិប-តេយ្យ។ លោកអាចធ្វើការប្រៀបធៀបតើវាមានលក្ខណៈខុសគ្នាទេ ឬក៏ថាវិស័យអប់រំនេះមានលក្ខណៈដូចគ្នា?

**ឆ៖** ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ មុនចូលសមាហរណកម្មជាមួយរដ្ឋាភិបាល ហើយនិងសម័យដែលរដ្ឋាភិបាលបច្ចុប្បន្ននេះ កាន់កាប់ខាងផ្នែកសិក្សាអប់រំ -- សុំទោសលោកមេធាវីខ្ញុំមិនដែលបានទទួលដឹងអំពីបញ្ហានេះទេ។ ប៉ុន្តែសម័យដែលខ្ញុំមកសំឡូតនេះ មកនៅសំឡូត៩៥ គឺការអប់រំការបង្រៀនដល់សិស្ស គឺមានភាពល្អច្រើនដែរ គឺរៀនទាំងព្រឹកទាំងល្ងាច។ តែកម្មវិធីឥឡូវនេះ មានរៀនសិស្សរៀនបានព្រឹក ហើយសិស្សខ្លះបានរៀនតែល្ងាច។ សាលាមានច្រើន ក៏ប៉ុន្តែកម្មវិធីបង្រៀននេះមានបានប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

ទំនងសំណួរនេះ លោកដូចចាកសំណួរ។ សំណួរនេះគឺសួរអំឡុង៩៥-៩៦ ហ្នឹងធៀបជាមួយនឹងការអប់រំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ៣ឆ្នាំ ៨ខែ ២០ថ្ងៃ។

[១៥:៤៧:១២]

**លោក នាង អ៊ួច៖**

**ឆ៖** បាទ ន៎ែ ប្រៀបធៀបសម័យ៣ឆ្នាំ និងសម័យឆ្នាំ៩៥-៩៦។ សម័យ៣ឆ្នាំមានភាព មានៗសៀវភៅអីបានច្បាស់លាស់ ហើយមកឆ្នាំ៩៥-៩៦ នេះក៏មានសៀវភៅបានច្បាស់លាស់ដែរ។ សាលារៀនមានភាពល្អនៅឆ្នាំ៩៥-៩៦ មានភាពល្អច្រើន មានផ្ទះសម្បែង មានតុ មានអីបានល្អត្រឹមត្រូវ។ ឯសម័យ៣ឆ្នាំ រៀនក្រោមដើមឈើ រៀនអីចឹងទៅ តាមដែលៗមានតាមលទ្ធភាព។ ឯមានកន្លែងខ្លះមានផ្ទះសម្បែងមានសាលា មានតុ មានអីចឹងមានមែន។ តែបើយើងប្រៀបធៀបទៅសម័យ ៩៥-៩៦ --ដោយឡែកទេ ដោយឡែកខ្ញុំនៅសំឡូតទេ តែទូទាំងប្រទេសខ្ញុំអត់ដឹងទេ។ ៩៥-៩៦ នៅសំឡូតវាល្អជាងសម័យ៣ឆ្នាំ ការសិក្សាអប់រំ។ ហើយខ្ញុំទទួលខាងផ្នែកអប់រំយុវជន និងកីឡាស្រុកហ្នឹង គឺក្នុងកន្លះខែម្តងខ្ញុំអញ្ជើញ គ្រូៗទាំងអស់មកប្រជុំដកពិសោធអំពីការងារសិក្សាអប់រំនៅសម័យឆ្នាំ៩៥-៩៦ នេះឯង។

សូមអស់លោកមេធាវី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរខ្ញុំចុងក្រោយ ពាក់ព័ន្ធទៅនឹងវិស័យអប់រំនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថាផលប៉ះពាល់ពីសង្គ្រាមស៊ីវិលវាយ៉ាងម៉េចដែរ? សង្គ្រាមរំដោះជាតិ? គឺតាំងពីឆ្នាំ១៩៧០ ដល់ ៧៨ តើសង្គ្រាមស៊ីវិល វាប៉ះពាល់ទៅដល់វិស័យអប់រំ ប៉ះពាល់ដល់អគារសិក្សាជាដើម។ល។ ដូចម្ដេចដែរ?

**ឆ៖** សង្គ្រាមពី៧០ -- លោកសួរ ៧៥ -- ៧០ ដល់ ៧៥ មែនទេ?

**ស៖** តាមដែលលោកដឹង ហើយយើងទាំងអស់ដឹងហើយ គឺថាសង្គ្រាមស៊ីវិលអូសបន្លាយរហូតមកដល់ឆ្នាំ១៩៧៥ តើលោកមានអ្វីដែលអាចនិយាយបានអំពីផលប៉ះពាល់បីសង្គ្រាមទៅលើវិស័យអប់រំទៅលើអគារសិក្សា ទៅលើរចនាសម្ព័ន្ធអប់រំដែរឬទេ?

[១៥:៥០:១៦]

**ឆ៖** សង្គ្រាមពី៧០ទៅ៧៥ រយៈពេល៥ឆ្នាំជាង។ ដូច្នេះប៉ះពាល់ធំធេងណាស់ដល់វិស័យសិក្សាអប់រំ សាលារៀនខ្ទេចខ្ទី ភូមិឋាន វត្តលោកសង្ឃ ហើយក្មេងៗពេលនោះ ដល់អស់អីចឹងទៅត្រូវការបង្រៀនក្មេង គឺនៅក្រោមដើមឈើខ្លះ ហើយនិងសង់ផ្ទះប្រក់ស្បូវ ប្រក់ស្លឹកត្នោត ដែលតាមលទ្ធភាពធ្វើតុពីឫស្សី ពីឈើអី បើតាមលទ្ធភាពកន្លែងដែលធ្វើបាន។ ដូច្នេះសង្គ្រាម៥ឆ្នាំ គឺប៉ះពាល់យ៉ាងធំធេងដល់ប្រទេសកម្ពុជាយើង។ ហ្នឹងខ្ញុំនិយាយដោយឡែកនៅខេត្តតាកែវ តែទូទាំងប្រទេសខ្ញុំមិនបានដឹងទេ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ តើវាជាគោលបំណងរបស់ -- តើកម្ពុជាប្រជាធិបតេយ្យមានគោលបំណងកសាងវិស័យអប់រំឡើងវិញឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ដើម្បីរៀបចំអំពីមហន្តរាយដោយសារសង្គ្រាមដែរឬទេ? តើពាក់ព័ន្ធនឹងវិស័យអប់រំកម្ពុជាប្រជាធិបតេយ្យមានគោល-បំណងយ៉ាងដូចម្ដេចដែរ?

**ឆ៖** បន្ទាប់ពីចប់សង្គ្រាម៥ឆ្នាំទៅ កម្ពុជាប្រជាធិបតេយ្យមានគោលបំណង វិស័យខាងសិក្សាអប់រំនេះ គឺមានគោលបំណងធំធេងណាស់ ខិតខំរៀបចំសាលារៀនថ្មីៗ ខិតខំប្រមែលប្រមូលសិស្សឲ្យចូលរៀនឡើងវិញ ហើយនិងមានគ្រូ ខិតខំអប់រំគ្រូ បង្រៀនគ្រូ ឲ្យចេះខាងគរុកោសល្យបង្រៀនសិស្ស។ ហ្នឹងនេះគឺជាគោលបំណងរបស់កម្ពុជាប្រជាធិបតេយ្យពេលនោះ ហើយនិងមានគោលបំណងធំធេងច្រើនទៀតក្នុងវិស័យអប់រំនេះ។ ហ្នឹងខ្ញុំសូមជម្រាបប៉ុណ្ណឹងលោកមេធាវី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

ពេលវេលានៅសល់តិចតួច ប៉ុន្តែយើងសម្រេចបំពេញកិច្ចដែលយើងបានធ្វើ បានជម្រាបជូនភាគី កាលពីព្រឹកមិញ។ ហើយបញ្ហានេះពាក់ព័ន្ធជាមួយនឹងសំណើសុំរបស់ការិយាល័យសហព្រះរាជអាជ្ញា ឯកសារ E319/7។ ហើយព្រឹកមិញគឺ មេធាវីការពារក្តី -- រសៀលៗ គឺមេធាវីការពារក្តីលោក នួន ជា បានឆ្លើយបញ្ជាក់រួចហើយលើបញ្ហានេះ។

ឥឡូវនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ធ្វើសារណាតប ទៅនឹងសំណើសុំរបស់ការិយាល័យសហព្រះរាជអាជ្ញាលើសំណើសុំស្តាប់សក្ខីកម្មសាក្សីថ្មី តាមឯកសារ E319/7 តើមានមតិយោបល់យ៉ាងម៉េចដែរ? អ៎! ខៀវ សំផន – មេធាវី ខៀវ សំផន!

បាទ មេធាវី នួន ជា គាត់បានឆ្លើយបញ្ជាក់ជំហររួចច្បាស់លាស់ហើយណ៎ះ! ថាគាត់មិនជំទាស់ តវ៉ាទេ ហើយគាត់សុំឲ្យធ្វើស្តាប់សក្ខីកម្មសាក្សីនោះបានឆាប់ទៀតផង។

[១៥:៥៤:២៥]

**លោក អាកឡូវ វែកគែន៖**

បាទលោកប្រធាន ពាក់ព័ន្ធទៅនឹងបញ្ហាដែលបានចោទឡើងនោះ ចម្លើយជាលាយលក្ខណ៍អក្សរ របស់គាត់ត្រូវបានយកមកប្រើប្រាស់ជាច្រើនរួចមកហើយនៅក្នុងសវនាការយើងនេះ។ ដូច្នេះ យើងអត់ មានអីជំទាស់ទៅនឹងការកោះហៅបុគ្គលរូបនេះឲ្យមកផ្តល់សក្ខីកម្មនោះទេ ពីព្រោះថាយើងគោរពទៅ តាមវិធាន៨៤ យើងគោរពទៅតាមគោលការណ៍ចំពោះមុខ។ ប្រសិនបើអង្គជំនុំជម្រះសម្រេចកោះហៅ សាក្សីរូបនេះមកផ្តល់សក្ខីកម្មនោះ អង្គជំនុំជម្រះត្រូវផ្តល់ពេលវេលាដើម្បីឲ្យយើងខ្ញុំអាចអានឯកសារ -- ដុំឯកសារទាំង១៦ ដែលបានដកចេញពីសំណុំរឿង០០៣, ០០៤ ដែលបានបញ្ជូនមកខាងយើងខ្ញុំដោយ ការិយាល័យសហព្រះរាជអាជ្ញា។ ហើយឯកសារហ្នឹងគឺច្រើនមែនទែន យើងត្រូវការពេលវេលាច្រើន ដើម្បីអានផងនិងវិភាគផង។ ដូច្នេះ ប្រហែលជានឹងមានសាក្សីជាច្រើនទៀតដែលនឹងលើកឡើងនូវបញ្ហា ដូចគ្នាទៅនឹងបញ្ហាដែលបានលើកឡើងដោយសាក្សី ដែលយើងលើកឡើងអម្បាញ់មិញនេះ។

ដូច្នេះ ដើម្បីឲ្យយើងអាចសួរដេញដោលឲ្យបានល្អនោះ មេធាវីការពារក្តីត្រូវ -- គួរតែអាចមាន ពេលវេលាដើម្បីអានទៅលើឯកសារទាំងអស់នេះ។ មិនត្រឹមតែសក្ខីកម្មរបស់សាក្សីដែលយើងនិយាយ

អម្បាញ់មិញនេះទេ គឺសក្ខីកម្មរបស់សាក្សីផ្សេងទៀតដែលបានបញ្ជូនមកទល់នឹងថ្ងៃនេះដោយសហព្រះរាជអាជ្ញា។ ហើយវាអាចនឹងពាក់ព័ន្ធទៅនឹងប្រធានបទដូចគ្នា។

ពាក់ព័ន្ធទៅនឹងបញ្ហានេះដដែល កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុននៅរសៀល នៅពេលដែលអង្គជំនុំជម្រះធ្វើកិច្ចប្រជុំរៀបចំសវនាការ ស្តីអំពីបញ្ហាឯកសារទាំង១៦ដុំដែលបញ្ជូនមកដោយសហព្រះរាជអាជ្ញា យើងបានស្នើសុំរយៈពេលមួយដើម្បីឱ្យយើងអាចធ្វើការវិភាគ និងអានទៅនឹងឯកសារទាំងអស់នេះ។ បន្ទាប់មកនៅថ្ងៃ មួយថ្ងៃបន្ទាប់មកទៀតនោះ លោក គេន រ៉ូប៊ីត ដែលជាមន្ត្រីច្បាប់ជាន់ខ្ពស់បានផ្ញើអ៊ីម៉ែលមួយមកពាក់ព័ន្ធទៅនឹងបញ្ហានេះ ហើយខ្ញុំសូមការបំភ្លឺរឿងហ្នឹង។ នៅក្នុងអ៊ីម៉ែលនោះមានការបញ្ជាក់ថាអង្គជំនុំជម្រះនឹងមិនលើកពេលធ្វើសវនាការកោះហៅសាក្សីនោះទេ។ ពីព្រោះថាសំណើនុំងលើកមកយឺតពេលទៅហើយៗបុគ្គលនោះជាជនចាស់ជរា ហើយគាត់រស់នៅឆ្ងាយពីទីក្រុងភ្នំពេញ។

[១៥:៥៧:៤៥]

បន្ទាប់មកក៏មានការបញ្ជាក់ផងដែរថា សាក្សី948 ក៏ត្រូវស្តាប់សក្ខីកម្ម ក៏ប៉ុន្តែអត់មានបញ្ជាក់នៅក្នុងអ៊ីម៉ែលហ្នឹងថាហេតុអ្វីទេ។ ហេតុអ្វីបានជាសាក្សីរូបនោះនឹងត្រូវមកផ្តល់សក្ខីកម្មនោះ។ អ៊ីចឹងខ្ញុំមិនដឹងថាហេតុអ្វីក៏មិនមានការបញ្ជាក់អំពីមូលហេតុនោះទេ។ ដូច្នេះ ខ្ញុំយល់ថាសំណើដែលភាគីបានដាក់នៅពេលរៀបចំសវនាការនោះ គឺថាត្រូវបានបដិសេធចោល។ ដូច្នេះកាលនោះ អង្គជំនុំជម្រះបញ្ជាក់ថាសាក្សីនឹងត្រូវមកផ្តល់សក្ខីកម្មនៅរក្សាទុកសក្ខីកម្មនូវការកោះហៅដដែល ហើយដោយមិនមានការបញ្ជាក់ពីមូលហេតុទេ។ ដូច្នេះ ខ្ញុំមិនដឹងអំពីគោលជំហរច្បាស់លាស់របស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងសំណើដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនោះទេ។

ដូចដែលយើងទាំងអស់គ្នានៅទីនេះដឹងហើយថា នៅក្នុងការផ្ញើលិខិតឆ្លើយឆ្លងនៅថ្ងៃបន្ទាប់មកទៀតនោះ គឺនិយាយអំពីការបរិច្ឆេទនៃវិស្សមកាលតុលាការ។ ហើយអង្គជំនុំជម្រះបានបញ្ជាក់ថា ភាគីអាចឆ្លៀតពេលនៅពេលដែលអង្គជំនុំជម្រះមិនធ្វើសវនាការនោះ ដើម្បីធ្វើការទៅលើភស្តុតាងថ្មីដែលបានផ្តល់ជូន។ ខ្ញុំមិនដឹងថាតើអង្គជំនុំជម្រចង់និយាយអំពីអ្វីទេ នៅពេលដែលនិយាយអំពីភស្តុតាងថ្មីដែលនឹងត្រូវផ្តល់ជូននោះ។ នៅពេលដែលខ្ញុំអានអត្ថបទនោះទៅ ខ្ញុំមើលឃើញថាវាពាក់ព័ន្ធទៅនឹងឯកសារទាំង១៦ដុំ ដែលបានផ្តល់ជូននោះ។ ហើយខ្ញុំសូមនិយាយម្តងទៀតថា យើងទាមទារឱ្យមានពេលវេលា៦សប្តាហ៍ ដើម្បីឱ្យយើងអាចអាន ក៏ដូចជាការវិភាគទៅលើឯកសារទាំងអស់នុំង។

[១៥:៥៩:៥២]

ជាចុងក្រោយខ្ញុំសូមរំឭកថា ការភ័យខ្លាចរបស់មេធាវីការពារក្ដីលោក ខៀវ សំផន នៅក្នុងស្ថានភាពដូចដែលយើងជួបប្រទះថ្ងៃនេះ គឺថា គឺមានការអនុវត្តនូវវិធីសាស្ត្រដដែលៗដូចក្នុងសំណុំរឿងទី១ដែរ គឺអង្គជំនុំជម្រះបានសម្រេចរួចទៅហើយ នៅពេលដែលយើងកំពុងធ្វើសារណាបញ្ចប់ការពិភាក្សាដេញដោលចុងក្រោយ។ ហើយអង្គជំនុំជម្រះបញ្ជាក់ថាឯកសារ១៥០០ ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់។ ហើយការសម្រេចនេះ គឺបានធ្វើរួចមកហើយ ហើយយើងក៏បានធ្វើបណ្ដឹងសាទុក្ខពាក់ព័ន្ធចំណុចៗនេះដែរ។ ក៏ប៉ុន្តែអង្គជំនុំជម្រះ ទន្ទឹមនឹងនោះក៏បានលើកឡើងផងដែរថាការស៊ើបអង្កេតទៅលើសំណុំរឿង០០៣, ០០៤ កំពុងតែបន្តរហូត។ ដូច្នេះអង្គជំនុំជម្រះមិនអាចគ្រប់គ្រងនូវភាពមិនច្បាស់លាស់ ពាក់ព័ន្ធទៅនឹងការបញ្ជូនឯកសារបន្ថែមមកទៀតនោះទេ។

ហើយដូច្នេះ វាអាចមានកំណត់ហេតុជាច្រើនដែលនឹងផ្ទេរមកចូលសំណុំរឿង០០២ យើងនេះ។ ដូច្នេះ ខ្ញុំគិតថាចំណុចនេះដូចជាមិនសមហេតុផលទេ។ នៅក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្ដីដោយយុត្តិធម៌នោះ យើងមិនអាចនិយាយថាអាចមានភស្តុតាងថ្មី ហើយត្រូវយើងបើកចំហយកភស្តុតាងថ្មីមកអ៊ីចឹងរហូតទេ។ យើងត្រូវតែសម្រេចឲ្យមានវិធានច្បាស់លាស់ទៅតាមលំដាប់លំដោយកាលបរិច្ឆេទ ត្រូវកំណត់កាលបរិច្ឆេទឲ្យច្បាស់មួយ។ យើងមិនត្រូវបើកចំហទទួលភស្តុតាងថ្មីរហូតអ៊ីចឹងទេ។

[១៦:០១:៥៣]

**ប្រធានអង្គជំនុំ៖**

ហើយអានោះជាកម្មវត្ថុដែលអង្គជំនុំជម្រះ កំណត់ឲ្យលោកនិយាយនៅក្នុងអំឡុងពេលប្រជុំធី.អឹម.អឹម កន្លងមក។ លោកមិនបានចូលរួមប្រជុំពិភាក្សាទេ។ ថ្ងៃនេះ អង្គជំនុំជម្រះបានកំណត់ពេលវេលាខ្លី ហើយឲ្យភាគីនិយាយពាក់ព័ន្ធទៅនឹងការសំណើសុំរបស់ អូ.ស៊ី.ភី លើឯកសារ E319/7 នៅក្នុងការស្ដាប់សក្ខីកម្មសាក្សីថ្មី ទំនងជាមួយរូបទេ។ ដូច្នេះបញ្ហាដទៃទៀត លោកហាក់ដូចជាលើកឡើងវិញនូវអ្វីដែលអង្គជំនុំជម្រះបានស្ដាប់ភាគីពិភាក្សាដេញដោល ជជែកវែកញែកគ្នានៅក្នុងកិច្ចប្រជុំ ធី.អឹម.អឹម រួចហើយ។ ទី២ ចំពោះសាក្សី TCW-948 ពុំមែនជាកម្មវត្ថុនៃការសុំលើកស្ដាប់ -- ធ្វើសវនាការរបស់មេធាវី នួន ជា ទេ។ មេធាវី នួន ជា លើកឡើងតែសាក្សីពីរទេ គឺ TCW-803 និង 809។ យើងអង្គជំនុំជម្រះបានពិចារណា ហើយបានជូនដំណឹងទៅភាគី ដោយសារបញ្ហាប្រឈមនឹងវ័យចាស់ ហើយនិងគាត់នៅឆ្ងាយ។ បញ្ហានេះ គឺមានការសុំទទូចពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ អំពីហេតុផលថាសូមឲ្យស្ដាប់សក្ខីកម្មសាក្សីរូបនេះ នៅក្នុងអំឡុងពេលនេះ ពីព្រោះការធ្វើដំណើរទៅមកហ្នឹង ទៅ៣ថ្ងៃ

មក៣ថ្ងៃ ហើយគាត់មានបញ្ហាសុខភាពវ័យចាស់ផង។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះបានសម្រេចទៅ។ ហើយម្ចាស់សំណើចម្បងគឺ នួន ជា លោកមិនបានតវ៉ាទេ រហូតដល់ម៉ោងនេះ។ ហើយបានស្ដាប់សក្ខីកម្ម បានសួរដេញដោលរហូតចប់ហើយ។ ដូច្នេះ លោកដូចជាយកពេលវេលាដែលយើងបានកំណត់របៀបវារៈដែលអនុញ្ញាតឲ្យនិយាយនេះ ក្របខ័ណ្ឌតែលើសំណើសុំរបស់ អូ.ស៊ី.ភី ឯកសារ E319/7 ប៉ុណ្ណោះ។ យើងស្ដាប់ច្រើនហើយ ហើយដូចជារឿងច្រំដែល ដែលរបៀបវារៈនេះអង្គជំនុំជម្រះបានដាក់ជជែកនៅក្នុងកិច្ចប្រជុំ ធី.អឹម.អឹម រួចហើយ។

លោកមានបញ្ហាអីពាក់ព័ន្ធជាមួយនឹងរឿងឯកសារ E319/7 ទៀតទេ? បើមិនមានអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកលើកឡើងដូច្នោះតទៅទៀតទេ។ នៅភាគីមួយទៀត ដែលនឹងត្រូវការពេលវេលាដើម្បីធ្វើសារណាជាផ្ទាល់មាត់ ដើម្បីបញ្ជាក់លើសំណើនេះ។

[១៦:០៥:៤២]

អង្គជំនុំជម្រះសូមជម្រាបជូនលោកថា ក្រោយពីបានស្ដាប់ភាគីនិងកិច្ចប្រជុំរៀបចំនេះ គឺអង្គជំនុំជម្រះបានយកបញ្ហានេះទៅពិចារណា ប្រជុំពិភាក្សាគ្នារួចហើយ ប៉ុន្តែអង្គជំនុំជម្រះ -- មូលហេតុសព្វថ្ងៃនេះកំពុងតែត្រៀមរៀបចំដើម្បីចេញសេចក្ដីសម្រេច។ ដោយសារមូលហេតុអី? បញ្ហាពាក់ព័ន្ធជាមួយនឹងខាងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលជាភារកិច្ចរបស់គាត់ ដែលជាពាក់ព័ន្ធជាមួយនឹងកិច្ចការរបស់គាត់ត្រូវធ្វើ។ ហើយយើងបានសូមពិគ្រោះយោបល់ជាមួយគាត់ ដើម្បីឲ្យគាត់ផ្ដល់ និងបើកផ្លូវមួយចំនួនតាមសំណើសុំរបស់ភាគី ដើម្បីមានលទ្ធភាពមើលឯកសារ។ ឥឡូវរហូតដល់ម៉ោងនេះគាត់មិនទាន់ឆ្លើយតបយើងទេ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះនេះ គឺព្រឹកមិញ រហូតដល់អាចយឺត ៥នាទី ដោយសារយើងប្រជុំតាំងពីម៉ោងប្រាំបីកន្លះ ដើម្បីធ្វើកិច្ចការនេះ។ ប៉ុន្តែយើងមិនអាចរកច្រកចេញនៅឡើយទេ ដោយសារយើងរង់ចាំលទ្ធផលនៃការបង្ហាញ ការឆ្លើយតបរបស់ខាងសហចៅក្រមស៊ើបអង្កេតអន្តរជាតិលើបញ្ហានេះ ដើម្បីយើងមានមូលដ្ឋានថាឆ្លើយទៅរបៀបណាលើបញ្ហាសេចក្ដីសម្រេចនេះ។ យើងជឿថាប្រសិនបើ យើងមិនអាចធ្វើសេចក្ដីសម្រេចបានទេនោះ គឺអង្គជំនុំជម្រះនឹងធ្វើ ធី.អឹម.អឹម សាជាថ្មីបន្ថែមទៀតដើម្បី -- លើកដោះស្រាយបញ្ហានេះ។ ប៉ុន្តែយើងមិនទាន់បាន -- យើងបានធ្វើ ធី.អឹម.អឹម រួចហើយ ប៉ុន្តែយើងមិនទាន់បានចេញសេចក្ដីសម្រេចដោយសារមូលហេតុពាក់ព័ន្ធជាមួយនឹងបុគ្គលដទៃទៀត ដែលមានការពាក់ព័ន្ធទៅលើឯកសារថ្មីៗនេះ។ ហើយបញ្ហាទាំងនេះ គឺយើងបានទទួលនូវ -- ភាគីបានមិនៗជំទាស់ទេ។ លើកឡើងដោយសារសហព្រះរាជអាជ្ញាមិនជំទាស់ទេ

ដោយគាត់លើកពីយុត្តិសាស្ត្រអន្តរជាតិក្នុងការដាក់ឯកសាររបៀបនេះ។ ទាំងចំនួនច្រើនផង អន្តរជាតិមានច្រើនជាងនេះទៀត។ នេះជាបញ្ហាត្រូវប្រឹងប្រែងទាំងអស់គ្នា។ ចំពោះអង្គជំនុំជម្រះគឺថានឹងពិនិត្យលទ្ធភាពនេះថាដោះស្រាយយ៉ាងម៉េចនោះ គឺអង្គជំនុំជម្រះនឹងដោះស្រាយ។ បើសិនជាមិនពាក់ព័ន្ធជាមួយនឹងឯកសារ E319/7 ទេ យើងមិនអនុញ្ញាតឱ្យលោកនិយាយតទៅទៀតទេ លើបញ្ហាដដែលនេះ ព្រោះអង្គជំនុំជម្រះបានជជែកពិភាក្សារួចហើយ នៅក្នុងកិច្ចប្រជុំ ធី.អឹម.អឹម កន្លងមកនេះ។

[១៦:០៧:០៤]

**លោក អាកទូរ វែកគែន៖**

លោកប្រធាន ខ្ញុំគ្រាន់តែព្យាយាមពន្យល់មូលហេតុ--

**ប្រធានអង្គជំនុំ៖**

គ្រាន់ប៉ុនណា ក៏លែងឱ្យនិយាយហើយ ពីព្រោះអង្គជំនុំជម្រះស្តាប់ហើយ មកពីលោកមិនចូលទេ លោកមិនចំណាយពេលវេលាក្នុងការចូលរួមក្នុងកិច្ចប្រជុំ ធី.អឹម.អឹម ដែលគេដាក់របៀបវារៈក្នុងការជជែកបញ្ហាហ្នឹងទេ។

**លោក អាកទូរ វែកគែន៖**

ក៏ប៉ុន្តែ ខ្ញុំក៏អានប្រតិចារឹកដែរ លោកប្រធាន ទោះបីជាខ្ញុំមិនចូលរួមក៏ដោយ។

**ប្រធានអង្គជំនុំ៖**

ពេលវេលាសម្រាប់អង្គជំនុំជម្រះធ្វើសវនាការ វាបានកន្លងផុតទៅហើយ។ អង្គុយចុះ!

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី អ៊ំ! សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានមតិយោបល់អ្វីទេលើសំណើសុំរបស់ អូ.ស៊ី.ភី ឯកសារ E319/7?

[១៦:០៨:០១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងអត់មានការជំទាស់ទៅនឹងសាក្សីដែលស្នើដោយសហព្រះរាជអាជ្ញាទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សវនាការថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវ-

នាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី១២ ខែមីនា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ នៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី នាង អ៊ុំច សូមភាគីនិងជ្រាប និងអញ្ជើញចូលរួមតាមកាលវេលាបានកំណត់នេះ។

ហើយអង្គជំនុំជម្រះសូមអរគុណលោក នាង អ៊ុំច ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនៅថ្ងៃស្អែកនេះ គឺទំនងតែ ក្នុងរយៈពេលតែមួយប្រហែលជាជាងមួយម៉ោងប៉ុណ្ណោះ។ ហើយពេលនេះ អង្គជំនុំជម្រះអាច អ៎! លោកអាចវិលត្រឡប់ទៅទីកន្លែងដែលលោកស្នាក់នៅវិញបានហើយ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនលោក នាង អ៊ុំច ហើយរួមទាំងសាក្សីបម្រុងផង TCW-948 ត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ និងឲ្យសូមអញ្ជើញពួកគាត់មកចូលរួមសវនាការនៅថ្ងៃស្អែកវិញឲ្យបានមុនម៉ោងប្រាំបួន។ ហើយលោកមេធាវីប្រឹក្សា មឿន សុវណ្ណ ដូចគ្នាក៏សូមអញ្ជើញលោកមកចូលរួមដើម្បី នៅក្នុងអំឡុងពេលនៃស្ដាប់សក្ខីកម្មសាក្សីទាំងពីររូប ក្នុងនាមជាមេធាវីប្រឹក្សានៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃស្អែកទៀត។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការនៅព្រឹកថ្ងៃស្អែកវិញឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១០ នាទី)*